# ក

# មាតិកា

## I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

## ១.ព្រះរាជក្រឹត្យ


១៧-០២-២០០៩ - ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៧៨ ស្តីពី ការតែងតាំង លោកជំទាវ **ខែក កែមាលី ស៊ីសុជា** ជាឧត្តមប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាបន្ថែមលើមុខងារបច្ចុប្បន្ន ៩៦២១

១៥-១២-២០០៩ - ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៦៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចាវ ហ្សេនជីង** (**ZHAO ZHEN QING**) ជនជាតិចិន សញ្ជាតិកាណាដា កើតនៅ **ក្រុងធានជីង**(**Tianjin**) សាធារណរដ្ឋប្រជាមានិតចិន ៩៦២២

១៥-១២-២០០៩ - ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៦៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ជិន ដាវីស** (**JIN DAVIS**) ជនជាតិចិន សញ្ជាតិកាណាដា កើតនៅខេត្តវ៉ូឆាង សាធារណរដ្ឋប្រជាមានិតចិនដោយប្តូរឈ្មោះជា **ជិន សុវណ្ណ** (**JIN SOVANN**) ៩៦២៣

១៥-១២-២០០៩ - ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៦៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លី ស៊ូយ៉ុង** (**LEE SOO YOUNG**) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ ក្រុង GEON GU សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **ស្រី ជ័យសែន** (**SREY CHEY SEN**) ៩៦២៤

១៨-១២-២០០៩ - ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៦៧ ស្តីពីការតែងតាំងឯកឧត្តមចំនួន០៤រូប ជាទីប្រឹក្សា សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានីតិកាលទី ៤ មានឋានៈស្មើ រដ្ឋលេខាធិការ និង ស្មើអនុរដ្ឋលេខាធិការ ៩៦២៥

១៨-១២-២០០៩ - ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៦៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកឧកញ៉ា,លោកជំទាវ និង អស់លោក ចំនួន ២១ រូប ៩៦២៦

១៨-១២-២០០៩ - ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៦៩ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកជំទាវ និង អស់លោក ចំនួន ៧៥ រូប ៩៦២៧

១៨-១២-២០០៩ - ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៧០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះអស់លោក ចំនួន ២៥ រូប ៩៦៣០


# II. រាជរដ្ឋាភិបាល

## អនុក្រឹត្យ

### <u>សូមអភ័យទោស</u>

.- ដោយមានកំហុសផ្នែកបច្ចេកទេស ក្នុងការចុះផ្សាយអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ចេញផ្សាយក្នុងរាជកិច្ចលេខ ៦៤ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០៩ ។

-យើងខ្ញុំសូមចុះផ្សាយនូវអនុក្រឹត្យខាងលើក្នុងរាជកិច្ចលេខ៩៥ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៩ ទាំងស្រុងឡើងវិញ ។

សូមអរគុណ!


១៩-៨-២០០៩ - អនុក្រឹត្យលេខ ១៣២ អនក្រ.បក ស្តីពីការធ្វើអនុបយោគដីព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ សម្រាប់ សម្បទានដីសង្គមកិច្ច ស្ថិតនៅឃុំរំដោះស្រែ ស្រុកជាំក្សាន ខេត្តព្រះវិហារ ៩៦៣១

១៤-១២-២០០៩ - អនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក ៩៦៣៦

១៤-១២-២០០៩ - អនុក្រឹត្យលេខ ២១៧ អនក្រ.បក ស្តីពី ការបង្កើត ការរៀបចំ និងការប្រព្រឹត្តិទៅនៃ គណៈកម្មា ធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និង គណៈកម្មាធិការសម្របសម្រួល បច្ចេកទេសក្រុមប្រឹក្សាខណ្ឌ នៃរាជធានីភ្នំពេញ ៩៧០៨

១៨-១២-២០០៩ - អនុក្រឹត្យលេខ ១៧៥៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ជូននាយនគរបាលជាតិជាន់ខ្ពស់ ៩៧២១

១៨-១២-២០០៩ - អនុក្រឹត្យលេខ ១៧៥៧ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌ មន្ត្រីរាជការ ក្រសួងកិច្ចការនារី ជូនមន្ត្រីរាជការចំនួន ២ រូប ៩៧២២

១៨-១២-២០០៩ - អនុក្រឹត្យលេខ ១៧៥៨ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៃក្រសួងទេសចរណ៍ ៩៧២៣

១៨-១២-២០០៩ - អនុក្រឹត្យលេខ ១៧៥៩ អនក្រ.តត ស្តីពី ការជូន **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន** ជូនលោកស្រី **Helena Ahola** ៩៧២៤

១៨-១២-២០០៩ - អនុក្រឹត្យលេខ ១៧៦០ អនក្រ.តត ស្តីពី ការជូន **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **ស៊ុន គឹមលី (Mr. SUN KIMLY)** ៩៧២៥

១៨-១២-២០០៩ - អនុក្រឹត្យលេខ ១៧៦១ អនក្រ.តត ស្តីពីការជូន **មេដាយស្ថាបនាជាតិ** ជូននាយទាហាន និង មន្ត្រីរាជការ ចំនួន ០៨ រូប ៩៧២៦

១៨-១២-២០០៩ - អនុក្រឹត្យលេខ ១៧៦២ អនក្រ.តត ស្តីពី ការជូន **មេដាយស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនអង្គការ **Room to Read Cambodia** ៩៧២៧

១៨-១២-២០០៩ - អនុក្រឹត្យលេខ ១៧៦៣ អនក្រ.តត ស្តីពី ការជូន **មេដាយស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនអង្គការ **MASAO HOSONO** ៩៧២៨

១៨-១២-២០០៩ - អនុក្រឹត្យលេខ ១៧៦៤ អនក្រ.តត ស្តីពី ការជូន **មេដាយស្ថាបនាជាតិ** ចំនួន ០៣ គ្រឿង ជូនអង្គការ សមាគម និង ក្រុមហ៊ុន ៩៧២៩


# III-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ


១១-១២-២០០៩ - ប្រកាសលេខ ៦០២ កសក.ប្រក ស្តីពី ការដាក់ឱ្យប្រើប្រាស់នូវបទបញ្ជាផ្ទៃក្នុងគំរូរបស់បុរេសហគមន៍ កសិកម្ម ៩៧៣០

១៥-១២-២០០៩ - ប្រកាសលេខ ៦០៥ កសក.ប្រក ស្តីពី ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃ

# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៧៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

**លោកជំទាវ ខែក កែមាលី ស៊ីសូវ៉ា**

ជា

ឧត្តមប្រឹក្សាផ្ទាល់
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
បន្ថែមលើមុខងារបច្ចុប្បន្ន

៣រ.ល. ០៩០២. ១៩១

**បានប្រមាថព្រះរាជហត្ថលេខាហើយ**

ធ្វើនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩

**នរោត្តម សីហមុនី**

បានឃើញថាត្រឹមត្រូវតាមច្បាប់ដើម
លេខ ...០៩... រ.ទទ
រាជធានីភ្នំពេញ, ថ្ងៃទី ១៧... ខែ កុម្ភៈ... ឆ្នាំ ២០០៩
[illegible] សម្តេចចៅហ្វាវាំង [illegible] អគ្គបតីស្រីដ្ឋារ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
[illegible]

គង់ សំអុល

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៦៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចាវ ចេង្ស៊ីង** (ZHAO ZHEN QING) ជនជាតិចិន សញ្ជាតិកាណាដា កើតថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៦០ នៅក្រុងធានជីង (Tianjin) សាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩ល.០៩១២.១១៩៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៩*

លេខៈ ១០៨៩ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៦៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជិន ដាវីស** (JIN DAVIS) ជនជាតិចិន សញ្ជាតិកាណាដា កើតថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៦៦ នៅខេត្តក្វាំងតុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ជិន សុវណ្ណ** (JIN SOVANN) ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៩១២.១១៧៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១០៩៦ ច.ល
ចម្លងចែកជូន
រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ីន ឆែរេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៦៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សម្ពោហនភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី ស៊ូយ៉ុង** (LEE SOO YOUNG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៥៩ នៅក្រុង GEON GU សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **ស្រី ជ័យសែន** (SREY CHEY SEN) ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៩១២.១១៩០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩*

លេខ:១០៩៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៦៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**__មាត្រា១__** : ត្រូវបានតែងតាំង :

១- **ឯកឧត្តម ហេង ខាង** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

២- **ឯកឧត្តម ច័ន្ទ ចណ្ណៈ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣- **ឯកឧត្តម ឈឹម នែម** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

៤- **ឯកឧត្តម ស៊ូ ចន្ទ្រី** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**__មាត្រា២__** : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**__មាត្រា៣__** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រ៧.០៩១២.១១៩៣

លេខ:១០៩៤ ច.ល
**ជូនចំពោះបង្គំទូលថ្វាយ**

*ធ្វើនៅព្រះបរមរាជវាំង. រាជធានីភ្នំពេញ. ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩*

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៩
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ស៊ុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៦៨

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស **សម្ដេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១- ឯកឧត្ដមអ្នកឧកញ៉ាបណ្ឌិត **សុខ គង់** ២- លោកបណ្ឌិត **ឌុច សារីម**
៣-លោកឧកញ៉ាបណ្ឌិត **លី សាយ យាង** ៤-លោកឧកញ៉ាបណ្ឌិត **ស សេរីវិចិត្រ**

ខ-គ្រឿងឥស្សរិយយស **សម្ដេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេនា** ចំពោះ :

១- ឯកឧត្ដម **ខង ស្វួត** ២- ឯកឧត្ដម **ឈាំម គុសល**
៣- ឯកឧត្ដម **អ៊ុំ ចណ្ណា** ៤- សាស្ត្រាចារ្យបណ្ឌិត **ជា ចំរើន**
៥- ឯកឧត្ដម **ច័ន្ទ ចណ្ណា** ៦- លោកជំទាវ **ហេង ពៅ**

គ-គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** ចំពោះ :

១-លោកឧត្ដមសេនីយ៍ទោ **ហុត ធីន** ២-វរសេនីយ៍ឯក **ចៀត ម៉ាន់ធី**

ឃ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

១-លោកឧត្ដមសេនីយ៍ទោ **ស្វួន ផល្លា**

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះ :

១-លោក **ម៉ី សំណាង** ២-វរសេនីយ៍ឯក **គង់ ហាម**
៣-លោក **គង់ សុធា** ៤-លោក **ធីង ម៉េង**
៥-លោកវរសេនីយ៍ត្រី **អ៊ុំម តែម** ៦-លោក **ចឿង ប្រយុទ្ធ**
៧-លោក **ជិន សុខ** ៨-លោក **ឃឹម សុចណ្ណា**

៣៧.០៩១២.១១៩៤

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩*

លេខៈ ១០៩៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី... ខែ ធ្នូ ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**...ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៦៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ក**- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១- ឯកឧត្តម **ជា អឿង**
២- ឯកឧត្តម **អ៊ុង ឿងរិទ្ធ**
៣- ឯកឧត្តម **ឡុង ហ៊ីប**
៤- ឯកឧត្តម **សោម សុផាត**
៥- ឯកឧត្តម **ឡៅ សារឿន**

**ខ**- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១- លោកជំទាវ **ញៀម សុផានី ខួន ញ៉ិល**
២- ឯកឧត្តម **ម៉េន ស៊ីផាន់**
៣- ឯកឧត្តម **ហង្ស វិចិត្រ**
៤- ឯកឧត្តម **ហាយ ស៊ីទី**
៥- ឯកឧត្តម **គីម សាន់**

**គ**- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១- ឯកឧត្តម **ហ៊ី ទាន់ថន**

**ឃ**- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** ចំពោះ :

១- ឯកឧត្តម **ទ៉ាន់ ផាន់នី**
២- ឯកឧត្តម **គីម សំអុល**
៣- ឯកឧត្តម **ហាប់ អូម៉ារអាលី**
៤- ឯកឧត្តម **ជា ជាតិ**
៥- ឯកឧត្តម **ឡិម គីលី**

**ង**- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** ចំពោះ :

១- ឯកឧត្តម **ហេង ឃួត**

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១- ឯកឧត្តម **រស់ច័ន កុសល**
២- ឯកឧត្តម **ម៉ម ចិន្តារិទ្ធ**
៣- ឯកឧត្តម **ទី ពុន្លីរម្យ**
៤- ឯកឧត្តម **ខូន សុជាតិ**
៥- ឯកឧត្តម **អ៊ុំ សោភារិទ្ធិ**
៦- ឯកឧត្តម **ឡុង សារ៉ាទី**
៧- ឯកឧត្តម **ទ៉ោ ហៃហុង**
៨- ឯកឧត្តម **សេង សុជាតិ**
៩- ឯកឧត្តម **គង់ ឪឡា**
១០- ឯកឧត្តម **ប៊ុន នី**
១១- ឯកឧត្តម **ឈិនលីម សាធុន**
១២- ឯកឧត្តម **ហែម ចន្ទ្រសៀ**
១៣- ឯកឧត្តម **យ៉ាញ់ សុមិត្ត**
១៤- ឯកឧត្តម **នេព ចាសនា**
១៥- ឯកឧត្តម **គុង ប៉េងខួន**
១៦- ឯកឧត្តម **ឌី ជារាធុន**
១៧- ឯកឧត្តម **ជិន រដ្ឋា**
១៨- ឯកឧត្តម **ហួត ចាន់ថូ**
១៩- ឯកឧត្តម **ឈាង ណារិន**
២០- ឯកឧត្តម **ជា គីមហាន**

ឆ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១- ឯកឧត្តម **អ៊ុំ សៀង**
២- ឯកឧត្តម **យិន សុខ**
៣- ឯកឧត្តម **ជា ហៀង**
៤- ឯកឧត្តម **ម៉ៅ ឡាំង**
៥- ឯកឧត្តម **នេន ម៉ាលំយ**

ជ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះ :

១- ឯកឧត្តម **ចាន ឈៀងឈុន**
២- ឯកឧត្តម **នួច សែ**
៣- ឯកឧត្តម **ឈៀង សុខហៀង**
៤- ឯកឧត្តម **ឡេង ចន្ថា**
៥- លោកជំទាវ **យ៉ាង ចាន់ហាន់**
៦- ឯកឧត្តម **យឹម សុខា**
៧- ឯកឧត្តម **ថូ សំអាង**
៨- ឯកឧត្តម **ហូ គុងហៃ**
៩- ឯកឧត្តម **ឡឹង កែច**
១០- ឯកឧត្តម **មិត សាឡាង**
១១- ឯកឧត្តម **គុយ មីន**
១២- លោក **ញៀម រដ្ឋា**
១៣- លោកស្រី **អ៊ុង រិទ្ធរតនា**
១៤- លោក **ស្រី សុផល**
១៥- លោក **ជា គី**
១៦- លោក **គីម សេង**
១៧- លោក **ចាន់ ប៊ុនធឿន**
១៨- លោក **អោម ជីលុច**
១៩- លោក **ឆន ផាន**
២០- លោក **មូល ប៊ុណ្ណារិន**
២១- លោក **យឹម ជួងដេត**
២២- លោក **រុន រឿន**

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**ឈ-** គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សរិទ្ធិ** ចំពោះ :

១- លោក **គង់ នឿន**
២- លោក **ថន សារ៉ាត**
៣- លោក **ម៉ឿន សារើន**
៤- លោក **ជុំ សោភ័ណ្ឌ**
៥- លោក **សំ វណ្ណសៀម**
៦- លោក **តា គីរៈ**
៧- លោក **ពុំ តារ៉ាត់**
៨- លោក **ញ៉ៀម ប៊ូរ៉ា**
៩- លោក **សែម គីមស្រន់**

**ញ-** គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **អស្សរិទ្ធិ** ចំពោះ :

១- លោក **ជួ សុខចំរើន**
២- លោក **ចាន់ សុផុន**

៣៧/ល. ០៩១២. ១១៥៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩*

លេខ: ១១៧៤ .ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឃុន ឋិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

- លោកឧកញ៉ា **គុង បូរ៉ាល**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

១- ឧត្តមសេនីយ៍ត្រី **រុន សុវណ្ណា**
២- ឧត្តមសេនីយ៍ត្រី **ពុំ ចិត្រា**
៣- ឧត្តមសេនីយ៍ត្រី **ព្រាហ្ម និមល**
៤- វរសេនីយ៍ឯក **សុខ វាសនា**
៥- វរសេនីយ៍ឯក **ព្រុំ បូរ៉ាធឿន**
៦- វរសេនីយ៍ទោ **តាន់ សុខវិជ្ជា**
៧- វរសេនីយ៍ទោ **ធៀប ប៊ុនលាភ**
៨- វរសេនីយ៍ទោ **ថ្មើន នារី**
៩- វរសេនីយ៍ទោ **លុញ ប្លង់**
១០- វរសេនីយ៍ទោ **ស៊ុយ សុភាព**
១១- វរសេនីយ៍ទោ **ឃួន ផែលល**
១២- វរសេនីយ៍ទោ **ពេជ កោសលមុនី**
១៣- វរសេនីយ៍ទោ **អ៊ិត ចេតនា**
១៤- វរសេនីយ៍ទោ **ឌុល ស៊ីថុល**
១៥- វរសេនីយ៍ទោ **នាង សុឃាង**
១៦- វរសេនីយ៍ត្រី **តូច ពិជោឡា**
១៧- វរសេនីយ៍ត្រី **ចាន់ សុខា**
១៨- លោក **នុយ ប៊ុនសេរីវត្តមុនី**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

១- វរសេនីយ៍ទោ **ណែម ចំនួថេត**
២- អនុសេនីយ៍ឯក **ឆាម ចន្ថា**
៣- អនុសេនីយ៍ឯក **ស៊ាង សុធារិទ្ធ**
៤- អនុសេនីយ៍ទោ **ស្រ៊ី ម៉េងស្រ៊ាន់**
៥- អនុសេនីយ៍ទោ **ហ៊ាន ពេជ្រសទ្វារ**
៦- អនុសេនីយ៍ត្រី **អ៊ុយ ស៊ីថារ៉ាវុធ**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ០៩១២. ១១៩៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩*

លេខ: ១១៧២ច.ល

**ចម្លងចែក**

ភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០០៩

**[illegible]រាជរដ្ឋាភិបាល**

**[illegible] ជិនកេន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ សម្រាប់សម្បទានដីសង្គមកិច្ច ស្ថិតនៅឃុំរំដោះស្រែ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ

របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ ... ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

### មាត្រា ១.-

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀតនូវដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ទំហំប្រាំរយសាមសិបបួនហិកតា (៥៣៤ហិកតា) ស្ថិតនៅឃុំរំដោះស្រែ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ហើយកំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម :

A(៤៧៩០៦៧ , ១៥៧១៥៧៧) B(៤៧៩៣៤៣ , ១៥៧៣០០៥) C(៤៨១៨៧៦ , ១៥៧៣១៧៥)
D(៤៨១៨៧៦ , ១៥៧២០៧៧) E(៤៨២០០០ , ១៥៧២០៧៧) F(៤៨២០០០ , ១៥៧១០៧៧)
G(៤៨១៥០០ , ១៥៧១០៧៧) H(៤៨១៥០០ , ១៥៧១៥៧៧) និង I(៤៨៣២៧១ , ១៥៧២៩៨០)
J(៤៨៣៧៨១ , ១៥៧២៩២០) K(៤៨៤៣៣០, ១៥៧២៦៤៦) L(៤៨៤៣៣០ , ១៥៧១៥៧៧)
M(៤៨៤០០០ , ១៥៧១៥៧៧) N(៤៨៤០០០ , ១៥៧២០៧៧) O(៤៨៣២៧១ , ១៥៧២០៧៧) ។

### មាត្រា ២.-

ត្រូវបានរំសាយផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ចេញពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ។

### មាត្រា ៣.-

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ប្រាំរយសាមសិបបួនហិកតា (៥៣៤ហិកតា) ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

### មាត្រា ៤.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋទំហំ ប្រាំរយសាមសិបបួនហិកតា(៥៣៤ហិកតា) ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(រដ្ឋបាលព្រៃឈើ) ជាអាជ្ញាធរកាន់កាប់ដីរដ្ឋ

ដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋ សម្រាប់បែងចែកជាដីសម្បទានសង្គមកិច្ចជូនគ្រួសារយោធិននៃវរសេនាតូចលេខ ២ តំបន់ប្រតិបត្តិការសឹករងព្រះវិហារ និង ផ្នែកសឹករងជាំក្សាន្ត ស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល និងតម្រូវការជាក់ស្តែង ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ពន្ធ័ និង អភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ .

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អង្គទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៦
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០០៩ ស្តីពីការធ្វើអនុបយោគដីព្រៃបម្រុងទុក
អចិន្ត្រៃយ៍របស់រដ្ឋ សំរាប់សម្បទានដីសង្គមកិច្ច ស្ថិតនៅឃុំរំដោះស្រែ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ




**និយាមការតំបន់ទី១**

| | | |
|---|---|---|
| A | 479067 | 1571577 |
| B | 479343 | 1573005 |
| C | 481876 | 1573175 |
| D | 481876 | 1572077 |
| E | 482000 | 1572077 |
| F | 482000 | 1571077 |
| G | 481500 | 1571077 |
| H | 481500 | 1571577 |

**និយាមការតំបន់ទី២**

| | | |
|---|---|---|
| I | 483271 | 1572980 |
| J | 483781 | 1572920 |
| K | 484330 | 1572646 |
| L | 484330 | 1571577 |
| M | 484000 | 1571577 |
| N | 484000 | 1572077 |
| O | 483271 | 1572077 |

**សញ្ញាសំគាល់**

# ទីតាំងស្នើសុំ តំបន់រៀបចំគ្រួសារកងទ័ព របស់តំបន់ប្រតិបត្តិការសឹករងព្រះវិហារ



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ២១៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត របស់ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង របស់ក្រុមប្រឹក្សានិងគណៈអភិបាលស្រុក ព្រមទាំងទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត ជាមួយរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ក្នុងខេត្ត និងរដ្ឋបាលទាំងនេះជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ។

**មាត្រា ២.-**

រដ្ឋបាលខេត្តដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត ។

រដ្ឋបាលក្រុងដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលក្រុង ។

រដ្ឋបាលស្រុកដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលស្រុក ។

**មាត្រា ៣.-**

ខេត្ត ក្រុង ស្រុក ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ។

**មាត្រា ៤.-**

ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងខេត្ត ត្រូវមានក្រុមប្រឹក្សារៀងៗខ្លួនជាតំណាង ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥.-**

រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ទទួលសិទ្ធិអំណាចរបស់ខ្លួនដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀតដែលស្របនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

## ជំពូកទី២

## រដ្ឋបាលខេត្ត

### ផ្នែកទី១

### ក្រុមប្រឹក្សាខេត្ត

**មាត្រា ៦.-**

ក្រុមប្រឹក្សាខេត្តដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ

ជាអ្នកការពារនិងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ៧.-**

ក្រុមប្រឹក្សាខេត្ត ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលនៅជាធរមាន។

**មាត្រា ៨.-**

ក្រុមប្រឹក្សាខេត្ត មានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្ម ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៩.-**

ក្នុងអំឡុងត្រីមាសទី៤នៃឆ្នាំនីមួយៗ ក្រុមប្រឹក្សាខេត្តត្រូវរៀបចំឱ្យមានវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ នៅតាមក្រុងនិងស្រុកនានាក្នុងខេត្ត។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ ត្រូវចូលរួមដោយសមាជិកក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត សមាជិកក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង សមាជិកក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក សមាជិកក្រុមប្រឹក្សាឃុំ សមាជិកក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត តំណាងសហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធដទៃទៀតតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ មានគោលបំណងដើម្បីឱ្យក្រុមប្រឹក្សាខេត្តជម្រាបជូនក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធនានា អំពីសកម្មភាពរបស់ក្រុមប្រឹក្សាខេត្តក្នុងរយៈពេលមួយ(០១)ឆ្នាំ ការឆ្លើយតបចំពោះសំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ការពិភាក្សាស្រាយបំភ្លឺអំពីបញ្ហានានាដល់អ្នកចូលរួម និងការប្រមូលមតិយោបល់នានាពីអ្នកចូលរួម ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន។

ប្រធានក្រុមប្រឹក្សាខេត្ត ជាអ្នកសម្របសម្រួលក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះ។

គណៈអភិបាលខេត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើការបូកសរុប វាយតម្លៃអំពីលទ្ធផលនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះយ៉ាងយូរដប់ប្រាំ(១៥)ថ្ងៃបន្ទាប់។ ក្នុងការបូកសរុបវាយតម្លៃនេះ ត្រូវលើកឡើងនូវគោលការណ៍ វិធានការ ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន ក្នុងក្របខ័ណ្ឌតួនាទីសមត្ថកិច្ចរបស់រដ្ឋបាលខេត្ត។ ចំពោះកិច្ចការទាំងឡាយណា ដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀត រដ្ឋបាលខេត្តត្រូវពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាដែលពាក់ព័ន្ធទាំងនោះ ដើម្បីលើកឡើងអំពីគោលការណ៍ វិធានការ ដោះស្រាយ

តាមសមត្ថកិច្ចរៀងៗខ្លួន។ ចំពោះកិច្ចការដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរបស់ថ្នាក់ជាតិ រដ្ឋបាលខេត្តត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រសួងមហាផ្ទៃ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំបន្ថែមទៀតអំពីការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់តាមការចាំបាច់។

**មាត្រា ១០.-**

ក្រុមប្រឹក្សាខេត្ត ត្រូវបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈដីកា និងសេចក្តីសម្រេចនានាក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនោះ ត្រូវបានអនុវត្តដោយមានការតាមដាននិងវាយតម្លៃជាប្រចាំ។

**មាត្រា ១១.-**

កិច្ចប្រជុំក្រុមប្រឹក្សាខេត្ត អាចយកជាការបានលុះត្រាតែកិច្ចប្រជុំនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន។

សេចក្តីសម្រេចទាំងឡាយណា ដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន មិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវណែនាំ ឬអាចធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាកែតម្រូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះឡើងវិញ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាខេត្ត អាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការឬអនុគណៈកម្មាធិការឬក្រុមការងារនានា ដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់។ ក្នុងករណីនេះ គណៈអភិបាលខេត្តត្រូវដឹកនាំនាយករដ្ឋបាលសាលាខេត្ត និងទីចាត់ការពាក់ព័ន្ធនៃសាលាខេត្ត ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ។

គណៈអភិបាលខេត្ត ដោយមាននាយករដ្ឋបាលសាលាខេត្តជាជំនួយការ ត្រូវធ្វើការសម្របសម្រួល ណែនាំដល់ទីចាត់ការនានានៃសាលាខេត្ត រៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេច ដើម្បីដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យពិភាក្សា និងអនុម័ត។

អភិបាលខេត្ត ត្រូវណែនាំនាយករដ្ឋបាលសាលាខេត្ត ឱ្យរៀបចំដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច ឱ្យស្របតាមទម្រង់ដែលកំណត់ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាខេត្តចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន និងត្រូវប្រថាប់ត្រារដ្ឋបាលខេត្ត។

ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យអភិបាលខេត្តចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេចទាំងឡាយណាដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះ ព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

**មាត្រា ១៣.-**

ប្រធានក្រុមប្រឹក្សាខេត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានសិទ្ធិចុះហត្ថលេខានិងប្រថាប់ត្រារដ្ឋបាលខេត្តលើ :

- ដីកាឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាខេត្ត
- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាខេត្ត
- សំណើដកហូតអភិបាលខេត្តឬអភិបាលរងខេត្តចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត តាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា១៥២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាខេត្ត
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តរយៈពេលដប់ពីរ(១២)ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាខេត្ត
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

គណៈអភិបាលខេត្ត ត្រូវជួយក្រុមប្រឹក្សារបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែឯកសារក្នុងចំណុចគំនូសទី៤។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំអំពីទម្រង់នៃឯកសារខាងលើតាមការចាំបាច់។

**មាត្រា ១៤.-**

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលខេត្ត និងវិធានការ បែបបទ នីតិវិធីចាត់ចែងការងារ តាមការចាំបាច់ដែលទាក់ទងទៅនឹង :

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីដែលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាខេត្ត
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលខេត្ត
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាខេត្ត
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត

- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាខេត្ត ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនិងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត
- ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលខេត្ត
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ១៥.-**

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាខេត្តត្រូវធ្វើការសម្រេចរៀងរាល់កិច្ចប្រជុំដូចមានចែងក្នុងមាត្រា១៤នៃអនុក្រឹត្យនេះ ក្រុមប្រឹក្សាខេត្តអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន :

- ការកោះអញ្ជើញអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬគណៈអភិបាលខេត្ត ឬបុគ្គលដែលពាក់ព័ន្ធ មកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ឬហេតុការណ៍ណាមួយដែលកើតមានក្នុងខេត្ត ឬការដោះស្រាយបញ្ហាបន្ទាន់និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលខេត្ត
- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាខេត្តយល់ថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវឬការធ្វើអង្កេតនេះ ព្រមទាំងណែនាំដល់គណៈអភិបាលខេត្តអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ
- ការពិនិត្យ ស្រាវជ្រាវ និងការធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាច ដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សាខេត្ត ឬសមាជិកក្រុមប្រឹក្សាខេត្ត ឬគណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត តាមគោលការណ៍ដូចមានចែងក្នុងផ្នែកទី៥ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់និងនីតិវិធីជាធរមាន
- ការពិនិត្យនិងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ពិនិត្យនិងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលខេត្ត
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្តយល់ឃើញថាចាំបាច់។

**មាត្រា ១៦.-**

ក្រុមប្រឹក្សាខេត្ត ត្រូវប្រើប្រាស់អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ។

ក្នុងករណីកិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទនិងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យគណៈអភិបាលខេត្តធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទនិងនីតិវិធីសមស្រប ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យនិងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនេះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធនានាធ្វើការបញ្ជាក់នូវបែបបទ នីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនេះ ។

ក្នុងករណីកិច្ចការណាមួយដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទនិងនីតិវិធីនោះចែងមិនច្បាស់លាស់ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាខេត្តមិនអាចអនុវត្តបាន ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យគណៈអភិបាលខេត្តធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់ ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវផ្អែកតាមយន្តការនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.) ធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យនិងដោះស្រាយករណីនេះ ។

**មាត្រា ១៧.-**

អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាខេត្តបានសម្រេចរួចហើយ គណៈអភិបាលខេត្តត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

គណៈអភិបាលខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត ដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥នៃអនុក្រឹត្យនេះ ។

ក្រុមប្រឹក្សាខេត្ត ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលខេត្តដើម្បីធានាថាគណៈអភិបាលខេត្តអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ។

គ.ជ.អ.ប. ត្រូវដាក់ចេញនូវគោលការណ៍ណែនាំ គាំទ្រដល់ក្រុមប្រឹក្សាខេត្តក្នុងការរៀបចំនូវប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត ។

## ផ្នែកទី២

## អំពីគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត

**មាត្រា ១៨.-**

ក្រុមប្រឹក្សាខេត្ត ត្រូវមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមាន :

– គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
– គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ
– គណៈកម្មាធិការលទ្ធកម្ម ។

កិច្ចដំណើរការនៃគណៈកម្មាធិការទាំងបីខាងលើ ត្រូវផ្អែកតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទាំងនេះ ។

**មាត្រា ១៩.-**

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាខេត្តអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទាំងបីដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឡើយ ។

ក្រុមប្រឹក្សាខេត្តអាចបង្កើតអនុគណៈកម្មាធិការឬក្រុមការងារផ្សេងៗទៀត តាមការស្នើសុំរបស់គណៈកម្មាធិការនានាឬគណៈអភិបាលខេត្ត ។

អនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ ត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការឬគណៈអភិបាលខេត្ត ។

**មាត្រា ២០.-**

ក្រុមប្រឹក្សាខេត្ត អាចតែងតាំងសមាជិកក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត អភិបាលរងខេត្ត បុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត តំណាងក្រុមប្រឹក្សាប្រភេទផ្សេងទៀតក្នុងដែនសមត្ថកិច្ចរបស់ខេត្ត តំណាងសហគមន៍ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់ ជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង ។

ក្រុមប្រឹក្សាខេត្ត ត្រូវសម្រេចពីចំនួនសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ការតែងតាំងប្រធាន អនុប្រធាន និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាដែលខ្លួនបានបង្កើតឡើង ។

គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ត្រូវមានតំណាងស្ត្រីសមស្រប រួមទាំងតំណែងប្រធាន ឬ អនុប្រធានគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារផង ។

ក្រុមប្រឹក្សាខេត្ត អាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង តាមការចាំបាច់ ឬតាមសំណើរបស់គណៈកម្មាធិការ ឬគណៈអភិបាលខេត្ត ។

**មាត្រា ២១.-**

គណៈអភិបាលខេត្ត អាចស្នើសុំក្រុមប្រឹក្សាខេត្តដើម្បីឱ្យគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយដែលក្រុមប្រឹក្សាខេត្តបានបង្កើតឡើង រួមទាំងគណៈកម្មាធិការទាំងបី(០៣)ដែលតម្រូវឱ្យបង្កើតឡើងដោយ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយ ឬមួយចំនួន ដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត។

**មាត្រា ២២.-**

ក្រុមប្រឹក្សាខេត្ត ត្រូវទទួលខុសត្រូវរាល់ការសម្រេចនិងសកម្មភាពរបស់គណៈកម្មាធិការនានា និងទទួលខុសត្រូវចំពោះផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ។

**មាត្រា ២៣.-**

ក្រុមប្រឹក្សាខេត្ត ត្រូវណែនាំឱ្យគណៈអភិបាលខេត្តផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់ និងបច្ចេកទេស ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការទាំងបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាខេត្តបានបង្កើតឡើង។

**មាត្រា ២៤.-**

គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមតម្រូវការចាំបាច់នានា។

សេចក្តីរាយការណ៍ខាងលើនេះ ត្រូវចម្លងជូនគណៈអភិបាលខេត្ត ដើម្បីធ្វើការបូកសរុប និងរាយការណ៍ជូនក្រុមប្រឹក្សាខេត្ត។

ក្រុមប្រឹក្សាខេត្ត អាចតម្រូវឱ្យគណៈកម្មាធិការណាមួយរាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេសនិងបន្ទាន់ណាមួយក្នុងកិច្ចប្រជុំរបស់ខ្លួនតាមការចាំបាច់។

## ផ្នែកទី៣

## គណៈអភិបាលខេត្ត

**មាត្រា ២៥.-**

ខេត្តនីមួយៗ ត្រូវមានគណៈអភិបាលខេត្តមួយដែលរួមមាន អភិបាលខេត្ត អភិបាលរងខេត្ត ដែលត្រូវបានតែងតាំងឡើងស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ២៦.-**

អភិបាលខេត្ត អភិបាលរងខេត្ត មិនមែនជាសមាជិកក្រុមប្រឹក្សាខេត្តឡើយ។

**មាត្រា ២៧.-**

គណៈអភិបាលខេត្ត ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន អំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ២៨.-**

គណៈអភិបាលខេត្ត មានភារកិច្ចផ្តល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សាខេត្ត និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។

**មាត្រា ២៩.-**

គណៈអភិបាលខេត្ត ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្តអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាខេត្ត ដើម្បីក្រុមប្រឹក្សាខេត្តធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញ ទាក់ទងនឹង :

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាខេត្ត និងរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការបង្កើត ការកែសម្រួល ឬការរំសាយទីចាត់ការ ឬការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរសក្តិ និងការបញ្ឈប់បុគ្គលិក
- ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្ស និងកម្រៃផ្សេងៗនៃបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាខេត្ត ពិនិត្យ និងអនុម័តមិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ដែលពាក់ព័ន្ធនឹង :
  + ដីកានិងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាខេត្ត និងសកម្មភាព លទ្ធផលនៃការអនុវត្ត
  + របាយការណ៍ហិរញ្ញវត្ថុ
  + ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលខេត្តនិងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
  + វិធានការចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាខេត្ត

+ វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ

+ កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាខេត្តយល់ឃើញថា ចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។

– របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស

– ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាខេត្ត

– ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្តារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានា ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

– កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ៣០.-**

នៅពេលបានទទួលរបាយការណ៍ឬព័ត៌មានអំពីការរំលោភអំណាចដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលខេត្តត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថា មានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលខេត្តត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនក្រុមប្រឹក្សាខេត្តនិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៣១.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា២៩ និងមាត្រា៣០ នៃអនុក្រឹត្យនេះ និងការងារដទៃទៀតដែលខ្លួនយល់ឃើញថាចាំបាច់ អភិបាលខេត្តត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលរបស់ខ្លួនដោយឈរលើគោលការណ៍ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេច និងគោលការណ៍ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន។

អភិបាលខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាខេត្តអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរបស់ខ្លួន។

អភិបាលរងខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលខេត្ត លើភារកិច្ចនានាដែលបានប្រគល់ ហើយត្រូវរួមជាមួយអភិបាលខេត្តទទួលខុសត្រូវអំពីការសម្រេចនិងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន។

ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលខេត្តត្រូវជួបប្រជុំគ្នាប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ។

ក្រៅពីការប្រជុំប្រចាំអឌ្ឍមាសនិងការប្រជុំប្រចាំខែខាងលើ គណៈអភិបាលខេត្តអាចកោះប្រជុំតាមការចាំបាច់។

រៀងរាល់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។

**មាត្រា ៣២.-**

គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ដែលបានសម្រេច និង/ឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាខេត្ត ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ ។

គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពខាងលើនេះ ។

**មាត្រា ៣៣.-**

គណៈអភិបាលខេត្ត ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលខេត្ត និងអភិបាលរងខេត្ត ហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីការបែងចែកភារកិច្ចដល់អភិបាលខេត្ត អភិបាលរងខេត្ត និងរបៀបរបបអនុវត្តភារកិច្ចដែលបានបែងចែកនោះ ។

**មាត្រា ៣៤.-**

អភិបាលខេត្ត ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សារបស់ខ្លួន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាខេត្តចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ ។

អភិបាលខេត្ត អាចប្រគល់សិទ្ធិដល់អភិបាលរងខេត្តក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងខេត្តនីមួយៗ ។

អភិបាលខេត្ត ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងខេត្ត ។

អភិបាលខេត្ត មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងខេត្តណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់ និងមិនស្របតាមបែបបទ នីតិវិធី ។ ការប្រគល់និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលខេត្តត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការប្រគល់សិទ្ធិចុះហត្ថលេខានេះ ។

**មាត្រា ៣៥.-**

ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងខេត្ត អភិបាលខេត្តមានភារកិច្ច :

- ណែនាំដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ឱ្យអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងមន្ទីរ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ

- សម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅខេត្ត ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលជាមួយមន្ទីរ អង្គភាព និងទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តកិច្ចការនោះដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ក្នុងការធ្វើសមាហរណកម្មផែនការនិងថវិការបស់ខ្លួនទៅក្នុងផែនការនិងថវិការបស់ក្រុមប្រឹក្សាខេត្ត។
- ពិនិត្យ វាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានា តាមគោលការណ៍កំណត់
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខេត្តជាមុន ក្នុងការផ្តល់យោបល់ដល់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នលើបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានាដែលប្រចាំនៅខេត្ត។ ក្នុងករណីមិនគាំទ្រចំពោះបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពណាមួយ អភិបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់អំពីហេតុផលដែលមិនគាំទ្រនោះជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដើម្បីពិនិត្យពិចារណា។ ក្នុងករណីរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីឯកភាពតាមរបាយការណ៍របស់អភិបាលខេត្ត រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវផ្លាស់ប្តូរបេក្ខភាពដែលបានស្នើឡើងឱ្យបានសមស្រប។ ក្នុងករណីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីស្រាវជ្រាវឃើញថា ហេតុផលដែលបានបញ្ជាក់ក្នុងរបាយការណ៍របស់អភិបាលខេត្តពុំមានមូលដ្ឋានច្បាស់លាស់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវបញ្ជាក់ជូនអភិបាលខេត្ត ដើម្បីទទួលយកបេក្ខភាពដែលបានស្នើតែងតាំងនោះ។ ក្នុងករណីមិនមានការឯកភាពរវាងអភិបាលខេត្ត ជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីទៅលើបេក្ខភាពដែលស្នើតែងតាំងនោះ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ សម្រេច។ អភិបាលខេត្តត្រូវរាយការណ៍ករណីនេះជូនក្រុមប្រឹក្សារបស់ខ្លួននិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ក្នុងករណីពិនិត្យឃើញភាពមិនប្រក្រតីក្នុងមន្ទីរ អង្គភាព និងទីភ្នាក់ងារណាមួយ ឬការប្រព្រឹត្តខុសឆ្គងរបស់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយ អភិបាលខេត្តត្រូវធ្វើការណែនាំជាបន្ទាន់ដល់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះ ឱ្យធ្វើការកែលម្អឡើងវិញជាបន្ទាន់។ ក្នុងករណីប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះមិនបានកែប្រែ ឬក្នុងករណីភាពមិនប្រក្រតីឬការប្រព្រឹត្តខុសឆ្គងខាងលើមានលក្ខណៈធ្ងន់ធ្ងរ អភិបាលខេត្តត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីនៃមន្ទីរ អង្គភាព និងទីភ្នាក់ងារទាំងនោះ។ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីត្រូវធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ដើម្បីដោះស្រាយទៅតាមច្បាប់។

– អភិបាលខេត្ត មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីឬប្រធានស្ថាប័ន ដើម្បីដកហូតពីមុខតំណែងនូវប្រធានមន្ទីរ អង្គភាព ឬអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយដែលប្រព្រឹត្តខុសឆ្គង ហើយដែលមិនអាចធ្វើយុត្តិកម្មបាន ។

ដើម្បីធានាឱ្យអភិបាលខេត្តអនុវត្តនូវតួនាទី ភារកិច្ចខាងលើនេះ សេចក្តីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវដាក់ជូនអភិបាលខេត្តដើម្បីពិនិត្យ ផ្តល់យោបល់ជាមុន ។ ប្រសិនបើឯកភាព អភិបាលខេត្តត្រូវចុះហត្ថលេខាលើរបាយការណ៍នេះជាមួយប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ ។ ចំពោះសេចក្តីរាយការណ៍ក្រៅពីនោះរបស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ត្រូវចម្លងជូនសាលាខេត្ត ។

**មាត្រា ៣៦.-**

អភិបាលខេត្ត ត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារនិងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងខេត្ត ។

អភិបាលខេត្ត គឺជាប្រធានគណៈបញ្ជាការឯកភាពខេត្ត ក្នុងការដឹកនាំ សម្របសម្រួលមន្ទីរ អង្គភាពពាក់ព័ន្ធនានា រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងខេត្ត ។

**មាត្រា ៣៧.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៣៥និងមាត្រា៣៦នៃអនុក្រឹត្យនេះ អភិបាលខេត្តត្រូវធ្វើការបែងចែកភារកិច្ចដល់អភិបាលរងខេត្តក្នុងគណៈអភិបាលរបស់ខ្លួន ឱ្យជួយក្នុងការងារខាងលើនេះ ។

អភិបាលរងខេត្តដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខអភិបាលខេត្ត ។

អភិបាលខេត្ត ត្រូវកោះប្រជុំគណៈអភិបាលខេត្តតាមការចាំបាច់ ដើម្បីពិគ្រោះពិភាក្សាលើបញ្ហាណាមួយដែលខ្លួនយល់ឃើញថាចាំបាច់ត្រូវធ្វើការពិភាក្សាក្នុងគណៈអភិបាលខេត្ត សំដៅលើកកម្ពស់ការចូលរួមអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា ។

គ្រប់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុប្រជុំ ។

**មាត្រា ៣៨.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៣៥និងមាត្រា៣៦នៃអនុក្រឹត្យនេះ អភិបាលខេត្តត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា ស្របទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ។

**មាត្រា ៣៩.-**

អភិបាលខេត្ត ដោយមាននាយករដ្ឋបាលសាលាខេត្តជាជំនួយការ ត្រូវធ្វើសេចក្តីរាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាលនិងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះ ក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន ។

ក្នុងករណីមានបញ្ហាណាមួយដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលខេត្តក្នុងនាមជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារ តវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាខេត្តអាចតម្រូវឱ្យអភិបាលខេត្តធ្វើសេចក្តីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ។

ក្រុមប្រឹក្សាខេត្ត អាចផ្តល់អនុសាសន៍ និងការណែនាំដល់អភិបាលខេត្តអំពីការអនុវត្តតួនាទីខាងលើនេះ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាពនិងបញ្ហាប្រឈមនានារបស់មូលដ្ឋាន ។

អភិបាលខេត្ត ត្រូវទទួលយកអនុសាសន៍និងការណែនាំពីក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធ្វើការណែនាំ សម្របសម្រួល និងតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ក្នុងការឆ្លើយតបតម្រូវការទាំងនោះ ហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនវិញ ។

**មាត្រា ៤០.-**

ក្នុងករណីអភិបាលខេត្តអវត្តមាន អភិបាលខេត្តត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងខេត្តមួយរូបឱ្យទទួលជាអភិបាលខេត្តស្តីទី ។

ប្រសិនបើអភិបាលខេត្តអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងខេត្តដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃអនុក្រឹត្យតែងតាំងអភិបាលរងនៃគណៈអភិបាលខេត្ត ត្រូវធ្វើជាអភិបាលខេត្តស្តីទី ។

ក្នុងករណីអភិបាលខេត្តស្តីទីអវត្តមាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាស ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងខេត្តមួយរូបឱ្យទទួលជាអភិបាលខេត្តស្តីទី ។

អភិបាលខេត្តស្តីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលខេត្ត នៅពេលដែលអភិបាលខេត្តមានវត្តមានវិញ ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្ទេរសិទ្ធិនេះ ។

**មាត្រា ៤១.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើសេចក្តីណែនាំស្តីពីការសុំច្បាប់ឈប់សម្រាករបស់អភិបាលខេត្ត អភិបាលរងខេត្ត និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត ។

## ផ្នែកទី៤

## នាយករដ្ឋបាលសាលាខេត្ត

**មាត្រា ៤២.-**

ក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្ត ត្រូវមាននាយករដ្ឋបាលមួយ(០១)រូប ហៅថានាយករដ្ឋបាលសាលាខេត្ត

ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមសំណើពីអភិបាលខេត្ត យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាខេត្ត។

នាយករដ្ឋបាលសាលាខេត្ត ត្រូវមាននាយករងរដ្ឋបាលពីរ(០២)រូបជាជំនួយការ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមសំណើពីអភិបាលខេត្ត យោងតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត។

នាយករដ្ឋបាលសាលាខេត្ត ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរស័ក្តិចាប់ពីអនុមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ។

នាយករងរដ្ឋបាលសាលាខេត្ត ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរស័ក្តិចាប់ពីនាយក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

**មាត្រា ៤៣.-**

លក្ខណសម្បត្តិនិងនីតិវិធីសម្រាប់ការតែងតាំងនាយករដ្ឋបាលសាលាខេត្ត និងនាយករងរដ្ឋបាលសាលាខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញប្រកាសឬសេចក្តីណែនាំអំពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់នាយករដ្ឋបាលសាលាខេត្ត និងនាយករងរដ្ឋបាលសាលាខេត្ត។

**មាត្រា ៤៤.-**

នាយករដ្ឋបាលសាលាខេត្ត មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងអភិបាលខេត្តក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងការធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខេត្ត។

ក្នុងតួនាទីនេះ នាយករដ្ឋបាលសាលាខេត្តត្រូវធ្វើរបាយការណ៍ និងត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាលខេត្ត អភិបាលខេត្ត និងក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ៤៥.-**

ក្នុងការអនុវត្តតួនាទីដូចមានចែងក្នុងមាត្រា៤៤នៃអនុក្រឹត្យនេះ នាយករដ្ឋបាលសាលាខេត្តមានភារកិច្ច :

- រៀបចំនិងដាក់ជូនគណៈអភិបាលខេត្ត ពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខេត្ត ផ្អែកតាមក្របខ័ណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត ហើយត្រូវធានាថាកិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល
- រៀបចំនិងដាក់ជូនគណៈអភិបាលខេត្ត នូវវិធាននិងគោលការណ៍ក្នុងការអនុវត្តដីកានិងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត
- ធ្វើជាសេនាធិការជូនអភិបាលខេត្តនិងប្រធានក្រុមប្រឹក្សាខេត្ត ក្នុងការត្រៀមរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខេត្ត រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារនិងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខេត្ត ស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ សេចក្តីព្រាងរបៀបវារៈ ឯកសារ និងខ្លឹមសារទាំងអស់ដែលនាយករដ្ឋបាលសាលាខេត្ត បានរៀបចំសម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត ត្រូវតែដាក់ជូនគណៈអភិបាលខេត្ត ដើម្បីពិនិត្យ

និងផ្តល់យោបល់ជាមុន លើកលែងតែមានការកំណត់ផ្សេងដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ។

- ធ្វើជាសេនាធិការជូនក្រុមប្រឹក្សាខេត្តក្នុងការរៀបចំនិងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខេត្ត
- ត្រៀមរៀបចំកិច្ចការនានាសម្រាប់បម្រើឱ្យកិច្ចប្រជុំទាំងអស់របស់គណៈអភិបាលខេត្ត តាមការណែនាំរបស់អភិបាលខេត្ត
- ធានាក្នុងការទទួលនិងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវ ដល់សមាជិកក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត និងអភិបាលរងខេត្ត ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានា
- ធានារក្សាទុកដាក់ឱ្យបានត្រឹមត្រូវនិងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តនិងរដ្ឋបាលរបស់ខ្លួន
- គ្រប់គ្រងនិងប្រើប្រាស់ត្រារដ្ឋបាលខេត្តឱ្យបានត្រឹមត្រូវតាមការកំណត់ដូចមានចែងក្នុងមាត្រា៩៣នៃអនុក្រឹត្យនេះ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត អភិបាលខេត្ត ឬដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ។

**មាត្រា ៤៦.-**

នាយករដ្ឋបាលសាលាខេត្ត មានសិទ្ធិចូលរួម និងបញ្ចេញយោបល់គ្រប់កិច្ចប្រជុំក្រុមប្រឹក្សាខេត្ត កិច្ចប្រជុំគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាខេត្ត និងកិច្ចប្រជុំគណៈអភិបាលខេត្ត ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលសាលាខេត្តជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយរបស់ក្រុមប្រឹក្សាខេត្ត ។

**មាត្រា ៤៧.-**

ក្នុងការចូលរួមក្នុងកិច្ចប្រជុំដូចមានចែងក្នុងមាត្រា៤៦នៃអនុក្រឹត្យនេះ និងការអនុវត្តការងារប្រចាំថ្ងៃ នាយករដ្ឋបាលសាលាខេត្ត អាចផ្តល់យោបល់ដល់ក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលរបស់ខ្លួន អំពីបញ្ហាច្បាប់ និងបច្ចេកទេស ដើម្បីធានាថាសេចក្តីសម្រេច និងសកម្មភាពនានារបស់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងអភិបាលខេត្ត មានលក្ខណៈសមស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបទដ្ឋានជាតិសម្រាប់សុវត្ថិភាពនិងគុណភាពដែលបានកំណត់ ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងសាលាខេត្ត ។

**មាត្រា ៤៨.-**

ដោយមានការដឹកនាំ ណែនាំពីគណៈអភិបាលខេត្ត និងអភិបាលខេត្ត នាយករដ្ឋបាលសាលាខេត្តត្រូវធានាឱ្យនាយកទីចាត់ការ មន្ត្រី បុគ្គលិកទាំងអស់អនុវត្តការងារឱ្យបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនានា និងការសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន ។

**មាត្រា ៤៩.-**

គណៈអភិបាលខេត្ត ឬអភិបាលខេត្ត អាចធ្វើប្រតិភូកម្មដល់នាយករដ្ឋបាលសាលាខេត្ត ឱ្យលើកយោបល់លើកិច្ចការណាមួយដែលស្ថិតក្នុងវិសាលភាពនៃតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីគណៈអភិបាលខេត្ត ឬអភិបាលខេត្តពិនិត្យសម្រេចតាមការចាំបាច់។

## ផ្នែកទី៥

## សាលាខេត្តនិងទីចាត់ការចំណុះនានា

**មាត្រា ៥០.-**

សាលាខេត្ត គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្ត។

សាលាខេត្ត ត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការរបស់រដ្ឋ។

ក្នុងអំឡុងពេលម៉ោងធ្វើការងារ ប្រជាពលរដ្ឋមានសិទ្ធិ :

- ធ្វើទំនាក់ទំនងនិងធ្វើការងារជាមួយក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្ត
- ទទួលព័ត៌មានអំពីសំណើនិងការងារនានាពីរដ្ឋបាលខេត្ត
- ចូលរួមយោបល់ឬសំណូមពរលើបញ្ហាណាមួយ។

នៅចន្លោះម៉ោងធ្វើការឬថ្ងៃឈប់សម្រាកជាផ្លូវការ ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តត្រូវធានាឱ្យមានមន្ត្រី បុគ្គលិកនៃរដ្ឋបាលរបស់ខ្លួនក្នុងចំនួនសមស្របប្រចាំការ ដើម្បីទទួល ឬដោះស្រាយសំណូមពរបន្ទាន់ពិសេសនានា។

**មាត្រា ៥១.-**

រដ្ឋបាលខេត្ត ត្រូវធ្វើជាម្ចាស់និងទទួលខុសត្រូវចាត់ចែងលើរាល់លិខិតស្នាម ឯកសារទាំងអស់ដែលបានទទួលត្រឹមត្រូវ ឱ្យបានស្របតាមច្បាប់ជាធរមាន។

**មាត្រា ៥២.-**

រដ្ឋបាលខេត្តជាម្ចាស់និងទទួលខុសត្រូវលើរាល់លិខិតស្នាម ឯកសារនានាដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាខេត្ត ឬក្នុងនាមក្រុមប្រឹក្សាខេត្ត និងដោយគណៈអភិបាលខេត្តក្នុងនាមរដ្ឋ ព្រមទាំងជាម្ចាស់លើឧបករណ៍ មធ្យោបាយនិងសម្ភារៈនានានៃរដ្ឋបាលរបស់ខ្លួន។

រដ្ឋបាលខេត្ត ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាម ឧបករណ៍ មធ្យោបាយ សម្ភារៈនានានៃរដ្ឋបាលរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមការកំណត់ មានសណ្តាប់ធ្នាប់ល្អ និងគង់វង្ស។

**មាត្រា ៥៣.-**

ត្រារដ្ឋបាលខេត្ត ត្រូវបានប្រគល់ឱ្យនាយករដ្ឋបាលសាលាខេត្ត ដើម្បីទទួលខុសត្រូវនិងគ្រប់គ្រង សម្រាប់ក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្តប្រើប្រាស់។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើការណែនាំអំពីការគ្រប់គ្រង និងប្រើប្រាស់ត្រាខាងលើនេះ។

**មាត្រា ៥៤.-**

រដ្ឋបាលខេត្ត ត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈនៅមុខសាលាខេត្ត ដែលសាធារណជនអាចពិនិត្យមើលបានដោយងាយស្រួល ។

ក្តារព័ត៌មានសាធារណៈនេះ ត្រូវបានសរសេរឬបានបិទផ្សាយសេចក្តីជូនដំណឹងជាផ្លូវការដល់សាធារណជន ។

ការសរសេរនិងការបិទផ្សាយខាងលើនេះ ត្រូវរក្សាទុកឱ្យបានយ៉ាងតិចដប់(១០)ថ្ងៃ ។

ក្រៅពីក្តារព័ត៌មានសាធារណៈនៅមុខសាលាខេត្ត ក្រុមប្រឹក្សាខេត្តត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈនៅទីសាធារណៈសមស្រប ដើម្បីបិទផ្សាយព័ត៌មានជូនសាធារណជន ។

ក្រៅពីការរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈ ក្រុមប្រឹក្សាខេត្តត្រូវស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ដើម្បីជូនដំណឹងអំពីកិច្ចការនានានៃរដ្ឋបាលរបស់ខ្លួនដល់ប្រជាពលរដ្ឋ ។

**មាត្រា ៥៥.-**

សាលាខេត្ត ត្រូវមានទីចាត់ការចំណុះចាំបាច់ដូចខាងក្រោម :

- ទីចាត់ការរដ្ឋបាល
- ទីចាត់ការផែនការនិងវិនិយោគ
- ទីចាត់ការហិរញ្ញវត្ថុ
- ទីចាត់ការគ្រប់គ្រងធនធានមនុស្ស
- ទីចាត់ការអន្តរវិស័យ ។

**មាត្រា ៥៦.-**

ទីចាត់ការនីមួយៗ ត្រូវស្ថិតក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់នាយកទីចាត់ការ ។

នាយកទីចាត់ការនីមួយៗ ត្រូវទទួលខុសត្រូវនិងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលាខេត្ត ។

**មាត្រា ៥៧.-**

ទីចាត់ការនីមួយៗនៃសាលាខេត្តដូចមានចែងក្នុងមាត្រា៥៥នៃអនុក្រឹត្យនេះ ត្រូវមាននាយកទីចាត់ការមួយ(០១)រូប និងនាយករងទីចាត់ការយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ ។

ទីចាត់ការនីមួយៗនៃសាលាខេត្ត ត្រូវមានការិយាល័យចំណុះមួយចំនួន ។

ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធានការិយាល័យមួយ(០១)រូប និងមានអនុប្រធានការិយាល័យយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ ។

ល័ក្ខខ័ណ្ឌនៃការតែងតាំងនាយកទីចាត់ការ នាយករងទីចាត់ការ ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រី បុគ្គលិកនៃទីចាត់ការនីមួយៗ ត្រូវផ្អែកតាមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ៥៨.-**

ទីចាត់ការទីមួយៗដូចមានចែងក្នុងមាត្រា៥៥នៃអនុក្រឹត្យនេះ ជាសេនាធិការរបស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ក្នុងការសហការជាមួយស្ថាប័ន អង្គភាពជំនាញតាមវិស័យ ទាក់ទងនឹងកិច្ចការសំខាន់ៗដូចខាងក្រោម :

**ក). ទីចាត់ការរដ្ឋបាល :**

- ការងារលិខិតស្នាម តម្កល់ឯកសារ និងការធ្វើនីត្យានុកូលកម្មលើឯកសារផ្សេងៗ
- ការគ្រប់គ្រងនិងថែរក្សាត្រារបស់រដ្ឋបាលខេត្ត
- ទំនាក់ទំនងជាមួយសាធារណជនដែលមកទាក់ទងនៅសាលាខេត្ត ការងារព័ត៌មាន ការរៀបចំរបាយការណ៍ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស ឆ្នាំ និងការបិទផ្សាយព័ត៌មានលើក្តារព័ត៌មានសាធារណៈ
- ការគ្រប់គ្រងស្ថិតិ ទិន្នន័យប្រជាពលរដ្ឋ និងការងារអត្រានុកូលដ្ឋាន
- ការងារពិធីការនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ការគាំទ្រការងារលេខាធិការដ្ឋានដល់ក្រុមប្រឹក្សាខេត្ត។

**ខ). ទីចាត់ការផែនការ និងវិនិយោគ :**

- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ
- ការគ្រប់គ្រងកិច្ចសន្យា និង/ឬអនុវត្តគម្រោងនានា ដែលចុះកិច្ចសន្យាជាមួយរដ្ឋបាលខេត្ត
- គាំទ្រធនធានផ្នែករដ្ឋបាលនិងសមត្ថភាពផ្នែករដ្ឋបាលដល់ក្រុង ស្រុក ឃុំ និងសង្កាត់
- កិច្ចសហការសិក្សាគម្រោង រៀបចំប្លង់ ប៉ាន់ស្មានតម្លៃ និងរៀបចំសំណើគម្រោងសម្រាប់បញ្ចូលក្នុងផែនការអភិវឌ្ឍខេត្ត និងគាំទ្របច្ចេកទេសដល់ក្រុង ស្រុក ឃុំ និងសង្កាត់លើការងារទាំងនេះ
- ការធ្វើសហប្រតិបត្តិការនិងការគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ក្រុង ស្រុក ឃុំ និងសង្កាត់ ព្រមទាំងការគាំទ្រសមត្ថភាពចាំបាច់ដល់ក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងការអនុវត្តគម្រោងនានា
- ការពិនិត្យនិងផ្តល់យោបល់លើសំណើវិនិយោគ និងគម្រោងអភិវឌ្ឍរបស់ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ក្នុងដែនសមត្ថកិច្ចរបស់ខេត្ត
- ការចងក្រងនិងធ្វើបច្ចុប្បន្នភាពទិន្នន័យពាក់ព័ន្ធគម្រោងអភិវឌ្ឍនានារបស់ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់។

**គ). ទីចាត់ការហិរញ្ញវត្ថុ :**

- ការរៀបចំសេចក្តីព្រាងថវិកាប្រចាំឆ្នាំនិងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- ការងារហិរញ្ញវត្ថុ ថវិកា និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខេត្ត
- ការរៀបចំឱ្យមានការធ្វើសវនកម្មឱ្យបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ

- ការគ្រប់គ្រងចំណូល ចំណាយ និងគណនេយ្យ
- ការគាំទ្រដល់ការងារហិរញ្ញវត្ថុក្រុង ស្រុក ឃុំ និងសង្កាត់
- ការងារសារពើភណ្ឌ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលខេត្ត
- ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាលាខេត្ត
- ការងារលទ្ធកម្ម ។

**ឃ). ទីចាត់ការគ្រប់គ្រងធនធានមនុស្ស :**

- ការងារក្របខ័ណ្ឌ និងការគ្រប់គ្រងមន្ត្រី បុគ្គលិកដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- ផែនការប្រើប្រាស់ និងជ្រើសរើសទីប្រឹក្សាបច្ចេកទេស បុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត
- ការផ្តល់គ្រឿងឥស្សរិយយស មេដាយ បណ្ណសរសើរដល់មន្ត្រី បុគ្គលិក និងសប្បុរសជននានា
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាព និងបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិក
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិក
- ការបង្កើត ការកែសម្រួល ឬការរំសាយទីចាត់ការ ឬការិយាល័យចំណុះសាលាខេត្ត
- ការកំណត់នីតិវិធីរដ្ឋបាលសម្រាប់ទីចាត់ការ និងល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិក
- ការផ្សព្វផ្សាយ និងតាមដានការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីរដ្ឋបាលដែលពាក់ព័ន្ធនឹងការងារបុគ្គលិក តួនាទី ភារកិច្ច ល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិក ។

**ង). ទីចាត់ការអន្តរវិស័យ :**

- កិច្ចសហការសម្របសម្រួលក្នុងការពិនិត្យមើលឡើងវិញនូវមុខងារ ធនធាន និងការទទួលខុសត្រូវដើម្បីផ្ទេរមកឱ្យរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់នៅក្នុងខេត្ត
- កិច្ចសហការសម្របសម្រួលក្នុងការប្រគល់និងការធ្វើប្រតិភូកម្មមុខងារនិងធនធានដល់ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់នៅក្នុងខេត្ត
- កិច្ចសហការសម្របសម្រួលអនុវត្តមុខងារ ភារកិច្ចនានាដែលទាក់ទងការងារសេដ្ឋកិច្ច ការលើកកម្ពស់សុខុមាលភាពសង្គម ការងារពាក់ព័ន្ធដីធ្លី ផែនការរៀបចំដែនដីខេត្ត ការងារបរិស្ថាន ធនធានធម្មជាតិ ឧទ្យាន ការគ្រប់គ្រងកាកសំណល់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូន ព្រមទាំងការផ្តល់សេវាសាធារណៈនានា លើកលែងតែមុខងារ ភារកិច្ចទាំងឡាយណាដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ទីចាត់ការនានានៃសាលាខេត្ត ដែលកំណត់ក្នុងអនុក្រឹត្យនេះ
- ការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតាមដាន ត្រួតពិនិត្យ វាយតម្លៃការយល់ដឹងអំពីច្បាប់ និងការអនុវត្តច្បាប់
- ការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស ការគោរពសិទ្ធិមនុស្ស និងយេនឌ័រ
- ការរំលោភអំណាចក្នុងដែនសមត្ថកិច្ចរបស់ខេត្ត និងការដោះស្រាយវិវាទនៅមូលដ្ឋាន
- ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការលើកកម្ពស់សុវត្ថិភាពសង្គម

– ការអនុវត្តមុខងារ ភារកិច្ចថ្មីដែលបានផ្ទេរមកឱ្យរដ្ឋបាលខេត្ត លើកលែងតែមុខងារ ភារកិច្ចដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ទីចាត់ការនានានៃសាលាខេត្ត ដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ។

ក្រៅពីភារកិច្ចដូចមានចែងខាងលើនេះ ទីចាត់ការនីមួយៗអាចបំពេញកិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីគណៈអភិបាលខេត្ត ។

ទីចាត់ការនីមួយៗ ត្រូវបំពេញកិច្ចការដោយផ្អែកតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនានាជាធរមាន ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីភារកិច្ច និងរបៀបរបបការងាររបស់ទីចាត់ការនានានៃសាលាខេត្ត ។

**មាត្រា ៥៩.-**

ផ្អែកតាមតួនាទី ភារកិច្ចរបស់ទីចាត់ការនានានៃសាលាខេត្ត ដូចមានចែងក្នុងមាត្រា៥៨នៃអនុក្រឹត្យនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រោយពីមានការឯកភាពពី គ.ជ.អ.ប. ត្រូវចេញប្រកាសបង្កើតការិយាល័យចំណុះទីចាត់ការនីមួយៗនៃសាលាខេត្ត និងកំណត់អំពីតួនាទី ភារកិច្ច របៀបរបបការងាររបស់ការិយាល័យនីមួយៗនោះ ។

**មាត្រា ៦០.-**

ក្រៅពីទីចាត់ការនិងការិយាល័យដូចមានចែងក្នុងមាត្រា៥៨និងមាត្រា៥៩នៃអនុក្រឹត្យនេះ គណៈអភិបាលខេត្តអាចស្នើទៅក្រុមប្រឹក្សាខេត្ត ដើម្បីបង្កើតទីចាត់ការឬការិយាល័យបន្ថែមទៀតតាមការចាំបាច់ ។

ទីចាត់ការឬការិយាល័យដែលបង្កើតបន្ថែមខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយទីចាត់ការឬការិយាល័យដែលតម្រូវឱ្យបង្កើតឡើងដោយអនុក្រឹត្យនេះឡើយ ។

ផ្អែកតាមការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលខេត្តត្រូវលើកសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ សម្រេច និង/ឬរៀបចំបែបបទក្នុងការបង្កើត ឬរំសាយ ឬកែសម្រួលទីចាត់ការ ឬការិយាល័យខាងលើនេះ ។

## ជំពូកទី៣
## រដ្ឋបាលក្រុង
### ផ្នែកទី១
### ក្រុមប្រឹក្សាក្រុង

**មាត្រា ៦១.-**

ក្រុមប្រឹក្សាក្រុងនីមួយៗដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈជាអ្នកការពារនិងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ៦២.-**

ក្រុមប្រឹក្សាក្រុងនីមួយៗ ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ។

**មាត្រា ៦៣.-**

ក្រុមប្រឹក្សាក្រុង មានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្ម ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៦៤.-**

ក្រុមប្រឹក្សាក្រុងនីមួយៗ ត្រូវសម្របសម្រួលនិងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាសង្កាត់ និងសហគមន៍ប្រជាពលរដ្ឋក្នុងក្រុងរបស់ខ្លួន ដើម្បីកំណត់អំពីតម្រូវការជាអាទិភាពក្នុងការផ្តល់សេវានិងការអភិវឌ្ឍ និងសំណើឬសំណូមពរនានារបស់ប្រជាពលរដ្ឋក្នុងក្រុងរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ (០៥) ឆ្នាំ និងកម្មវិធីវិនិយោគបី (០៣) ឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុង ។

**មាត្រា ៦៥.-**

ក្នុងអំឡុងខែមិថុនានៃឆ្នាំនីមួយៗ ក្រុមប្រឹក្សាក្រុងត្រូវរៀបចំឱ្យមានវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ នៅតាមសង្កាត់នានាក្នុងក្រុងរបស់ខ្លួន ។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ ត្រូវចូលរួមដោយសមាជិកក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង សមាជិកក្រុមប្រឹក្សាសង្កាត់ទាំងអស់នៅក្នុងក្រុង តំណាងសហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធដទៃទៀត តាមការសម្រេចពីក្រុមប្រឹក្សាក្រុង ។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ មានគោលបំណងដើម្បីឱ្យក្រុមប្រឹក្សាក្រុងជម្រាបជូនក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធនានាអំពីសកម្មភាពរបស់ក្រុមប្រឹក្សាក្រុង ក្នុងចន្លោះពេលពីវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់មួយទៅវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់មួយ ការឆ្លើយតបចំពោះសំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ការពិភាក្សា ស្រាយបំភ្លឺអំពីបញ្ហានានាដល់អ្នកចូលរួម និងការប្រមូលមតិយោបល់នានាពីអ្នកចូលរួម ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន ។

ប្រធានក្រុមប្រឹក្សាក្រុងនីមួយៗ ជាអ្នកសម្របសម្រួលក្នុងវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ ។

គណៈអភិបាលក្រុង ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើការបូកសរុប វាយតម្លៃអំពីលទ្ធផលនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះ ក្នុងរយៈពេលយ៉ាងយូរដប់ប្រាំ (១៥) ថ្ងៃបន្ទាប់ ។ ក្នុងការបូកសរុបវាយតម្លៃនេះ ត្រូវលើកឡើងនូវគោលការណ៍ វិធានការ ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន ក្នុងក្របខ័ណ្ឌតួនាទី សមត្ថកិច្ចរបស់រដ្ឋបាលក្រុង ។ ចំពោះកិច្ចការទាំងឡាយណាដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀត រដ្ឋបាលក្រុងត្រូវពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាដែលពាក់ព័ន្ធទាំងនោះ ដើម្បីលើកឡើងអំពីគោលការណ៍ វិធានការដោះស្រាយតាមសមត្ថកិច្ចរៀងៗខ្លួន ។ គណៈអភិបាលក្រុងត្រូវបញ្ជូនរបាយការណ៍ខាងលើនេះ មួយច្បាប់មករដ្ឋបាលខេត្ត ដើម្បីពិនិត្យនិងដោះស្រាយកិច្ចការទាំងឡាយណាដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរដ្ឋបាលខេត្ត ។ ចំពោះកិច្ចការដែលពាក់ព័ន្ធសមត្ថកិច្ចដោះស្រាយរបស់ថ្នាក់ជាតិ គណៈអភិបាលខេត្តត្រូវធ្វើការប្រមូលផ្តុំពីគ្រប់ក្រុង ដើម្បីធ្វើ

សេចក្តីរាយការណ៍មកក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សារបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំបន្ថែមទៀតអំពីការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់តាមការចាំបាច់ ។

**មាត្រា ៦៦.-**

ក្រុមប្រឹក្សាក្រុង ត្រូវបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈដីកា និងសេចក្តីសម្រេចនានាក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ ។

**មាត្រា ៦៧.-**

កិច្ចប្រជុំក្រុមប្រឹក្សាក្រុង អាចយកជាការបានលុះត្រាតែកិច្ចប្រជុំនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន ។

សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាក្រុងរបស់ខ្លួន មិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវណែនាំ ឬអាចធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាក្រុងកែតម្រូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះឡើងវិញ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ ។

**មាត្រា ៦៨.-**

ក្រុមប្រឹក្សាក្រុង អាចចាត់ឱ្យគណៈកម្មាធិការណាមួយឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការឬអនុគណៈកម្មាធិការឬក្រុមការងារនានា ដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់ ។ ក្នុងករណីនេះ គណៈអភិបាលក្រុងត្រូវដឹកនាំនាយករដ្ឋបាលសាលាក្រុងនិងការិយាល័យពាក់ព័ន្ធនៃសាលាក្រុង ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ ។

គណៈអភិបាលក្រុងដោយមាននាយករដ្ឋបាលសាលាក្រុងជាជំនួយការ ត្រូវធ្វើការសម្របសម្រួល ណែនាំដល់ការិយាល័យនានានៃសាលាក្រុង រៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចដាក់ជូនក្រុមប្រឹក្សាពិនិត្យពិភាក្សា និងអនុម័ត ។

គណៈអភិបាលក្រុង ត្រូវណែនាំនាយករដ្ឋបាលសាលាក្រុងឱ្យរៀបចំដីកាឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួចឱ្យស្របតាមទម្រង់ដែលកំណត់ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាក្រុងចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន និងត្រូវប្រថាប់ត្រារដ្ឋបាលក្រុង ។

ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេចទាំងឡាយណាដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះ ព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព ។

**មាត្រា ៦៩.-**

ប្រធានក្រុមប្រឹក្សាក្រុងក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលក្រុង លើ :

- ដីកាឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាក្រុង
- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាក្រុង
- សំណើដកហូតអភិបាលក្រុងឬអភិបាលរងក្រុងចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាក្រុង តាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៩២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាក្រុង
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្រុងរយៈពេលដប់ពីរ(១២)ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាក្រុង
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

គណៈអភិបាលក្រុង ត្រូវជួយក្រុមប្រឹក្សារបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែឯកសារក្នុងចំណុចគំនូសទី៤។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំអំពីទម្រង់នៃឯកសារខាងលើតាមការចាំបាច់។

**មាត្រា ៧០.-**

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាក្រុងត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ ដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលក្រុងនិងវិធានការ បែបបទ នីតិវិធីចាត់ចែងការងារតាមការចាំបាច់ ដែលទាក់ទងទៅនឹង :

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាក្រុង
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន មន្ទីរ ឬការិយាល័យ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំនិងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលក្រុង
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាក្រុង

- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាក្រុង ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនិងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាក្រុង
- ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង រួមទាំងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់ និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ៧១.-**

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាក្រុងត្រូវធ្វើការសម្រេចរៀងរាល់កិច្ចប្រជុំ ដូចមានចែងក្នុងមាត្រា៧០នៃអនុក្រឹត្យនេះ ក្រុមប្រឹក្សាក្រុងអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ខ្លួន នូវកិច្ចការផ្សេងៗទៀត រួមមាន :

- ការកោះអញ្ជើញអភិបាលក្រុង ឬអភិបាលរងក្រុង ឬគណៈអភិបាលក្រុងទាំងមូល ឬបុគ្គលដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ឬហេតុការណ៍ណាមួយដែលកើតមានក្នុងក្រុង ឬការដោះស្រាយបញ្ហាបន្ទាន់និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលក្រុង
- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាក្រុងយល់ឃើញថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងការសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវឬការធ្វើអង្កេតនេះ ព្រមទាំងណែនាំដល់គណៈអភិបាលក្រុងអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនោះ
- ការធ្វើប្រតិភូកម្មមុខងារ ភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់
- ការពិនិត្យស្រាវជ្រាវនិងការធ្វើសេចក្ដីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សាក្រុង ឬសមាជិកក្រុមប្រឹក្សាក្រុង ឬគណៈអភិបាលក្រុង ឬអភិបាលក្រុង ឬអភិបាលរងក្រុង ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាក្រុងតាមគោលការណ៍ដូចមានចែងក្នុងផ្នែកទី៥ ជំពូកទី២នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ការពិនិត្យនិងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់និងនីតិវិធីជាធរមាន
- ការពិនិត្យនិងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ពិនិត្យនិងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលក្រុង
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុងយល់ឃើញថាមានការចាំបាច់ ។

**មាត្រា ៧២.-**

ក្រុមប្រឹក្សាក្រុង ត្រូវប្រើប្រាស់អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ។

ក្នុងករណី កិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត មិនបានចែងអំពីបែបបទនិងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលក្រុងធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទនិងនីតិវិធីសមស្រប ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនេះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឬរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធនានា ធ្វើការបញ្ជាក់នូវបែបបទ នីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនោះ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ ។

ក្នុងករណី កិច្ចការណាមួយដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទនិងនីតិវិធីដែរ ប៉ុន្តែបែបបទនិងនីតិវិធីនោះចែងមិនច្បាស់លាស់ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាក្រុងមិនអាចអនុវត្តបាន ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលក្រុងធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវផ្អែកតាមយន្តការនៃ គ.ជ.អ.ប. ធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យនិងដោះស្រាយករណីនេះ ។

**មាត្រា ៧៣.-**

អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាក្រុងបានសម្រេចរួចហើយ គណៈអភិបាលក្រុងត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

គណៈអភិបាលក្រុង ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សា ដូចមានចែងក្នុងមាត្រា៧០និងមាត្រា៧១នៃអនុក្រឹត្យនេះ ។

ក្រុមប្រឹក្សាក្រុង ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលក្រុង ដើម្បីធានាថា គណៈអភិបាលក្រុងអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាក្រុង ។

គ.ជ.អ.ប. ត្រូវដាក់ចេញនូវគោលការណ៍ណែនាំ គាំទ្រដល់ក្រុមប្រឹក្សាក្រុងក្នុងការរៀបចំនូវប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាក្រុង ។

**មាត្រា ៧៤.-**

ដីកាឬសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាសង្កាត់ ត្រូវស្ថិតក្រោមការពិនិត្យនីត្យានុកូលភាពរបស់ក្រុមប្រឹក្សាក្រុង ។

ក្រុមប្រឹក្សាក្រុង ត្រូវធ្វើប្រតិភូកម្មដល់គណៈអភិបាលក្រុង ដើម្បីពិនិត្យនីត្យានុកូលភាពនេះ ។

ក្នុងករណីពិនិត្យឃើញថាដីកាឬសេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សាសង្កាត់ មិនស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលការណ៍ដែលសម្រេចដោយក្រុមប្រឹក្សាក្រុង ឬការសម្រេចឬការងារណាមួយដែលក្រុមប្រឹក្សាសង្កាត់បានធ្វើការសម្រេចហួសពីដែនសមត្ថកិច្ចដែលក្រុមប្រឹក្សាក្រុងបានធ្វើប្រតិភូកម្ម គណៈអភិបាលក្រុង ត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរជូនដល់ក្រុមប្រឹក្សាសង្កាត់ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីសេចក្តីសម្រេចជាក់លាក់ និងកិច្ចការជាក់លាក់ណាមួយឬមួយចំនួន ដែលក្រុមប្រឹក្សាសង្កាត់ធ្វើការសម្រេចឬធ្វើសកម្មភាពមិនសមស្រប ។ ផ្អែកតាមការណែនាំនេះ ក្រុមប្រឹក្សាសង្កាត់ត្រូវកែតម្រូវសេចក្តីសម្រេចឬសកម្មភាពរបស់ខ្លួនឱ្យបានសមស្របឡើងវិញក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ បន្ទាប់ពីបានទទួលការណែនាំជាលាយលក្ខណ៍អក្សរពីគណៈអភិបាលក្រុង ។

ក្នុងករណីក្រុមប្រឹក្សាសង្កាត់មិនអនុវត្តតាមការណែនាំខាងលើនេះ ក្រុមប្រឹក្សាក្រុងត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាខេត្ត ដើម្បីសម្របសម្រួលអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ ។

## ផ្នែកទី២
## គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្រុង

**មាត្រា ៧៥.-**

ក្រុមប្រឹក្សាក្រុង ត្រូវមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមាន :

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ
- គណៈកម្មាធិការលទ្ធកម្ម ។

កិច្ចដំណើរការនៃគណៈកម្មាធិការទាំងបីខាងលើ ត្រូវផ្អែកតាមលិខិតបទដ្ឋានស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទាំងនេះ ។

**មាត្រា ៧៦.-**

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាក្រុងអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទាំងបីដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឡើយ ។

ក្រុមប្រឹក្សាក្រុងអាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗទៀតតាមការស្នើសុំរបស់គណៈកម្មាធិការនានាឬគណៈអភិបាលក្រុង ។

អនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ ត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការឬគណៈអភិបាលក្រុង ។

**មាត្រា ៧៧.-**

ក្រុមប្រឹក្សាក្រុង អាចតែងតាំងសមាជិកក្រុមប្រឹក្សាក្រុង អភិបាលក្រុង អភិបាលរងក្រុង តំណាងក្រុមប្រឹក្សាសង្កាត់ បុគ្គលិករបស់ក្រុមប្រឹក្សាក្រុង តំណាងសហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់ សម្រាប់ជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង ។

ក្រុមប្រឹក្សាក្រុង ត្រូវសម្រេចពីចំនួនសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗការតែងតាំងប្រធាន អនុប្រធាន និងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការឬក្រុមការងារនានាដែលខ្លួនបានបង្កើតឡើង ។

គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ត្រូវមានតំណាងស្ត្រីសមស្រប រួមទាំងតំណែងប្រធាន ឬអនុប្រធានគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារផង ។

ក្រុមប្រឹក្សាក្រុង អាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង តាមការចាំបាច់ឬតាមសំណើរបស់គណៈកម្មាធិការឬគណៈអភិបាលក្រុង ។

**មាត្រា ៧៨.-**

គណៈអភិបាលក្រុង អាចស្នើសុំក្រុមប្រឹក្សាក្រុងដើម្បីឱ្យគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយដែលក្រុមប្រឹក្សាក្រុងបានបង្កើតឡើង រួមទាំងគណៈកម្មាធិការទាំងបី(០៣)ដែលតម្រូវដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយឬមួយចំនួនដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈអភិបាលក្រុង ។

**មាត្រា ៧៩.-**

ក្រុមប្រឹក្សាក្រុង ត្រូវទទួលខុសត្រូវរាល់ការសម្រេចនិងសកម្មភាពរបស់គណៈកម្មាធិការនានានិងទទួលខុសត្រូវចំពោះផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនេះ ។

**មាត្រា ៨០.-**

ក្រុមប្រឹក្សាក្រុង ត្រូវណែនាំឱ្យគណៈអភិបាលក្រុងផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់និងបច្ចេកទេស ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការទាំងបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាក្រុងបានបង្កើតឡើង ។

**មាត្រា ៨១.-**

គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមតម្រូវការចាំបាច់នានា ។

សេចក្តីរាយការណ៍ខាងលើនេះ ត្រូវចម្លងជូនគណៈអភិបាលក្រុង ដើម្បីធ្វើការបូកសរុបនិងរាយការណ៍ជូនក្រុមប្រឹក្សាក្រុង ។

ក្រុមប្រឹក្សាក្រុង អាចតម្រូវឱ្យគណៈកម្មាធិការណាមួយរាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេសនិងបន្ទាន់ណាមួយ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាក្រុងតាមការចាំបាច់ ។

## ផ្នែកទី៣
## គណៈអភិបាលក្រុង

**មាត្រា ៨២.-**

ក្រុងនីមួយៗ ត្រូវមានគណៈអភិបាលក្រុងមួយដែលរួមមាន អភិបាលក្រុង អភិបាលរងក្រុង ដែលត្រូវបានតែងតាំងឡើងស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៨៣.-**

អភិបាលក្រុង អភិបាលរងក្រុង មិនមែនជាសមាជិកក្រុមប្រឹក្សាក្រុងឡើយ ។

**មាត្រា ៨៤.-**

គណៈអភិបាលក្រុង ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន អំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាក្រុង និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា ។

**មាត្រា ៨៥.-**

គណៈអភិបាលក្រុង មានភារកិច្ចផ្តល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សាក្រុង និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ទាំងសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ ។

**មាត្រា ៨៦.-**

គណៈអភិបាលក្រុង ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាក្រុងអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាក្រុង ដើម្បីក្រុមប្រឹក្សាក្រុងធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញទាក់ទងនឹង :

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាក្រុង និងអំពីរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ

- ការរៀបចំយុទ្ធសាស្ត្រនិងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ឬបានផ្ទេរស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការងារហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ក្រុង
- ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការកំណត់នីតិវិធីរដ្ឋបាលនិងហិរញ្ញវត្ថុសម្រាប់ការិយាល័យនិងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដាក់ជូនក្រុមប្រឹក្សាក្រុង ពិនិត្យ និងអនុម័ត មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ដែលពាក់ព័ន្ធនឹង :
  + ដីកានិងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាក្រុង និងសកម្មភាព លទ្ធផលនៃការអនុវត្ត
  + របាយការណ៍ហិរញ្ញវត្ថុ
  + ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលក្រុង និងបុគ្គលិក
  + វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង
  + វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
  + កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាក្រុងយល់ឃើញថាចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។
- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្តារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់សង្កាត់
- ការធ្វើប្រតិភូកម្មមុខងារ ភារកិច្ច និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់

– កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សាក្រុងរបស់ខ្លួន។

**មាត្រា ៨៧.–**

នៅពេលបានទទួលរបាយការណ៍ ឬព័ត៌មានអំពីការរំលោភអំណាច ដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលក្រុងត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថា មានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលក្រុងត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនក្រុមប្រឹក្សាក្រុង និងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៨៨.–**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៨៦និងមាត្រា៨៧នៃអនុក្រឹត្យនេះ និងការងារដទៃទៀតដែលខ្លួនយល់ឃើញថាចាំបាច់ អភិបាលក្រុងត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលក្រុងរបស់ខ្លួន ដោយឈរលើគោលការណ៍ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេចនិងគោលការណ៍ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន។

អភិបាលក្រុង ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាក្រុងអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរបស់ខ្លួន។

អភិបាលរងក្រុង ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលក្រុងលើភារកិច្ចនានាដែលបានប្រគល់ជូន ហើយត្រូវរួមជាមួយអភិបាលក្រុងទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន។

ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលក្រុងត្រូវជួបប្រជុំគ្នាប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ។

ក្រៅពីការប្រជុំប្រចាំអឌ្ឍមាសនិងការប្រជុំប្រចាំខែខាងលើ គណៈអភិបាលក្រុងអាចកោះប្រជុំតាមការចាំបាច់។

រៀងរាល់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។

**មាត្រា ៨៩.–**

គណៈអភិបាលក្រុង ឬអភិបាលក្រុង ឬអភិបាលរងក្រុង ដែលបានសម្រេច និង/ឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាក្រុង ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។

គណៈអភិបាលក្រុង ឬអភិបាលក្រុង ឬអភិបាលរងក្រុង ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពខាងលើនេះ។

**មាត្រា ៩០.-**

គណៈអភិបាលក្រុង ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលក្រុងនិងអភិបាលរងក្រុង ហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីការបែងចែកភារកិច្ចដល់អភិបាលក្រុង អភិបាលរងក្រុង និងរបៀបរបបអនុវត្តភារកិច្ចដែលបានបែងចែកនោះ។

**មាត្រា ៩១.-**

អភិបាលក្រុង ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សារបស់ខ្លួន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាក្រុងចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនដូចមានចែងក្នុងមាត្រា៦៩នៃអនុក្រឹត្យនេះ។

អភិបាលក្រុង អាចប្រគល់សិទ្ធិដល់អភិបាលរងក្រុងក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងក្រុងនីមួយៗ។

អភិបាលក្រុង ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងក្រុង។

អភិបាលក្រុង មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងក្រុងណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់និងមិនស្របតាមបែបបទ នីតិវិធី។ ការប្រគល់និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលក្រុងត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការប្រគល់សិទ្ធិចុះហត្ថលេខានេះ។

**មាត្រា ៩២.-**

ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងក្រុង អភិបាលក្រុងមានភារកិច្ច :

- ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ឱ្យអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ
- សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលក្រុងត្រូវធ្វើការសម្របសម្រួលការិយាល័យ អង្គភាព ទីភ្នាក់ងារពាក់ព័ន្ធដើម្បីសហការគ្នាអនុវត្តកិច្ចការនោះ ដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និង តម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង អភិបាលក្រុងត្រូវសម្របសម្រួល តម្រង់ទិសការិយាល័យ អង្គភាព និង

ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ក្នុងការធ្វើសមាហរណកម្មផែនការនិងថវិការបស់ខ្លួនទៅក្នុងផែនការនិងថវិការបស់ក្រុមប្រឹក្សាក្រុង ។

- ពិនិត្យវាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានាតាមគោលការណ៍កំណត់
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាក្រុងជាមុន ក្នុងការផ្តល់យោបល់លើបេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យនិងអង្គភាពនៃក្រសួង ស្ថាប័ននានាប្រចាំនៅក្នុងក្រុងរបស់ខ្លួន ។ ក្នុងករណីមិនគាំទ្របេក្ខភាពដែលស្នើតែងតាំងខាងលើនេះ អភិបាលក្រុងត្រូវវាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់ពីហេតុផលនៃការមិនគាំទ្រនេះជូនអភិបាលខេត្ត ដើម្បីអភិបាលខេត្តធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីជាមុន មុននឹងធ្វើសេចក្តីវាយការណ៍ជូនរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ។
- ក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីដែលកើតមានក្នុងការិយាល័យ អង្គភាព និងទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងក្រុងរបស់ខ្លួន ឬ ករណីប្រធានការិយាល័យ ប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យ អង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទី ភារកិច្ចរបស់ខ្លួន អភិបាលក្រុងត្រូវវាយការណ៍ជាលាយលក្ខណ៍អក្សរនិងជាបន្ទាន់ទៅអភិបាលខេត្ត ។ អភិបាលខេត្តត្រូវណែនាំដល់មន្ទីរ អង្គភាពសាមីប្រចាំនៅខេត្ត ដើម្បីស្រាវជ្រាវអំពីបញ្ហានេះឬអាចចាត់តាំងគណៈកម្មការឬក្រុមការងារដែលមានការចូលរួមពីរដ្ឋបាលក្រុងដែលពាក់ព័ន្ធឱ្យធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ ដើម្បីធ្វើសេចក្តីវាយការណ៍ជូនរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ដោះស្រាយស្របតាមនីតិវិធី ។
- អភិបាលក្រុងមានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្ត ដើម្បីចាត់វិធានការផ្លាស់ប្តូរឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តិកម្មបាន ។

ដើម្បីធានាឱ្យអភិបាលក្រុងអនុវត្តនូវភារកិច្ចខាងលើនេះ សេចក្តីវាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ត្រូវដាក់ជូនអភិបាលក្រុងដើម្បីពិនិត្យនិងផ្តល់យោបល់ ។ ប្រសិនបើអភិបាលក្រុងឯកភាព អភិបាលក្រុងត្រូវចុះហត្ថលេខាលើរបាយការណ៍នោះរួមជាមួយប្រធានការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ ។ ចំពោះសេចក្តីវាយការណ៍ក្រៅពីនោះរបស់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ត្រូវចម្លងជូនសាលាក្រុង ។

**មាត្រា ៩៣.-**

អភិបាលក្រុងត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងក្រុង អំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារនិងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងក្រុង ។

អភិបាលក្រុង គឺជាប្រធានគណៈបញ្ជាការឯកភាពក្រុង ក្នុងការដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានានិងសង្កាត់នៅក្នុងក្រុង ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងក្រុង ។

**មាត្រា ៩៤.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៩២និងមាត្រា៩៣នៃអនុក្រឹត្យនេះ អភិបាលក្រុងត្រូវធ្វើការបែងចែកភារកិច្ចដល់អភិបាលរងក្នុងគណៈអភិបាលរបស់ខ្លួន ឱ្យជួយខ្លួនក្នុងការងារខាងលើនេះ ។

អភិបាលរងក្រុងដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខអភិបាលក្រុង ។

អភិបាលក្រុង ត្រូវកោះប្រជុំគណៈអភិបាលតាមការចាំបាច់ ដើម្បីពិគ្រោះពិភាក្សាលើបញ្ហាណាមួយដែលខ្លួនយល់ឃើញថាចាំបាច់ត្រូវធ្វើការពិភាក្សាក្នុងគណៈអភិបាលក្រុង សំដៅលើកកម្ពស់ការចូលរួមអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា ។

គ្រប់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុប្រជុំ ។

**មាត្រា ៩៥.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៩២និងមាត្រា៩៣នៃអនុក្រឹត្យនេះ អភិបាលក្រុងត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា ស្របទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ។

**មាត្រា ៩៦.-**

អភិបាលក្រុងដោយមាននាយករដ្ឋបាលសាលាក្រុងជាជំនួយការ ត្រូវធ្វើសេចក្តីរាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាលនិងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះ ក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាក្រុងរបស់ខ្លួន ។

ក្នុងករណីមានបញ្ហាណាមួយ ដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលក្រុងក្នុងនាមជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារ តវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាក្រុងអាចតម្រូវឱ្យអភិបាលក្រុងធ្វើសេចក្តីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ។

ក្រុមប្រឹក្សាក្រុង អាចផ្តល់អនុសាសន៍និងការណែនាំដល់អភិបាលក្រុងអំពីការអនុវត្តតួនាទីខាងលើនេះ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាពនិងបញ្ហាប្រឈមនានារបស់មូលដ្ឋាន ។

អភិបាលក្រុង ត្រូវទទួលយកអនុសាសន៍ និងការណែនាំនានាពីក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធ្វើការណែនាំ សម្របសម្រួល និងតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ក្នុងការឆ្លើយតបតម្រូវការទាំងនោះ ហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនវិញ ។

**មាត្រា ៩៧.-**

ក្នុងករណីអភិបាលក្រុងអវត្តមាន អភិបាលក្រុងត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងក្រុងមួយរូប

ឱ្យទទួលជាអភិបាលក្រុងស្តីទី ។

ប្រសិនបើអភិបាលក្រុងអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងក្រុងដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃប្រកាសតែងតាំងអភិបាលរងនៃគណៈអភិបាលក្រុង ត្រូវធ្វើជាអភិបាលក្រុងស្តីទី ។

ក្នុងករណីអភិបាលក្រុងស្តីទីអវត្តមាន អភិបាលខេត្តត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងក្រុងមួយរូបឱ្យទទួលជាអភិបាលក្រុងស្តីទី និងត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលក្រុងស្តីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលក្រុង នៅពេលដែលអភិបាលក្រុងមានវត្តមានវិញ ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំស្តីពីបែបបទនិងនីតិវិធីនៃការផ្ទេរសិទ្ធិនេះ ។

**មាត្រា ៩៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើសេចក្តីណែនាំស្តីពីការសុំច្បាប់ឈប់សម្រាករបស់អភិបាលក្រុង អភិបាលរងក្រុង និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង ។

## ផ្នែកទី៤
## នាយករដ្ឋបាលសាលាក្រុង

**មាត្រា ៩៩.-**

ក្រុមប្រឹក្សាក្រុងនិងគណៈអភិបាលក្រុង ត្រូវមាននាយករដ្ឋបាលមួយ(០១)រូប ហៅថានាយករដ្ឋបាលសាលាក្រុង ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលក្រុង ដោយយោងតាមការសម្រេចរបស់ក្រុមប្រឹក្សាក្រុង ។

នាយករដ្ឋបាលសាលាក្រុង ត្រូវមាននាយករងរដ្ឋបាលសាលាក្រុងយ៉ាងច្រើនពីរ(០២)រូប ជាជំនួយការ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលក្រុង ដោយយោងតាមការសម្រេចរបស់ក្រុមប្រឹក្សាក្រុង ។

នាយករដ្ឋបាលសាលាក្រុង ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិចាប់ពីក្រមការដើមខ្សែនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ។

នាយករងរដ្ឋបាលសាលាក្រុង ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិចាប់ពីក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ។

**មាត្រា ១០០.-**

លក្ខណសម្បត្តិនិងនីតិវិធីសម្រាប់ការតែងតាំងនាយករដ្ឋបាលសាលាក្រុង និងនាយករងរដ្ឋបាលសាលាក្រុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញប្រកាសឬសេចក្តីណែនាំអំពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់នាយករដ្ឋបាលសាលាក្រុងនិងនាយករងរដ្ឋបាលសាលាក្រុង។

**មាត្រា ១០១.-**

នាយករដ្ឋបាលសាលាក្រុង មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និងអភិបាលក្រុង ក្នុងការចាត់ចែងកិច្ចការរដ្ឋបាលនិងការធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាក្រុង។

ក្នុងតួនាទីនេះ នាយករដ្ឋបាលសាលាក្រុងត្រូវធ្វើរបាយការណ៍និងត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាលក្រុង អភិបាលក្រុង និងក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ១០២.-**

ក្នុងការអនុវត្តតួនាទីដូចមានចែងក្នុងមាត្រា១០១នៃអនុក្រឹត្យនេះ នាយករដ្ឋបាលសាលាក្រុង មានភារកិច្ច :

- រៀបចំនិងដាក់ជូនគណៈអភិបាលក្រុង ពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាក្រុង ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលក្រុង ហើយត្រូវធានាថា កិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល
- រៀបចំនិងដាក់ជូនគណៈអភិបាលក្រុងនូវវិធាននិងគោលការណ៍ក្នុងការអនុវត្តដីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាក្រុង
- ធ្វើជាសេនាធិការជូនអភិបាលក្រុងនិងប្រធានក្រុមប្រឹក្សាក្រុង ក្នុងការត្រៀមរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាក្រុង រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារ និងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាក្រុង ស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ សេចក្តីព្រាងរបៀបវារៈ ឯកសារ និងខ្លឹមសារទាំងអស់ដែលនាយករដ្ឋបាលសាលាក្រុងបានរៀបចំសម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សា ត្រូវតែដាក់ជូនគណៈអភិបាល ដើម្បីពិនិត្យនិងផ្តល់យោបល់ជាមុន លើកលែងតែមានការកំណត់ផ្សេងដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។
- ធ្វើជាសេនាធិការជូនក្រុមប្រឹក្សាក្រុងក្នុងការរៀបចំនិងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាក្រុង
- ត្រៀមរៀបចំកិច្ចការនានាសម្រាប់បម្រើឱ្យកិច្ចប្រជុំទាំងអស់របស់គណៈអភិបាលក្រុង តាមការណែនាំរបស់អភិបាលក្រុង
- ធានាក្នុងការទទួលនិងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវ ដល់សមាជិកក្រុមប្រឹក្សាក្រុង អភិបាលក្រុង និងអភិបាលរងក្រុង ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធនានា
- គ្រប់គ្រង និងប្រើប្រាស់ត្រារដ្ឋបាលក្រុងឱ្យបានត្រឹមត្រូវតាមការកំណត់ ដូចមានចែងក្នុងមាត្រា១១០ នៃអនុក្រឹត្យនេះ

- ធានារក្សាទុកដាក់ឱ្យបានត្រឹមត្រូវនិងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុងនិងរដ្ឋបាលរបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង អភិបាលក្រុង ឬដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ។

**មាត្រា ១០៣.-**

នាយករដ្ឋបាលសាលាក្រុង មានសិទ្ធិចូលរួម និងបញ្ចេញយោបល់គ្រប់កិច្ចប្រជុំក្រុមប្រឹក្សាក្រុង កិច្ចប្រជុំគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាក្រុង និងកិច្ចប្រជុំគណៈអភិបាលក្រុង ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលសាលាក្រុងជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយរបស់ក្រុមប្រឹក្សាក្រុង ។

**មាត្រា ១០៤.-**

ក្នុងការចូលរួមក្នុងកិច្ចប្រជុំដូចមានចែងក្នុងមាត្រា១០៣នៃអនុក្រឹត្យនេះ និងការអនុវត្តការងារប្រចាំថ្ងៃ នាយករដ្ឋបាលសាលាក្រុង អាចផ្តល់យោបល់ដល់ក្រុមប្រឹក្សាក្រុង គណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាក្រុង និងគណៈអភិបាលរបស់ខ្លួន អំពីបញ្ហាច្បាប់និងបច្ចេកទេស ដើម្បីធានាថាសេចក្តីសម្រេច និងសកម្មភាពនានារបស់ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និងអភិបាលក្រុង មានលក្ខណៈសមស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបទដ្ឋានជាតិសម្រាប់សុវត្ថិភាពនិងគុណភាពដែលបានកំណត់ ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងសាលាក្រុង ។

**មាត្រា ១០៥.-**

ដោយមានការដឹកនាំ ណែនាំពីគណៈអភិបាលក្រុង និងអភិបាលក្រុង នាយករដ្ឋបាលសាលាក្រុងត្រូវធានាឱ្យការិយាល័យ មន្ត្រី បុគ្គលិកទាំងអស់ អនុវត្តការងារបានត្រឹមត្រូវទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនានា និងតាមការសម្រេចរបស់ក្រុមប្រឹក្សានិងគណៈអភិបាលរបស់ខ្លួន ។

**មាត្រា ១០៦.-**

គណៈអភិបាលក្រុងនិងអភិបាលក្រុង អាចធ្វើប្រតិភូកម្មដល់នាយករដ្ឋបាលសាលាក្រុង ឱ្យលើកយោបល់លើកិច្ចការណាមួយដែលស្ថិតក្នុងវិសាលភាពនៃតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីគណៈអភិបាល ឬអភិបាលក្រុងពិនិត្យសម្រេចតាមការចាំបាច់ ។

## ផ្នែកទី៥

## សាលាក្រុងនិងការិយាល័យចំណុះនានា

**មាត្រា ១០៧.-**

សាលាក្រុង គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សាក្រុងនិងគណៈអភិបាលក្រុង ។

សាលាក្រុង ត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការរបស់រដ្ឋ ។

ក្នុងអំឡុងពេលម៉ោងធ្វើការងារ ប្រជាពលរដ្ឋមានសិទ្ធិ :

- ធ្វើទំនាក់ទំនងនិងធ្វើការងារជាមួយក្រុមប្រឹក្សាក្រុងនិងគណៈអភិបាលក្រុង
- ទទួលព័ត៌មានអំពីសំណើនិងការងារនានាពីរដ្ឋបាលក្រុង
- ចូលរួមយោបល់ឬសំណូមពរលើបញ្ហាណាមួយ ។

នៅចន្លោះម៉ោងធ្វើការឬថ្ងៃឈប់សម្រាកជាផ្លូវការ ក្រុមប្រឹក្សាក្រុងនិងគណៈអភិបាលក្រុងត្រូវចាត់ឱ្យមានមន្ត្រី បុគ្គលិកនៃរដ្ឋបាលរបស់ខ្លួន ក្នុងចំនួនសមស្របប្រចាំការ ដើម្បីទទួលឬដោះស្រាយសំណូមពរបន្ទាន់ពិសេសនានា ។

**មាត្រា ១០៨.-**

រដ្ឋបាលក្រុងនីមួយៗ ត្រូវធ្វើជាម្ចាស់និងទទួលខុសត្រូវចាត់ចែងលើរាល់លិខិតស្នាម ឯកសារទាំងអស់ដែលបានទទួលត្រឹមត្រូវ ឱ្យបានស្របតាមច្បាប់ជាធរមាន ។

**មាត្រា ១០៩.-**

រដ្ឋបាលក្រុងនីមួយៗ ជាម្ចាស់និងទទួលខុសត្រូវលើរាល់លិខិតស្នាម ឯកសារនានាដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាក្រុងឬក្នុងនាមក្រុមប្រឹក្សាក្រុងនិងដោយគណៈអភិបាលក្រុងក្នុងនាមរដ្ឋ ព្រមទាំងជាម្ចាស់លើឧបករណ៍ មធ្យោបាយនិងសម្ភារៈនានានៃរដ្ឋបាលរបស់ខ្លួន ។

រដ្ឋបាលក្រុងនីមួយៗ ត្រូវចាត់ទុកដាក់ឯកសារ លិខិតស្នាម ឧបករណ៍ មធ្យោបាយ សម្ភារៈនានានៃរដ្ឋបាលរបស់ខ្លួន ឱ្យបានត្រឹមត្រូវតាមការកំណត់ មានសណ្តាប់ធ្នាប់ល្អ និងគង់វង្ស ។

**មាត្រា ១១០.-**

ត្រារដ្ឋបាលក្រុងនីមួយៗ ត្រូវបានប្រគល់ឱ្យនាយករដ្ឋបាលសាលាក្រុងរបស់ខ្លួន ដើម្បីទទួលខុសត្រូវនិងគ្រប់គ្រងសម្រាប់ក្រុមប្រឹក្សាក្រុងនិងគណៈអភិបាលក្រុងប្រើប្រាស់ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើការណែនាំអំពីការគ្រប់គ្រងនិងប្រើប្រាស់ត្រាខាងលើនេះ ។

**មាត្រា ១១១.-**

រដ្ឋបាលក្រុងនីមួយៗ ត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈនៅមុខសាលាក្រុងរបស់ខ្លួន ដែលសាធារណជនអាចពិនិត្យមើលបានដោយងាយស្រួល ។

ក្តារព័ត៌មានសាធារណៈខាងលើនេះ ត្រូវបានសរសេរឬបានបិទផ្សាយសេចក្តីជូនដំណឹងជាផ្លូវការដល់សាធារណជន ។

ការសរសេរនិងការបិទផ្សាយខាងលើនេះ ត្រូវរក្សាទុកឱ្យបានយ៉ាងតិចដប់(១០)ថ្ងៃ ។

ក្រៅពីក្តារព័ត៌មានសាធារណៈនៅមុខសាលាក្រុង ក្រុមប្រឹក្សាក្រុងនីមួយៗត្រូវរួមជាមួយក្រុមប្រឹក្សាសង្កាត់ពិគ្រោះពិភាក្សាអំពីការរៀបចំក្តារព័ត៌មានសាធារណៈ នៅទីសាធារណៈដទៃទៀតក្នុងក្រុងរបស់ខ្លួន ដើម្បីបិទផ្សាយព័ត៌មានរួមគ្នារវាងក្រុងនិងសង្កាត់នៅក្នុងក្រុង ។

ក្រៅពីការរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈ ក្រុមប្រឹក្សាក្រុងនីមួយៗត្រូវស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ដើម្បីជូនដំណឹងអំពីកិច្ចការនានានៃរដ្ឋបាលរបស់ខ្លួនដល់ប្រជាពលរដ្ឋ ។

**មាត្រា ១១២.-**

សាលាក្រុងនីមួយៗ ត្រូវមានការិយាល័យចំណុះមួយចំនួន។

ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធានការិយាល័យមួយ(០១)រូប អមដោយអនុប្រធានការិយាល័យមួយ(០១)រូបជាជំនួយការ ដែលត្រូវតែងតាំងឡើងតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រធានការិយាល័យនីមួយៗ ត្រូវទទួលខុសត្រូវនិងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលាក្រុង។

ការិយាល័យខាងលើនេះ ជាសេនាធិការរបស់ក្រុមប្រឹក្សាក្រុងនិងគណៈអភិបាលក្រុង ក្នុងកិច្ចសហការជាមួយស្ថាប័ន អង្គភាពជំនាញតាមវិស័យ លើកិច្ចការសំខាន់ៗដូចខាងក្រោម :

- ការងាររដ្ឋបាលលិខិតស្នាម
- ការងារអគ្រានុកូលដ្ឋាន
- ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស
- ការអនុវត្តគម្រោង កម្មវិធីអភិវឌ្ឍ ការសម្របសម្រួលកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងការផ្តល់សេវារវាងសង្កាត់នានាក្នុងក្រុង
- ការងារហិរញ្ញវត្ថុ ថវិកា និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុង
- ការងារដីធ្លី សំណង់ និងរៀបចំក្រុង
- ការងារសណ្តាប់ធ្នាប់សាធារណៈ កិច្ចការច្បាប់ សិទ្ធិមនុស្ស និងយេនឌ័រ
- ការអនុវត្តមុខងារ ភារកិច្ចនានាដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្ម
- កិច្ចការដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

ផ្អែកលើតួនាទីខាងលើនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការសម្រេចរបស់ គ.ជ.អ.ប.ត្រូវចេញប្រកាសស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យនានាចំណុះសាលាក្រុង រួមទាំងល័ក្ខខ័ណ្ឌនៃការរៀបចំមន្ត្រី បុគ្គលិកនៃការិយាល័យទាំងនោះ។

## ជំពូកទី៤

## រដ្ឋបាលស្រុក

## ផ្នែកទី១

## ក្រុមប្រឹក្សាស្រុក

**មាត្រា ១១៣.-**

ក្រុមប្រឹក្សាស្រុកនីមួយៗដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ

ជាអ្នកការពារនិងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ១១៤.-**

ក្រុមប្រឹក្សាស្រុកនីមួយៗ ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**មាត្រា ១១៥.-**

ក្រុមប្រឹក្សាស្រុកត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងស្រុក។

ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្រុមប្រឹក្សាស្រុកត្រូវ :

- ជួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក ឱ្យបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- រួមជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក ដើម្បីជំរុញឱ្យមានការចូលរួមពីសាធារណជន ក្នុងដំណើរការអភិបាលកិច្ចនៅក្នុងស្រុក និងឃុំ សង្កាត់ក្នុងស្រុក
- ស្វែងយល់និងឆ្លើយតបចំពោះតម្រូវការក្នុងស្រុករបស់ខ្លួន និងចំពោះសំណើរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក។

**មាត្រា ១១៦.-**

ដើម្បីលើកកម្ពស់គណនេយ្យភាពរបស់ក្រុមប្រឹក្សាស្រុកចំពោះប្រជាពលរដ្ឋរបស់ខ្លួន ក្នុងការប្រើប្រាស់អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាស្រុកត្រូវរៀបចំឱ្យមានយន្តការពិគ្រោះ ពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក សំដៅធានាឱ្យបានថា ជម្រើស សេចក្តីសម្រេច និងសកម្មភាពរបស់ក្រុមប្រឹក្សាស្រុកមានការឆ្លើយតបចំពោះតម្រូវការជាអាទិភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក និងប្រជាពលរដ្ឋទាំងអស់ក្នុងស្រុករបស់ខ្លួន។

**មាត្រា ១១៧.-**

ដើម្បីលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍ ក្រុមប្រឹក្សាស្រុកត្រូវធានាឱ្យមានកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលគ្នារវាងក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក រវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ព្រមទាំងកិច្ចសហប្រតិបត្តិការរវាងក្រុមប្រឹក្សាស្រុក ជាមួយក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នា និងក្រុមប្រឹក្សាប្រភេទផ្សេងទៀត។

**មាត្រា ១១៨.-**

ផ្អែកតាមនីតិវិធី និងដំណើរការនៃការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ស្រុក ក្រុមប្រឹក្សាស្រុកត្រូវធានាធ្វើការពិគ្រោះ ពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក ដើម្បីដាក់បញ្ចូលនូវយុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាពសម្រាប់ឆ្លើយតបតម្រូវការ និងសំណើរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំរបស់ស្រុក និងផែនការ

អភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ឃុំ សង្កាត់ក្នុងស្រុក។

ក្រុមប្រឹក្សាស្រុកត្រូវធ្វើការពិគ្រោះ ពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីរៀបចំដាក់បញ្ចូល និងឆ្លុះបញ្ចាំងទៅវិញទៅមកនូវគម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សាស្រុក និងរបស់ក្រុមប្រឹក្សាឃុំ របស់ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក ស្របតាមបែបបទ នីតិវិធី នៃការរៀបចំថវិកាប្រចាំឆ្នាំ និងការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ស្រុក ឃុំ និងសង្កាត់ក្នុងស្រុក។

**មាត្រា ១១៩.-**

មេឃុំ ចៅសង្កាត់ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក ដើម្បីធ្វើការពិភាក្សាផ្តល់យោបល់ និងលើកសំណូមពរលើកិច្ចការណាមួយដែលពាក់ព័ន្ធផលប្រយោជន៍នៃឃុំ សង្កាត់របស់ខ្លួន ជូនក្រុមប្រឹក្សាស្រុក ដើម្បីពិនិត្យ ពិចារណា មុននឹងក្រុមប្រឹក្សាស្រុកធ្វើការសម្រេចលើកិច្ចការនោះ។

មេឃុំ ចៅសង្កាត់ដែលចូលរួមប្រជុំក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុក ត្រូវគោរពបទបញ្ជាផ្ទៃក្នុងនៃកិច្ចប្រជុំ និងមិនមានសិទ្ធិអនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុកបានឡើយ។

មេឃុំ ចៅសង្កាត់ត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធ្វើការផ្សព្វផ្សាយជូនប្រជាពលរដ្ឋ អំពីសេចក្តីសម្រេចនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក។

**មាត្រា ១២០.-**

ក្រុមប្រឹក្សាស្រុកត្រូវចាត់សមាជិកក្រុមប្រឹក្សាស្រុកមួយរូបឬច្រើនរូប ឱ្យធ្វើជាតំណាងក្រុមប្រឹក្សាស្រុក ដើម្បីចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុករបស់ខ្លួន។

តំណាងដែលចូលរួមប្រជុំនេះ ត្រូវជម្រាបជូនក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់អំពីសកម្មភាព និងការសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក និងការស្រាយបំភ្លឺលើបញ្ហានានាដែលស្នើឡើងដោយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ព្រមទាំងប្រមូលយកនូវសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ សង្កាត់ ដែលក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបាន។

តំណាងក្រុមប្រឹក្សាស្រុកដែលចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ត្រូវគោរពបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងមិនមានសិទ្ធិអនុម័តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់បានឡើយ។

សមាជិកក្រុមប្រឹក្សាស្រុកដែលចាត់ឱ្យចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ត្រូវធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការចូលរួមប្រជុំខាងលើនេះ ដោយរួមបញ្ចូលទាំងសំណើ សំណូមពរ និងបញ្ហាប្រឈមនានាដែលបានលើកឡើងដោយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់។ សេចក្តីរាយការណ៍នេះត្រូវបញ្ជូនមកគណៈអភិបាលស្រុក ដើម្បីធ្វើការពិនិត្យ និងដោះស្រាយជាបន្ទាន់នូវសំណើ សំណូមពរ ឬបញ្ហាប្រឈមទាំងឡាយណាដែលស្ថិតក្នុងក្របខ័ណ្ឌ តួនាទី សមត្ថកិច្ចរបស់គណៈអភិបាល។ ចំពោះសំណើ សំណូមពរ និងបញ្ហាប្រឈមទាំងឡាយណាដែលស្ថិតក្នុងក្របខ័ណ្ឌ តួនាទី សមត្ថកិច្ចរបស់ក្រុមប្រឹក្សា គណៈអភិបាលត្រូវចាត់ចែងធ្វើការសិក្សា ពិគ្រោះយោបល់ រៀបចំបែបបទ ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ សម្រេច។

**មាត្រា ១២១.-**

ក្នុងអំឡុងខែមិថុនានៃឆ្នាំនីមួយៗ ក្រុមប្រឹក្សាស្រុកត្រូវរៀបចំឱ្យមានវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នៅតាមឃុំនិងតាមសង្កាត់ក្នុងស្រុករបស់ខ្លួន ។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ ត្រូវចូលរួមដោយក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក សមាជិកក្រុមប្រឹក្សាឃុំ សមាជិកក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក តំណាងសហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធដទៃទៀតតាមការសម្រេចពីក្រុមប្រឹក្សាស្រុក ។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ មានគោលបំណងដើម្បីឱ្យក្រុមប្រឹក្សាស្រុក ជម្រាបជូនក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធនានា អំពីសកម្មភាពរបស់ក្រុមប្រឹក្សាស្រុក ក្នុងចន្លោះពេលពីវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់មួយទៅវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់មួយ ការឆ្លើយតបចំពោះសំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ការពិភាក្សា ស្រាយបំភ្លឺអំពីបញ្ហានានាដល់អ្នកចូលរួម ព្រមទាំងការប្រមូលមតិយោបល់នានាពីអ្នកចូលរួម ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន ។

ប្រធានក្រុមប្រឹក្សាស្រុកជាអ្នកសម្របសម្រួលក្នុងវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ ។

គណៈអភិបាលស្រុកក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើការបូកសរុប វាយតម្លៃអំពីលទ្ធផលនៃវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ ក្នុងរយៈពេលយ៉ាងយូរដប់ប្រាំ(១៥)ថ្ងៃបន្ទាប់ ។ ក្នុងការបូកសរុប វាយតម្លៃនេះត្រូវលើកឡើងនូវគោលការណ៍និងវិធានការ ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន ក្នុងក្របខ័ណ្ឌតួនាទី សមត្ថកិច្ចរបស់រដ្ឋបាលស្រុក ។ ចំពោះកិច្ចការទាំងឡាយណាដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀត រដ្ឋបាលស្រុកត្រូវពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាដែលពាក់ព័ន្ធទាំងនោះ ដើម្បីលើកឡើងអំពីគោលការណ៍ វិធានការដោះស្រាយតាមសមត្ថកិច្ចរៀងៗខ្លួន ។ គណៈអភិបាលស្រុកត្រូវបញ្ជូនរបាយការណ៍ខាងលើនេះមួយច្បាប់មករដ្ឋបាលខេត្ត ដើម្បីពិនិត្យ និងដោះស្រាយកិច្ចការទាំងឡាយណាដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរដ្ឋបាលខេត្ត ។ ចំពោះកិច្ចការដែលពាក់ព័ន្ធសមត្ថកិច្ចដោះស្រាយរបស់ថ្នាក់ជាតិ គណៈអភិបាលខេត្តត្រូវធ្វើការប្រមូលផ្តុំពីគ្រប់ស្រុក ដើម្បីធ្វើសេចក្តីរាយការណ៍មកក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សារបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំបន្ថែមទៀតអំពីការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់តាមការចាំបាច់ ។

**មាត្រា ១២២.-**

ដើម្បីធានាឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក ទទួលបានមុខងារ និងធនធានកាន់តែច្រើនថែមទៀតសំដៅឱ្យឃុំ សង្កាត់លើកកម្ពស់សមត្ថភាពក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅតាមឃុំ សង្កាត់នីមួយៗ ក្រុមប្រឹក្សាស្រុកត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធដើម្បី :

- វាយតម្លៃសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នីមួយៗ យ៉ាងហោចណាស់មួយ(០១)ឆ្នាំម្តង

- ធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ផ្អែកតាមការវាយតម្លៃខាងលើនេះ
- អប់រំ ផ្សព្វផ្សាយអំពីអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ វិសហមជ្ឈការដល់ប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិបាលកិច្ចក្នុងស្រុក និងឃុំ សង្កាត់ក្នុងស្រុក ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវរៀបចំប្រព័ន្ធនិងនីតិវិធីសម្រាប់រដ្ឋបាលខេត្ត ធ្វើការគាំទ្រដល់ក្រុមប្រឹក្សាស្រុកក្នុងការរៀបចំប្រព័ន្ធវាយតម្លៃសមត្ថភាព ប្រព័ន្ធបណ្តុះបណ្តាលកសាងសមត្ថភាព និងប្រព័ន្ធអប់រំប្រជាពលរដ្ឋខាងលើនេះ ដើម្បីធានាឱ្យការវាយតម្លៃសមត្ថភាពខាងលើនេះត្រូវបានធ្វើឡើងស្របតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តនានា ហើយធានាថាខ្លឹមសារនិងគុណភាពនៃការអប់រំ បណ្តុះបណ្តាល និងការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដែលធ្វើឡើងដោយក្រុមប្រឹក្សាស្រុក មានការឆ្លើយតបតាមខ្លឹមសារនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ១២៣.-**

ផ្អែកលើការវាយតម្លៃសមត្ថភាពដូចមានចែងក្នុងមាត្រា១២២នៃអនុក្រឹត្យនេះ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ក្រុមប្រឹក្សាស្រុកត្រូវសម្របសម្រួលនិងគាំទ្រដល់ការបង្កើនសមត្ថភាពផ្នែករដ្ឋបាលឬធនធានផ្នែករដ្ឋបាលដែលចាំបាច់ដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ សំដៅធានាឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់មានសមត្ថភាពផ្នែករដ្ឋបាលឬធនធានផ្នែករដ្ឋបាលគ្រប់គ្រាន់ និងជាអចិន្ត្រៃយ៍ ដើម្បី :

- ជំរុញនិងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ឬដើម្បីបំពេញមុខងារ ភារកិច្ចចាំបាច់នានា
- បំពេញសមត្ថភាពផ្នែករដ្ឋបាលនិងធនធានផ្នែករដ្ឋបាល រួមទាំងបុគ្គលិក ឧបករណ៍ ទ្រព្យសម្បត្តិ និងសម្ភារៈចាំបាច់នានា ។

**មាត្រា ១២៤.-**

ក្នុងការរៀបចំ ចាត់ចែងបង្កើនសមត្ថភាពផ្នែករដ្ឋបាលឬធនធានផ្នែករដ្ឋបាលនៅក្នុងឃុំ សង្កាត់ ក្រុមប្រឹក្សាស្រុកអាចសម្របសម្រួលឱ្យមានការស្រុះស្រួលគ្នាក្នុងចំណោមក្រុមប្រឹក្សាឃុំ សង្កាត់ពីរ ឬច្រើន ដើម្បីប្រើប្រាស់រួមគ្នានូវបុគ្គលិក ឧបករណ៍ ទ្រព្យសម្បត្តិ ឬសម្ភារៈខ្លះ ឬទាំងអស់តាមការចាំបាច់ ។

ក្រុមប្រឹក្សាស្រុកអាចធ្វើការពិគ្រោះយោបល់និងសម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ដើម្បីប្រើប្រាស់នូវបុគ្គលិករបស់រដ្ឋបាលស្រុក ដើម្បីជួយគាំទ្រធនធានផ្នែករដ្ឋបាលនិងសមត្ថភាពផ្នែករដ្ឋបាលដល់រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ តាមការចាំបាច់ ។

បុគ្គលិករបស់ស្រុកដែលចាត់ឱ្យជួយគាំទ្រខាងលើនេះ ត្រូវមានគណនេយ្យភាពអំពីសកម្មភាពរបស់ខ្លួនចំពោះក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ដែលខ្លួនគាំទ្រ ហើយត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាស្រុក អំពីការគោរពនិងការអនុវត្តភារកិច្ចស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំបន្ថែមអំពីការរៀបចំយន្តការនានាក្នុងការគាំទ្រនិងបង្កើនសមត្ថភាពផ្នែករដ្ឋបាលឬធនធានផ្នែករដ្ឋបាលដល់ឃុំ សង្កាត់ ។

**មាត្រា ១២៥.-**

ក្នុងដំណើរការគាំទ្រនិងជួយបំពេញសមត្ថភាពផ្នែករដ្ឋបាលឬធនធានផ្នែករដ្ឋបាល ក្រុមប្រឹក្សាស្រុកត្រូវធានាអំពីគោលការណ៍ស្វ័យភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងឋានៈរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដែលត្រូវបានប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសឡើងដោយផ្ទាល់ ។

ក្នុងដំណើរការគាំទ្រនិងការជួយបំពេញសមត្ថភាពផ្នែករដ្ឋបាលឬធនធានផ្នែករដ្ឋបាល ក្រុមប្រឹក្សាស្រុកត្រូវលើកកម្ពស់ភាពជាម្ចាស់ដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ក្នុងការបំពេញមុខងារ ភារកិច្ចចាំបាច់មួយ ឬច្រើនទៅតាមឃុំ សង្កាត់នីមួយៗ ដោយមិនត្រូវធ្វើជំនួសឡើយ ។

**មាត្រា ១២៦.-**

ក្នុងករណីក្រុមប្រឹក្សាស្រុកបានប្រឹងប្រែងសម្របសម្រួលបង្កើនសមត្ថភាពផ្នែករដ្ឋបាលឬធនធានផ្នែករដ្ឋបាលដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់រួចហើយ ប៉ុន្តែក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នោះនៅតែមិនអាចបំពេញភារកិច្ចជាមូលដ្ឋាន និងចាំបាច់របស់ខ្លួនបាន ឬមិនអាចជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យឱ្យបានគ្រប់គ្រាន់ ក្រុមប្រឹក្សាស្រុកត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយដាក់បញ្ចូលនូវអនុសាសន៍សមស្រប ដើម្បីកែតម្រូវកង្វះខាតទាំងនេះ ឬតម្រូវការចាំបាច់ណាមួយដែលក្រុមប្រឹក្សាស្រុកនិងក្រុមប្រឹក្សាឃុំ ឬក្រុមប្រឹក្សាសង្កាត់មិនអាចបំពេញបាន។

ក្នុងការធ្វើសេចក្តីរាយការណ៍នេះ ក្រុមប្រឹក្សាស្រុកត្រូវផ្អែកតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១៩៦ នៃអនុក្រឹត្យនេះ ។

**មាត្រា ១២៧.-**

ក្នុងករណីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឯកភាពតាមសេចក្តីរាយការណ៍របស់ក្រុមប្រឹក្សាស្រុក រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវរៀបចំគណៈកម្មាធិការឬក្រុមការងារមួយដែលចូលរួមដោយអ្នកពាក់ព័ន្ធ ដើម្បីធ្វើការពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ ឬក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធនានាអំពីតម្រូវការចាំបាច់នានា ដើម្បីរៀបចំមធ្យោបាយសមស្របក្នុងការផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ ឬក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធទាំងនោះ ។

**មាត្រា ១២៨.-**

ក្រុមប្រឹក្សាស្រុក ត្រូវបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈដីកានិងសេចក្តីសម្រេចនានាក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថា សេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការតាមដាននិងវាយតម្លៃជាប្រចាំ ។

**មាត្រា ១២៩.-**

កិច្ចប្រជុំក្រុមប្រឹក្សាស្រុកអាចយកជាការបាន លុះត្រាតែកិច្ចប្រជុំនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន ។

សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាស្រុករបស់ខ្លួន មិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវណែនាំឬអាចធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាស្រុកកែតម្រូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះឡើងវិញ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ ។

**មាត្រា ១៣០.-**

ក្រុមប្រឹក្សាស្រុក អាចចាត់ឱ្យគណៈកម្មាធិការណាមួយឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការឬអនុគណៈកម្មាធិការឬក្រុមការងារនានាដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកាឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់ ។ ក្នុងករណីនេះ គណៈអភិបាលស្រុកត្រូវដឹកនាំនាយករដ្ឋបាលសាលាស្រុកនិងការិយាល័យពាក់ព័ន្ធនៃសាលាស្រុក ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេសនិងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ ។

គណៈអភិបាលស្រុក ដោយមាននាយករដ្ឋបាលសាលាស្រុកជាជំនួយការ ត្រូវធ្វើការសម្របសម្រួល ណែនាំដល់ការិយាល័យនានានៃសាលាស្រុក រៀបចំសេចក្តីព្រាងដីកា និងសេចក្តីព្រាងសេចក្តីសម្រេចដាក់ជូនក្រុមប្រឹក្សាពិនិត្យពិភាក្សានិងអនុម័ត ។

គណៈអភិបាលស្រុក ត្រូវណែនាំនាយករដ្ឋបាលសាលាស្រុកឱ្យរៀបចំដីកា និងសេចក្តីសម្រេចដែលក្រុមប្រឹក្សាស្រុកបានអនុម័តរួច ឱ្យស្របតាមទម្រង់ដែលកំណត់ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាស្រុកចុះហត្ថលេខា ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួននិងត្រូវប្រថាប់ត្រារដ្ឋបាលស្រុក ។

ក្រុមប្រឹក្សាស្រុកត្រូវចាត់ឱ្យគណៈអភិបាលចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកាឬសេចក្តីសម្រេចទាំងឡាយណាដែលក្រុមប្រឹក្សាស្រុកបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះ ព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព ។

**មាត្រា ១៣១.-**

ប្រធានក្រុមប្រឹក្សាស្រុកក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានសិទ្ធិចុះហត្ថលេខានិងប្រថាប់ត្រារដ្ឋបាលស្រុកលើ :

- ដីកាឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាស្រុកបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការឬអនុគណៈកម្មាធិការឬក្រុមការងារ
  តាមការសម្រេចរបស់អង្គប្រជុំ ក្រុមប្រឹក្សារបស់ខ្លួន

- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាស្រុក
- សំណើដកហូតអភិបាលស្រុកឬអភិបាលរងស្រុកចេញពីមុខតំណែង តាមការសម្រេចពីក្រុមប្រឹក្សាស្រុក តាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា១៥២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាស្រុក
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាស្រុករយៈពេលដប់ពីរ(១២)ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាស្រុក
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

គណៈអភិបាលស្រុក ត្រូវជួយក្រុមប្រឹក្សារបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែឯកសារក្នុងចំណុចគំនូសទី៤។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំអំពីទម្រង់នៃឯកសារខាងលើតាមការចាំបាច់។

**មាត្រា ១៣២.-**

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាស្រុកត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ ដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលស្រុក និងវិធានការ បែបបទ នីតិវិធីចាត់ចែងការងារតាមការចាំបាច់ ដែលទាក់ទងទៅនឹង :

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាស្រុក
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាស្រុក
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទដូចគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន មន្ទីរ ឬការិយាល័យ អង្គភាពនានារបស់រាជរដ្ឋាភិបាលនិងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំនិងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលស្រុក
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាស្រុក
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាស្រុក ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនិងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាស្រុក
- ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុក

- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជន រួមទាំងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុក និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក
- ការចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ដោយតំណាងក្រុមប្រឹក្សាស្រុក
- ការគាំទ្រនានាដោយក្រុមប្រឹក្សាស្រុក ចំពោះក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ១៣៣.-**

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាស្រុកត្រូវធ្វើការសម្រេចរៀងរាល់កិច្ចប្រជុំដូចមានចែងក្នុងមាត្រា១៣២នៃអនុក្រឹត្យនេះ ក្រុមប្រឹក្សាស្រុកអាចធ្វើការសម្រេចនៅក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការនានា ដែលរួមមាន :

- ការកោះអញ្ជើញអភិបាលស្រុក ឬអភិបាលរងស្រុក ឬគណៈអភិបាលស្រុកទាំងមូល ឬបុគ្គលដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្រុក ឬហេតុការណ៍ណាមួយដែលកើតមានក្នុងស្រុក ឬការដោះស្រាយបញ្ហាបន្ទាន់ និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលស្រុក
- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវ ឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាស្រុកយល់ឃើញថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការធ្វើអង្កេតនេះ ព្រមទាំងណែនាំដល់គណៈអភិបាលស្រុកអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនោះ
- ការវាយតម្លៃអំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់និងតម្រូវការចាំបាច់ក្នុងការគាំទ្រឃុំ សង្កាត់ក្នុងស្រុក ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១២២នៃអនុក្រឹត្យនេះ
- ការពិនិត្យស្រាវជ្រាវ និងការធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សាស្រុក ឬសមាជិកក្រុមប្រឹក្សាស្រុក ឬដោយគណៈអភិបាលស្រុក ឬអភិបាលស្រុក ឬអភិបាលរងស្រុក ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក តាមគោលការណ៍ដូចមានចែងក្នុងផ្នែកទី៥ ជំពូកទី២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន
- ការពិនិត្យនិងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែន

សមត្ថកិច្ចរបស់ខ្លួន

- ពិនិត្យនិងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលស្រុក
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុក យល់ឃើញថាចាំបាច់។

**មាត្រា ១៣៤.-**

ក្រុមប្រឹក្សាស្រុក ត្រូវប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ ដោយផ្អែកតាមគោលការណ៍ បែបបទនិងនីតិវិធីដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

ក្នុងករណីកិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយកិច្ចការនោះ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទនិងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាស្រុក ត្រូវចាត់ឱ្យគណៈអភិបាលស្រុកធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទនិងនីតិវិធីសមស្រប ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនេះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឬរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធនានាធ្វើការបញ្ជាក់នូវបែបបទនីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនោះ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ។

ក្នុងករណីកិច្ចការណាមួយដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទនិងនីតិវិធីដែរ ប៉ុន្តែបែបបទនិងនីតិវិធីនោះចែងមិនច្បាស់លាស់ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាស្រុកមិនអាចអនុវត្តបាន ក្រុមប្រឹក្សាស្រុកត្រូវចាត់ឱ្យគណៈអភិបាលស្រុកធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវផ្អែកតាមយន្តការនៃ គ.ជ.អ.ប. ធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងដោះស្រាយករណីនេះ។

**មាត្រា ១៣៥.-**

អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាស្រុកបានសម្រេចរួចហើយ គណៈអភិបាលស្រុកត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

គណៈអភិបាលស្រុក ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ក្រុមប្រឹក្សាស្រុក ដូចមានចែងក្នុងមាត្រា១៣២និងមាត្រា១៣៣នៃអនុក្រឹត្យនេះ។

ក្រុមប្រឹក្សាស្រុក ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលស្រុក ដើម្បីធានាថាគណៈអភិបាលស្រុកអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាស្រុក។

គ.ជ.អ.ប. ត្រូវដាក់ចេញនូវគោលការណ៍ណែនាំ គាំទ្រដល់ក្រុមប្រឹក្សាស្រុក ក្នុងការរៀបចំនូវប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក។

## ផ្នែកទី២
## អំពីគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក

**មាត្រា ១៣៦.-**

ក្រុមប្រឹក្សាស្រុក ត្រូវមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមាន ៈ

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម ។

កិច្ចដំណើរការនៃគណៈកម្មាធិការទាំងបីខាងលើ ត្រូវផ្អែកតាមលិខិតបទដ្ឋានស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទាំងនេះ ។

**មាត្រា ១៣៧.-**

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាស្រុកអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទាំងបីដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឡើយ ។

ក្រុមប្រឹក្សាស្រុក អាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗទៀតតាមការស្នើសុំរបស់គណៈកម្មាធិការនានាឬគណៈអភិបាលស្រុក ។

អនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ ត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការឬគណៈអភិបាលស្រុក ។

**មាត្រា ១៣៨.-**

ក្រុមប្រឹក្សាស្រុក អាចតែងតាំងសមាជិកក្រុមប្រឹក្សាស្រុក អភិបាលស្រុក អភិបាលរងស្រុក តំណាងក្រុមប្រឹក្សាឃុំ តំណាងក្រុមប្រឹក្សាសង្កាត់ បុគ្គលិករបស់ក្រុមប្រឹក្សាស្រុក តំណាងសហគមន៍ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់សម្រាប់ជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង ។

ក្រុមប្រឹក្សាស្រុក ត្រូវសម្រេចពីចំនួនសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ការតែងតាំងប្រធាន អនុប្រធាន និងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាដែលខ្លួនបានបង្កើតឡើង ។

គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗត្រូវមានតំណាងស្ត្រីសមស្រប រួមទាំងប្រធាន ឬអនុប្រធានគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារផង ។

ក្រុមប្រឹក្សាស្រុក អាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើងតាមការចាំបាច់ឬតាមសំណើរបស់គណៈកម្មាធិការឬគណៈអភិបាលស្រុក។

**មាត្រា ១៣៩.-**

គណៈអភិបាលស្រុក អាចស្នើសុំក្រុមប្រឹក្សាស្រុកដើម្បីឱ្យគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយដែលក្រុមប្រឹក្សាស្រុកបានបង្កើតឡើង រួមទាំងគណៈកម្មាធិការទាំងបី(០៣)ដែលតម្រូវដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយ ឬមួយចំនួនដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈអភិបាលស្រុក។

**មាត្រា ១៤០.-**

ក្រុមប្រឹក្សាស្រុក ត្រូវទទួលខុសត្រូវរាល់ការសម្រេចនិងសកម្មភាពរបស់គណៈកម្មាធិការនានានិងទទួលខុសត្រូវចំពោះផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ។

**មាត្រា ១៤១.-**

ក្រុមប្រឹក្សាស្រុក ត្រូវណែនាំឱ្យគណៈអភិបាលស្រុកផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់និងបច្ចេកទេស ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការទាំងបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាស្រុកបានបង្កើតឡើង។

**មាត្រា ១៤២.-**

គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមតម្រូវការចាំបាច់នានា។

សេចក្តីរាយការណ៍ខាងលើនេះ ត្រូវចម្លងជូនគណៈអភិបាលស្រុក ដើម្បីធ្វើការបូកសរុបនិងរាយការណ៍ជូនក្រុមប្រឹក្សា។

ក្រុមប្រឹក្សាស្រុក អាចតម្រូវឱ្យគណៈកម្មាធិការណាមួយរាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេសនិងបន្ទាន់ណាមួយ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុកតាមការចាំបាច់របស់ខ្លួន។

## ផ្នែកទី៣

## គណៈអភិបាលស្រុក

**មាត្រា ១៤៣.-**

ស្រុកនីមួយៗ ត្រូវមានគណៈអភិបាលមួយដែលរួមមាន អភិបាល អភិបាលរង ដែលត្រូវបានតែងតាំងឡើងស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ១៤៤.-**

អភិបាល អភិបាលរងស្រុក មិនមែនជាសមាជិកក្រុមប្រឹក្សាស្រុកឡើយ ។

**មាត្រា ១៤៥.-**

គណៈអភិបាលស្រុក ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន អំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុកនិងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា ។

**មាត្រា ១៤៦.-**

គណៈអភិបាលស្រុក មានភារកិច្ចផ្តល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សាស្រុក និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្រុក ទាំងសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ ។

**មាត្រា ១៤៧.-**

គណៈអភិបាលស្រុក ត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាស្រុកអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញ ទាក់ទងនឹង :

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាស្រុកនិងអំពីរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្ត្រនិងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ឬបានផ្ទេរស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥) ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣) ឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការងារហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ស្រុក
- ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការកំណត់នីតិវិធីរដ្ឋបាលនិងហិរញ្ញវត្ថុសម្រាប់ការិយាល័យនិងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុកនិងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាស្រុកពិនិត្យនិងអនុម័ត មិនឱ្យលើសពីសែសិបប្រាំ(៤៥) ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ដែលពាក់ព័ន្ធនឹង :

+ ដីកានិងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាស្រុកនិងសកម្មភាព លទ្ធផលនៃការអនុវត្ត
+ របាយការណ៍ហិរញ្ញវត្ថុ
+ ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលនិងបុគ្គលិក
+ វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាស្រុក
+ វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
+ កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាស្រុកយល់ឃើញថាចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។

- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការវាយតម្លៃសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក និងតម្រូវការគាំទ្រចំពោះឃុំ សង្កាត់ក្នុងស្រុក
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាស្រុក
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្តារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាននិងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- កិច្ចសហការនិងការគាំទ្រដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នៅក្នុងស្រុករបស់ខ្លួន
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ១៤៨.-**

នៅពេលបានទទួលរបាយការណ៍ ឬព័ត៌មានអំពីការរំលោភអំណាច ដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨និងមាត្រា៤៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលស្រុកត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថា មានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនក្រុមប្រឹក្សាស្រុកនិងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១៤៩.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា១៤៧និងមាត្រា១៤៨នៃអនុក្រឹត្យនេះ និងការងារដទៃទៀត ដែលខ្លួនយល់ឃើញថាចាំបាច់ អភិបាលស្រុកត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលស្រុករបស់ខ្លួន ដោយឈរលើគោលការណ៍ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេចនិងគោលការណ៍

ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន ។

អភិបាលស្រុក ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាស្រុកអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរបស់ខ្លួន ។

អភិបាលរងស្រុក ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលស្រុកលើភារកិច្ចនានាដែលបានប្រគល់ជូន ហើយត្រូវរួមជាមួយអភិបាលទទួលខុសត្រូវអំពីការសម្រេចនិងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន ។

ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលស្រុកត្រូវជួបប្រជុំគ្នាប្រចាំអឌ្ឍមាស ។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ ។

ក្រៅពីការប្រជុំប្រចាំអឌ្ឍមាស និងការប្រជុំប្រចាំខែខាងលើ គណៈអភិបាលស្រុកអាចកោះប្រជុំតាមការចាំបាច់ ។

រៀងរាល់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ ។

**មាត្រា ១៥០.-**

គណៈអភិបាលស្រុក ឬអភិបាលស្រុក ឬអភិបាលរងស្រុក ដែលបានសម្រេច និង/ឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាស្រុក ការសម្រេចឬសកម្មភាពនោះពុំមានសុពលភាពឡើយ ។

គណៈអភិបាលស្រុក ឬអភិបាលស្រុក ឬអភិបាលរងស្រុក ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេចឬសកម្មភាពខាងលើនេះ ។

**មាត្រា ១៥១.-**

គណៈអភិបាលស្រុក ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលស្រុកនិងអភិបាលរងស្រុក ហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីការបែងចែកភារកិច្ចដល់អភិបាលស្រុក អភិបាលរងស្រុក និងរបៀបរបបអនុវត្តភារកិច្ចដែលបានបែងចែកនោះ ។

**មាត្រា ១៥២.-**

អភិបាលស្រុក ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សារបស់ខ្លួន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាស្រុកចុះហត្ថលេខា ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនដូចមានចែងក្នុងមាត្រា១៣១នៃអនុក្រឹត្យនេះ ។

អភិបាលស្រុក អាចប្រគល់សិទ្ធិដល់អភិបាលរងស្រុកក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងស្រុកនីមួយៗ ។

អភិបាលស្រុកត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងស្រុក ។

អភិបាលស្រុក មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងស្រុកណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់និងមិនស្របតាមបែបបទ នីតិវិធី ។ ការប្រគល់និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលស្រុកត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការប្រគល់សិទ្ធិចុះហត្ថលេខានេះ ។

**មាត្រា ១៥៣.-**

ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងស្រុក អភិបាលស្រុក មានភារកិច្ច :

- ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ឱ្យអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ
- សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន ។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលស្រុកត្រូវធ្វើការសម្របសម្រួលការិយាល័យ អង្គភាព ទីភ្នាក់ងារពាក់ព័ន្ធដើម្បីសហការគ្នាអនុវត្តកិច្ចការនោះ ដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងតម្រូវការអាទិភាពរបស់មូលដ្ឋាន ។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក អភិបាលស្រុកត្រូវសម្របសម្រួលតម្រង់ទិសការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ក្នុងការធ្វើសមាហរណកម្មផែនការនិងថវិការបស់ខ្លួនទៅក្នុងផែនការនិងថវិការបស់ក្រុមប្រឹក្សាស្រុក ។
- ពិនិត្យវាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានការិយាល័យអង្គភាពនៃក្រសួង ស្ថាប័ននានាតាមគោលការណ៍កំណត់
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាស្រុកជាមុន ក្នុងការផ្តល់យោបល់លើបេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យនិងអង្គភាពនៃក្រសួង ស្ថាប័ននានាប្រចាំក្នុងស្រុករបស់ខ្លួន ។ ក្នុងករណីមិនគាំទ្របេក្ខភាពដែលស្នើតែងតាំងខាងលើនេះ អភិបាលស្រុកត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់ពីហេតុផលនៃការមិនគាំទ្រនេះជូនអភិបាលខេត្ត ដើម្បីអភិបាលខេត្តធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីជាមុន មុននឹងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ។
- ក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីដែលកើតមានក្នុងការិយាល័យ អង្គភាព និងទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងស្រុករបស់ខ្លួនឬករណីប្រធានការិយាល័យ ប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យ អង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទី ភារកិច្ចរបស់ខ្លួន អភិបាលស្រុកត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរនិងជាបន្ទាន់ទៅអភិបាលខេត្ត ។ អភិបាលខេត្ត ត្រូវណែនាំដល់មន្ទីរ

អង្គភាពខ្សែបណ្តោយសាមីនៅថ្នាក់ខេត្តឬអាចចាត់តាំងគណៈកម្មការ ឬក្រុមការងារ ដែលមានការចូលរួមពីតំណាងស្រុកពាក់ព័ន្ធ ឱ្យធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ ដើម្បីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដោះស្រាយស្របតាមនីតិវិធី ។

– អភិបាលស្រុកមានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្ត ដើម្បីចាត់វិធានការផ្លាស់ប្តូរឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តិកម្មបាន។

ដើម្បីធានាឱ្យអភិបាលស្រុកអនុវត្តនូវភារកិច្ចខាងលើនេះ សេចក្តីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅស្រុក ត្រូវដាក់ជូនអភិបាលស្រុកដើម្បីពិនិត្យនិងផ្តល់យោបល់។ ប្រសិនបើអភិបាលស្រុកឯកភាព អភិបាលត្រូវចុះហត្ថលេខាលើរបាយការណ៍នោះរួមជាមួយប្រធានការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។ ចំពោះសេចក្តីរាយការណ៍ក្រៅពីនោះរបស់ការិយាល័យ អង្គភាពនិងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ត្រូវចម្លងជូនសាលាស្រុក។

**មាត្រា ១៥៤.-**

អភិបាលស្រុកត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងស្រុក អំពីច្បាប់និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារនិងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងស្រុក។

អភិបាលស្រុក គឺជាប្រធានគណៈបញ្ជាការឯកភាពស្រុក ក្នុងការដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់និងរបៀបរៀបរយសាធារណៈនៅក្នុងស្រុក។

**មាត្រា ១៥៥.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា១៥៣និងមាត្រា១៥៤នៃអនុក្រឹត្យនេះ អភិបាលស្រុកត្រូវធ្វើការបែងចែកភារកិច្ចដល់អភិបាលរងក្នុងគណៈអភិបាលរបស់ខ្លួន ឱ្យជួយខ្លួនក្នុងការងារខាងលើនេះ។

អភិបាលរងស្រុកដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខអភិបាលស្រុក។

អភិបាលស្រុក ត្រូវកោះប្រជុំគណៈអភិបាលតាមការចាំបាច់ ដើម្បីពិគ្រោះពិភាក្សាលើបញ្ហាណាមួយដែលខ្លួនយល់ឃើញថាចាំបាច់ត្រូវធ្វើការពិភាក្សាក្នុងគណៈអភិបាលស្រុក សំដៅលើកកម្ពស់ការចូលរួមអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាលនិងក្រសួង ស្ថាប័ននានា។

គ្រប់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុប្រជុំ។

**មាត្រា ១៥៦.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា១៥៣និងមាត្រា១៥៤នៃអនុក្រឹត្យនេះ អភិបាលស្រុកត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃនិងក្រសួង ស្ថាប័ននានា ស្របទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ១៥៧.-**

អភិបាលស្រុកដោយមាននាយករដ្ឋបាលជាជំនួយការ ត្រូវធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពនិងលទ្ធផលនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាលនិងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាស្រុករបស់ខ្លួន។

ក្នុងករណីមានបញ្ហាណាមួយ ដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលស្រុកក្នុងនាមជាតំណាងរាជរដ្ឋាភិបាលនិងតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋឬមានការទាមទារតវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុកអាចតម្រូវឱ្យអភិបាលស្រុកធ្វើសេចក្តីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សាស្រុក។

ក្រុមប្រឹក្សាស្រុក អាចផ្តល់អនុសាសន៍និងការណែនាំដល់អភិបាលស្រុកអំពីការអនុវត្តតួនាទីខាងលើនេះ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាពនិងបញ្ហាប្រឈមនានារបស់មូលដ្ឋាន។

អភិបាលស្រុក ត្រូវទទួលយកអនុសាសន៍និងការណែនាំពីក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធ្វើការណែនាំសម្របសម្រួលនិងតម្រង់ទិសដល់ការិយាល័យ អង្គភាពនិងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ក្នុងការឆ្លើយតបតម្រូវការទាំងនោះ ហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនវិញ។

**មាត្រា ១៥៨.-**

ក្នុងករណីអភិបាលស្រុកអវត្តមាន អភិបាលស្រុកត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងស្រុកមួយរូប ឱ្យទទួលជាអភិបាលស្រុកស្តីទី។

ប្រសិនបើអភិបាលស្រុកអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងស្រុកដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃប្រកាសតែងតាំងអភិបាលរងនៃគណៈអភិបាលស្រុក ត្រូវធ្វើជាអភិបាលស្រុកស្តីទី។

ក្នុងករណីអភិបាលស្រុកស្តីទីអវត្តមាន អភិបាលខេត្តត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងស្រុកមួយរូបឱ្យទទួលជាអភិបាលស្រុកស្តីទីនិងត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើសេចក្តីរាយការណ៍មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលស្រុកស្តីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្ត ជូនអភិបាលស្រុក នៅពេលដែលអភិបាលស្រុកមានវត្តមានវិញ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំស្តីពីបែបបទនិងនីតិវិធីនៃការផ្ទេរសិទ្ធិនេះ។

**មាត្រា ១៥៩.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើសេចក្តីណែនាំស្តីពីការសុំច្បាប់ឈប់សម្រាករបស់អភិបាលស្រុក អភិបាលរងស្រុកនិងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក។

## ផ្នែកទី៤
## នាយករដ្ឋបាលសាលាស្រុក

**មាត្រា ១៦០.-**

ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុក ត្រូវមាននាយករដ្ឋបាលមួយ(០១)រូប ហៅថានាយករដ្ឋបាលសាលាស្រុក ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលស្រុក ដោយយោងតាមការសម្រេចពីក្រុមប្រឹក្សាស្រុក។

នាយករដ្ឋបាលសាលាស្រុក ត្រូវមាននាយករងរដ្ឋបាលសាលាស្រុកយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលស្រុក ដោយយោងតាមការសម្រេចពីក្រុមប្រឹក្សាស្រុក។

នាយករដ្ឋបាលសាលាស្រុក ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិចាប់ពីក្រមការដើមខ្សែនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

នាយករងរដ្ឋបាលសាលាស្រុក ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិចាប់ពីក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

**មាត្រា ១៦១.-**

លក្ខណសម្បត្តិនិងនីតិវិធីសម្រាប់ការតែងតាំងនាយករដ្ឋបាលសាលាស្រុក និងនាយករងរដ្ឋបាលសាលាស្រុក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញប្រកាសឬសេចក្តីណែនាំអំពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់នាយករដ្ឋបាលសាលាស្រុកនិងនាយករងរដ្ឋបាលសាលាស្រុក។

**មាត្រា ១៦២.-**

នាយករដ្ឋបាលសាលាស្រុក មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុកនិងអភិបាលស្រុក ក្នុងការចាត់ចែងកិច្ចការរដ្ឋបាលនិងការធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាស្រុក។

ក្នុងតួនាទីនេះ នាយករដ្ឋបាលសាលាស្រុកត្រូវធ្វើរបាយការណ៍និងត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាលស្រុក អភិបាលស្រុកនិងក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ១៦៣.-**

ក្នុងការអនុវត្តតួនាទីដូចមានចែងក្នុងមាត្រា១៦២នៃអនុក្រឹត្យនេះ នាយករដ្ឋបាលសាលាស្រុក មានភារកិច្ច ៖

- រៀបចំនិងដាក់ជូនគណៈអភិបាលស្រុក ពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាស្រុក ក្នុង

ក្របខ័ណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលស្រុក ហើយត្រូវធានាថាកិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល

- រៀបចំនិងដាក់ជូនគណៈអភិបាលនូវវិធាននិងគោលការណ៍ក្នុងការអនុវត្តដីកានិងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក
- ធ្វើជាសេនាធិការជូនអភិបាលស្រុកនិងប្រធានក្រុមប្រឹក្សា ក្នុងការត្រៀមរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុក រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារនិងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា ស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ សេចក្តីព្រាងរបៀបវារៈ ឯកសារនិងខ្លឹមសារទាំងអស់ដែលនាយករដ្ឋបាលសាលាស្រុកបានរៀបចំសម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សា ត្រូវតែដាក់ជូនគណៈអភិបាល ដើម្បីពិនិត្យនិងផ្តល់យោបល់ជាមុន លើកលែងតែមានការកំណត់ផ្សេងដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។
- ធ្វើជាសេនាធិការជូនក្រុមប្រឹក្សាក្នុងការរៀបចំនិងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំនិងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុក
- ត្រៀមរៀបចំកិច្ចការនានាសម្រាប់បម្រើឱ្យកិច្ចប្រជុំទាំងអស់របស់គណៈអភិបាលស្រុក តាមការណែនាំរបស់អភិបាល
- ធានាក្នុងការទទួលនិងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវ ដល់សមាជិកក្រុមប្រឹក្សាស្រុក អភិបាលស្រុកនិងអភិបាលរងស្រុក ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យជំនាញនិងអ្នកពាក់ព័ន្ធនានា
- គ្រប់គ្រងនិងប្រើប្រាស់ត្រារដ្ឋបាលស្រុកឱ្យបានត្រឹមត្រូវតាមការកំណត់ ដូចមានចែងក្នុងមាត្រា១៧១នៃអនុក្រឹត្យនេះ
- ធានារក្សាទុកដាក់ឱ្យបានត្រឹមត្រូវនិងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុក និងរដ្ឋបាលរបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក អភិបាលស្រុក ឬដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ១៦៥.-**

នាយករដ្ឋបាលសាលាស្រុក មានសិទ្ធិចូលរួមនិងបញ្ចេញយោបល់គ្រប់កិច្ចប្រជុំក្រុមប្រឹក្សាស្រុក កិច្ចប្រជុំគណៈកម្មាធិការ អនុគណៈកម្មាធិការនិងក្រុមការងារនានារបស់ក្រុមប្រឹក្សាស្រុកនិងកិច្ចប្រជុំគណៈអភិបាលស្រុក ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលសាលាស្រុកជាសមាជិកគណៈកម្មាធិការឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយរបស់ក្រុមប្រឹក្សាស្រុក។

**មាត្រា ១៦៥.-**

ក្នុងការចូលរួមក្នុងកិច្ចប្រជុំ ដូចមានចែងក្នុងមាត្រា១៦៤នៃអនុក្រឹត្យនេះនិងការអនុវត្តការងារប្រចាំថ្ងៃ នាយករដ្ឋបាលសាលាស្រុកអាចផ្តល់យោបល់ដល់ក្រុមប្រឹក្សា គណៈកម្មាធិការ អនុគណៈកម្មាធិការនិងក្រុមការងារនានារបស់ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលរបស់ខ្លួន អំពីបញ្ហាច្បាប់និងបច្ចេកទេស ដើម្បីធានាថាសេចក្តីសម្រេចនិងសកម្មភាពនានារបស់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុកនិងអភិបាលស្រុក មានលក្ខណៈសមស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបទដ្ឋានជាតិសម្រាប់សុវត្ថិភាពនិងគុណភាពដែលបានកំណត់ ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងសាលាស្រុក។

**មាត្រា ១៦៦.-**

ដោយមានការដឹកនាំ ណែនាំពីគណៈអភិបាលស្រុកនិងអភិបាលស្រុក នាយករដ្ឋបាលសាលាស្រុកត្រូវធានាឱ្យការិយាល័យ មន្ត្រី បុគ្គលិកទាំងអស់ អនុវត្តការងារឱ្យបានត្រឹមត្រូវទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនានា និងតាមការសម្រេចរបស់ក្រុមប្រឹក្សានិងគណៈអភិបាលរបស់ខ្លួន។

**មាត្រា ១៦៧.-**

គណៈអភិបាលស្រុកនិងអភិបាលស្រុក អាចធ្វើប្រតិភូកម្មដល់នាយករដ្ឋបាលសាលាស្រុក ឱ្យលើកយោបល់លើកិច្ចការណាមួយដែលស្ថិតក្នុងវិសាលភាពនៃតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីគណៈអភិបាល ឬអភិបាល ពិនិត្យសម្រេចតាមការចាំបាច់។

## ផ្នែកទី៥

## សាលាស្រុក និងការិយាល័យចំណុះនានា

**មាត្រា ១៦៨.-**

សាលាស្រុក គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុក។

សាលាស្រុក ត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការរបស់រដ្ឋ។

ក្នុងអំឡុងពេលម៉ោងធ្វើការងារ ប្រជាពលរដ្ឋមានសិទ្ធិ :

- ធ្វើទំនាក់ទំនងនិងធ្វើការងារជាមួយក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុក
- ទទួលព័ត៌មានអំពីសំណើនិងការងារនានាពីរដ្ឋបាលស្រុក
- ចូលរួមយោបល់ឬសំណូមពរលើបញ្ហាណាមួយ។

នៅចន្លោះម៉ោងធ្វើការឬថ្ងៃឈប់សម្រាកជាផ្លូវការ ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុក ត្រូវធានាឱ្យមានមន្ត្រី បុគ្គលិកនៃរដ្ឋបាលរបស់ខ្លួន ក្នុងចំនួនសមស្របប្រចាំការ ដើម្បីទទួលឬដោះស្រាយសំណូមពរបន្ទាន់ពិសេសនានា។

**មាត្រា ១៦៩.-**

រដ្ឋបាលស្រុកនីមួយៗ ត្រូវធ្វើជាម្ចាស់និងទទួលខុសត្រូវចាត់ចែងលើរាល់លិខិតស្នាម ឯកសារទាំងអស់ដែលបានទទួលត្រឹមត្រូវ ឱ្យបានស្របតាមច្បាប់ជាធរមាន។

**មាត្រា ១៧០.-**

រដ្ឋបាលស្រុកនីមួយៗ ជាម្ចាស់និងទទួលខុសត្រូវលើរាល់លិខិតស្នាម ឯកសារនានាដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាស្រុក ឬក្នុងនាមក្រុមប្រឹក្សាស្រុក និងដោយគណៈអភិបាលស្រុកក្នុងនាមរដ្ឋ ព្រមទាំងជាម្ចាស់លើឧបករណ៍ មធ្យោបាយនិងសម្ភារៈនានានៃរដ្ឋបាលរបស់ខ្លួន។

រដ្ឋបាលស្រុកនីមួយៗ ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាម ឧបករណ៍ មធ្យោបាយ សម្ភារៈនានានៃរដ្ឋបាលរបស់ខ្លួន ឱ្យបានត្រឹមត្រូវតាមការកំណត់ មានសណ្តាប់ធ្នាប់ល្អនិងគង់វង្ស។

**មាត្រា ១៧១.-**

ត្រារដ្ឋបាលស្រុកនីមួយៗ ត្រូវបានប្រគល់ឱ្យនាយករដ្ឋបាលសាលាស្រុករបស់ខ្លួន ដើម្បីទទួលខុសត្រូវនិងគ្រប់គ្រងសម្រាប់ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុកប្រើប្រាស់។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើការណែនាំអំពីការគ្រប់គ្រងនិងប្រើប្រាស់ត្រាខាងលើនេះ។

**មាត្រា ១៧២.-**

រដ្ឋបាលស្រុកនីមួយៗ ត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈនៅមុខសាលាស្រុករបស់ខ្លួន ដែលសាធារណជនអាចពិនិត្យមើលបានដោយងាយស្រួល។

ក្តារព័ត៌មានសាធារណៈខាងលើនេះ ត្រូវបានសរសេរឬបានបិទផ្សាយសេចក្តីជូនដំណឹងជាផ្លូវការដល់សាធារណជន។

ការសរសេរនិងការបិទផ្សាយខាងលើនេះ ត្រូវរក្សាទុកឱ្យបានយ៉ាងតិចដប់(១០)ថ្ងៃ។

ក្រៅពីក្តារព័ត៌មានសាធារណៈនៅមុខសាលាស្រុក ក្រុមប្រឹក្សាស្រុកនីមួយៗត្រូវរៀបចំក្តារព័ត៌មានសាធារណៈនៅទីសាធារណៈដទៃទៀតក្នុងស្រុករបស់ខ្លួនតាមការចាំបាច់។

ក្រៅពីការរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈ ក្រុមប្រឹក្សាស្រុកនីមួយៗត្រូវស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ដើម្បីជូនដំណឹងអំពីកិច្ចការនានានៃរដ្ឋបាលរបស់ខ្លួនដល់ប្រជាពលរដ្ឋ។

**មាត្រា ១៧៣.-**

សាលាស្រុកនីមួយៗ ត្រូវមានការិយាល័យចំណុះមួយចំនួន។

ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធានការិយាល័យមួយ(០១)រូប អមដោយអនុប្រធានការិយាល័យមួយ(០១)រូបជាជំនួយការ ដែលត្រូវតែងតាំងឡើងតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រធានការិយាល័យនីមួយៗ ត្រូវទទួលខុសត្រូវនិងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលាស្រុក។

ការិយាល័យខាងលើនេះ ជាសេនាធិការរបស់ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុក ក្នុងកិច្ចសហការជាមួយស្ថាប័ន អង្គភាពជំនាញតាមវិស័យ លើកិច្ចការសំខាន់ៗដូចខាងក្រោម :

- ការងាររដ្ឋបាលលិខិតស្នាម
- ការងារអគ្រានុកូលដ្ឋាន
- ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស
- ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ
- ការគាំទ្រឃុំ សង្កាត់ ការសម្របសម្រួលកិច្ចសហប្រតិបត្តិការអភិវឌ្ឍនិងការផ្តល់សេវារវាងឃុំ សង្កាត់ និងឃុំ សង្កាត់ ព្រមទាំងរវាងស្រុកនិងឃុំ សង្កាត់
- ការងារហិរញ្ញវត្ថុ ថវិកា និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ស្រុក
- ការងារដីធ្លីនិងសំណង់
- ការងារសណ្តាប់ធ្នាប់សាធារណៈ កិច្ចការច្បាប់ សិទ្ធិមនុស្ស និងយេនឌ័រ
- ការអនុវត្តមុខងារ ភារកិច្ចនានាដែលបានប្រគល់ឬបានធ្វើប្រតិភូកម្ម
- កិច្ចការដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ។

ផ្អែកលើតួនាទីខាងលើនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការសម្រេចរបស់ គ.ជ.អ.ប.ត្រូវចេញប្រកាសស្តីពីការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យនានាចំណុះសាលាស្រុក រួមទាំងល័ក្ខខ័ណ្ឌនៃការរៀបចំមន្ត្រី បុគ្គលិកនៃការិយាល័យទាំងនោះ ។

## ជំពូកទី៥

## ការគាំទ្រនិងទំនាក់ទំនងរវាងរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងទំនាក់ទំនងរវាងរដ្ឋបាលទាំងនេះជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល

### ផ្នែកទី១

### ទំនាក់ទំនងរវាងរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំនិងសង្កាត់

**មាត្រា ១៧៤.-**

ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំនិងក្រុមប្រឹក្សាសង្កាត់ មានសិទ្ធិអំណាចរៀងៗខ្លួន ក្នុងការធ្វើសេចក្តីសម្រេចនិងការចាត់ចែងមុខងារ ភារកិច្ច និងធនធាននានាដែលបានប្រគល់ឬបានធ្វើប្រតិភូកម្ម ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងត្រូវធានាធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន ។

**មាត្រា ១៧៥.-**

ក្នុងការធ្វើសេចក្តីសម្រេចនិងការចាត់ចែងមុខងារ ភារកិច្ច និងធនធាននានាដែលបានប្រគល់ឬបានធ្វើប្រតិភូកម្ម ក្រុមប្រឹក្សាតាមប្រភេទនីមួយៗត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងការសម្រេចរបស់ គ.ជ.អ.ប. ដែលទាក់ទងដល់មុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាតាមប្រភេទនីមួយៗនោះ ។

**មាត្រា ១៧៦.-**

ដើម្បីធ្វើសេចក្តីសម្រេចនិងការចាត់ចែងមុខងារ ភារកិច្ចដែលមានទំនាក់ទំនងរវាងក្រុមប្រឹក្សាពីរឬច្រើនក្រុមប្រឹក្សាត្រូវធានាឱ្យមានការពិគ្រោះយោបល់ ការសម្របសម្រួល និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការនៅក្នុងចំណោមក្រុមប្រឹក្សាដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ១៧៧.-**

ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ដែលមានព្រំប្រទល់ជាប់គ្នា ត្រូវធ្វើទំនាក់ទំនងកិច្ចសហប្រតិបត្តិការនិងការពិគ្រោះយោបល់និងការសម្របសម្រួលជាមួយគ្នាលើមុខងារភារកិច្ចមួយឬច្រើននិងបញ្ហានានាដែលមានការពាក់ព័ន្ធគ្នា ។

**មាត្រា ១៧៨.-**

ក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនិងគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង ។

**មាត្រា ១៧៩.-**

ដើម្បីធានាឱ្យក្រុមប្រឹក្សាក្រុងលើកកម្ពស់ក្នុងការបង្កើត ការជំរុញនិងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្រុមប្រឹក្សាសង្កាត់ក្នុងក្រុងត្រូវទទួលខុសត្រូវ :

- ក្នុងការផ្តល់យោបល់និងការពិគ្រោះយោបល់ ជាមួយក្រុមប្រឹក្សាក្រុង ដើម្បីធានាថា ក្រុមប្រឹក្សាក្រុងនៅតែឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនិងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចក្រុងនិងតាមសង្កាត់នីមួយៗក្នុងក្រុង
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាក្រុង អំពីតម្រូវការនានារបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបានដោយសមត្ថភាពនិងធនធានដែលខ្លួនមាន
- អនុវត្តមុខងារ ភារកិច្ចទាំងឡាយដែលបានធ្វើប្រតិភូកម្មដោយក្រុមប្រឹក្សាក្រុង ។

**មាត្រា ១៨០.-**

ក្រុមប្រឹក្សាក្រុង ត្រូវរៀបចំឱ្យមានការពិគ្រោះយោបល់សមស្របជាមួយក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង ដើម្បី :

- ធ្វើការសម្របសម្រួលឱ្យមានកិច្ចសហប្រតិបត្តិការក្នុងចំណោមសង្កាត់នានាក្នុងក្រុង ដើម្បីលើកកម្ពស់ការឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ
- ប្រមូលផ្តុំសេចក្តីត្រូវការនានារបស់ប្រជាពលរដ្ឋ ដែលលើកឡើងដោយក្រុមប្រឹក្សាសង្កាត់ ហើយដែលក្រុមប្រឹក្សាសង្កាត់មិនអាចឆ្លើយតបបាន ដើម្បីពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ខិតខំឆ្លើយតបតម្រូវការទាំងនោះ
- គាំទ្រសមត្ថភាពចាំបាច់ដល់ក្រុមប្រឹក្សាសង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង មានសមត្ថភាពទទួលបាននូវមុខងារ ភារកិច្ច ដែលត្រូវធ្វើប្រតិភូកម្មកាន់តែច្រើនថែមទៀតពីក្រុមប្រឹក្សាក្រុង ។

**មាត្រា ១៨១.-**

ក្រុមប្រឹក្សាក្រុង ត្រូវធានាធ្វើប្រតិភូកម្មឱ្យបានសមស្របនូវមុខងារ ភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ក្នុងក្រុងរបស់ខ្លួន។

ដើម្បីធ្វើប្រតិភូកម្មមុខងារ ភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង ក្រុមប្រឹក្សាក្រុងត្រូវធ្វើការពិគ្រោះយោបល់ និងការសម្របសម្រួលឱ្យបានសមស្របជាមួយក្រុមប្រឹក្សាសង្កាត់ ដើម្បីរួមគ្នាពិចារណាអំពីភាពសមហេតុផល និងប្រសិទ្ធភាពនៃមុខងារ ភារកិច្ច ដែលគួររក្សាទុកជាមុខងារ ភារកិច្ចរបស់ក្រុងឬគួរធ្វើប្រតិភូកម្មទៅក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង។

**មាត្រា ១៨២.-**

ក្រុមប្រឹក្សាក្រុង ត្រូវធានាផ្តល់មធ្យោបាយ សម្ភារៈ ធនធាននានា រួមទាំងធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សាសង្កាត់និងបុគ្គលិកក្រុមប្រឹក្សាសង្កាត់ ដើម្បីអនុវត្តមុខងារភារកិច្ចដែលបានធ្វើប្រតិភូកម្មពីក្រុមប្រឹក្សាក្រុង ទៅក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង។

**មាត្រា ១៨៣.-**

ក្រុមប្រឹក្សាក្រុង ត្រូវធ្វើការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់ ដើម្បីធានាថាក្រុមប្រឹក្សាសង្កាត់អនុវត្តមុខងារភារកិច្ច ក្នុងក្របខ័ណ្ឌនៃអំណាចដែលបានធ្វើប្រតិភូកម្មឱ្យ លើមូលដ្ឋាននៃការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ហើយត្រូវធានាថាក្រុមប្រឹក្សាសង្កាត់បានអនុវត្តមុខងារ ភារកិច្ចនេះ ក្នុងការឆ្លើយតបបានយ៉ាងប្រសើរបំផុតនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

**មាត្រា ១៨៤.-**

ក្រុមប្រឹក្សាស្រុក ត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងស្រុក អំពីជម្រើស សេចក្តីសម្រេច និងការអនុវត្តរបស់ខ្លួន ព្រមទាំងផលប៉ះពាល់នៃជម្រើស សេចក្តីសម្រេចនិងការអនុវត្តសេចក្តីសម្រេចទាំងនោះ។

ផ្អែកលើគោលការណ៍ខាងលើនេះ ក្រុមប្រឹក្សាស្រុកត្រូវរៀបចំទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការឱ្យបានសមស្របជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុករបស់ខ្លួន ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា១១៥ មាត្រា១១៦ មាត្រា១១៧ មាត្រា១១៨ មាត្រា១១៩ មាត្រា១២០ មាត្រា១២១ មាត្រា១២២ មាត្រា១២៣ មាត្រា១២៤ មាត្រា១២៥ និងមាត្រា១២៦នៃអនុក្រឹត្យនេះ។

**មាត្រា ១៨៥.-**

ក្រុមប្រឹក្សាខេត្ត ត្រូវសហការជាមួយក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុកក្នុងខេត្តរបស់ខ្លួន ដើម្បីពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំនិងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្តរបស់ខ្លួន ក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាឃុំនិងក្រុមប្រឹក្សាសង្កាត់។

ក្នុងទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការខាងលើនេះ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត ត្រូវទទួលខុសត្រូវ ៖

- ផ្តល់យោបល់ ពិគ្រោះយោបល់និងត្រួតពិនិត្យ ដើម្បីធានាថាក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកនៅតែឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាននិងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងខេត្ត
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុកអំពីតម្រូវការនានារបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាឃុំនិងក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបានដោយសមត្ថភាពនិងធនធានដែលខ្លួនមាន
- ធ្វើសហប្រតិបត្តិការឱ្យបានពេញលេញជាមួយក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុកក្នុងការលើកកម្ពស់ការផ្តល់សេវានិងការអភិវឌ្ឍនៅមូលដ្ឋាន ។

**មាត្រា ១៨៦.-**

គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក មេឃុំ និងចៅសង្កាត់ មានភារកិច្ចអនុវត្តកិច្ចការប្រចាំថ្ងៃក្នុងការទំនាក់ទំនងទៅវិញទៅមករវាងខេត្ត ក្រុង ស្រុក ឃុំនិងសង្កាត់ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

## ផ្នែកទី២

## ទំនាក់ទំនងរវាងរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ជាមួយក្រសួង ស្ថាប័ននានា និងការគាំទ្ររបស់រដ្ឋបាលខេត្តចំពោះក្រុង ស្រុក ឃុំ សង្កាត់

**មាត្រា ១៨៧.-**

ក្រសួង ស្ថាប័ននានាត្រូវចូលរួម និងគាំទ្រយ៉ាងសកម្មចំពោះដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការនិងវិសហមជ្ឈការនៅខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ស្របតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ១៨៨.-**

ក្រសួង ស្ថាប័ននានាត្រូវមានផែនការសកម្មភាពដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ។

**មាត្រា ១៨៩.-**

ក្រសួង ស្ថាប័ននីមួយៗ ត្រូវធ្វើការប្រគល់និងធ្វើប្រតិភូកម្មមុខងារ ភារកិច្ចសមស្រប ដោយភ្ជាប់ជាមួយនូវធនធានហិរញ្ញវត្ថុ បុគ្គលិក និងសមត្ថភាពទៅឱ្យក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី២ ផ្នែកទី៣ ផ្នែកទី៤ និងផ្នែកទី៥ ជំពូកទី៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងបទប្បញ្ញត្តិនានាដូចមានចែងក្នុងអនុក្រឹត្យនេះ ។

**មាត្រា ១៩០.-**

ក្រសួង ស្ថាប័ននានា ត្រូវធ្វើការពិនិត្យឡើងវិញនូវច្បាប់ លិខិតបទដ្ឋានគតិយុត្តនិងកម្មវិធីនានាពាក់ព័ន្ធដល់វិស័យដែលខ្លួនទទួលខុសត្រូវ ដើម្បីស្នើធ្វើវិសោធនកម្មនិងកែសម្រួលឱ្យមានសង្គតិភាពជាមួយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ១៩១.-**

ក្រសួង ស្ថាប័ននានា ត្រូវទទួលខុសត្រូវក្នុងការកំណត់គោលនយោបាយសម្រាប់វិស័យរបស់ខ្លួនទូទាំងប្រទេស ការដាក់ចេញលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់អំពីបែបបទ នីតិវិធីសម្រាប់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ អនុវត្តមុខងារដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាទាំងនេះ រួមទាំងការកំណត់នូវបទដ្ឋានជាតិសម្រាប់សុវត្ថិភាពនិងគុណភាព ព្រមទាំងកំណត់យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាពាក់ព័ន្ធ ដើម្បីអនុវត្តមុខងារដែលបានធ្វើការប្រគល់ឬធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាពាក់ព័ន្ធ ។

លិខិតបទដ្ឋានគតិយុត្តដែលកំណត់អំពីបែបបទ នីតិវិធី ការកំណត់នូវបទដ្ឋានជាតិសម្រាប់សុវត្ថិភាពនិងគុណភាពខាងលើនេះ ត្រូវផ្អែកតាមគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ។

**មាត្រា ១៩២.-**

ក្រសួង ស្ថាប័ននានា ត្រូវសហការសម្របសម្រួលជាមួយ គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ ដើម្បីអនុវត្តបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៨៧ មាត្រា១៨៨ មាត្រា១៨៩ មាត្រា១៩០និងមាត្រា១៩១នៃអនុក្រឹត្យនេះ និងការងារដទៃៗទៀត ដែលពាក់ព័ន្ធដល់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ។

**មាត្រា ១៩៣.-**

ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវស្ថិតក្នុងក្របខ័ណ្ឌនៃអំណាចប្រតិបត្តិរបស់ជាតិ ។

ក្នុងក្របខ័ណ្ឌនៃអំណាចប្រតិបត្តិរបស់ជាតិ រាជរដ្ឋាភិបាលមានសិទ្ធិណែនាំនិងត្រួតពិនិត្យនីត្យានុកូលភាពនៃការសម្រេចនិងការធ្វើសកម្មភាពរបស់ក្រុមប្រឹក្សា ដើម្បីធានាឱ្យបានថាក្រុមប្រឹក្សាគោរពយ៉ាងត្រឹមត្រូវនូវរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងគោលនយោបាយរបស់ជាតិ ។

**មាត្រា ១៩៤.-**

ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាខេត្តត្រូវបានទទួលប្រតិភូកម្មដោយអនុក្រឹត្យនេះពីរាជរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រ ការសម្របសម្រួលនិងការធ្វើសហប្រតិបត្តិការជាមួយរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីរួមគ្នាសម្រេចឱ្យបាននូវគោលនយោបាយរបស់ជាតិ ។

**មាត្រា ១៩៥.-**

ក្រុមប្រឹក្សាខេត្តត្រូវទំនាក់ទំនងសហប្រតិបត្តិការនិងពិគ្រោះយោបល់ជាមួយ គ.ជ.អ.ប. និងក្រសួង ស្ថាប័ននានា ក្នុងការងារបែងចែកមុខងារ ធនធាន ទ្រព្យសម្បត្តិ ការគ្រប់គ្រងនិងការកៀរគរចំណូល ព្រមទាំងការពិនិត្យនិងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក រវាងថ្នាក់ជាតិ និងរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំនិងសង្កាត់ក្នុងខេត្ត ។

ក្រុមប្រឹក្សាខេត្តត្រូវធានាឱ្យមានការពិគ្រោះយោបល់សមស្រប ជាមួយរដ្ឋបាលក្រុង ស្រុក ឃុំនិងសង្កាត់ក្នុងខេត្ត សម្រាប់ជាមូលដ្ឋានក្នុងការពិគ្រោះពិភាក្សាជាមួយ គ.ជ.អ.ប. និងក្រសួង ស្ថាប័ននានាអំពីការងារខាងលើនេះ ។

ផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប. ក្រុមប្រឹក្សាខេត្តត្រូវធានាធ្វើការសម្របសម្រួលជាមួយរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំនិងរដ្ឋបាលសង្កាត់ក្នុងខេត្ត ដើម្បីបែងចែកមុខងារ ធនធាន ទ្រព្យសម្បត្តិ ការគ្រប់គ្រងនិងការកៀរគរចំណូល ព្រមទាំងបុគ្គលិក ឱ្យបានសមស្របតាមស្ថានភាពជាក់ស្តែងនៃតំបន់នីមួយៗ រួមទាំងតំបន់ប្រជុំជននិងតំបន់ជនបទក្នុងខេត្ត ។

ក្រុមប្រឹក្សាខេត្តត្រូវធានាថា រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ក្នុងខេត្ត បំពេញមុខងារ ភារកិច្ចដែលបានប្រគល់ឬបានធ្វើប្រតិភូកម្ម ឱ្យស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងគោលនយោបាយរបស់ជាតិ ។

**មាត្រា ១៩៦.-**

ក្រុមប្រឹក្សាខេត្តត្រូវបានទទួលការធ្វើប្រតិភូកម្មអំណាចក្នុងនាមរាជរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រនិងការត្រួតពិនិត្យនីត្យានុកូលភាពលើសេចក្តីសម្រេច និងសកម្មភាពរបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំនិងរដ្ឋបាលសង្កាត់ ដើម្បីធានាថារដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំនិងរដ្ឋបាលសង្កាត់ បំពេញមុខងារ ភារកិច្ចដែលបានប្រគល់ឬបានធ្វើប្រតិភូកម្ម ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងស្របតាមគោលនយោបាយរបស់ជាតិ ។

ការធ្វើប្រតិភូកម្មនេះរួមមាន :

- ការវាយតម្លៃនិងការរៀបចំយុទ្ធសាស្ត្រសមស្របសម្រាប់ផ្តល់ការគាំទ្រខាងសមត្ថភាពដល់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ព្រមទាំងមន្ត្រីបុគ្គលិកនៃក្រុមប្រឹក្សាទាំងនេះ
- ការណែនាំនិងសម្របសម្រួល គាំទ្រដល់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ក្នុងការអនុវត្តមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ឱ្យស្របទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងគោលនយោបាយរបស់ជាតិ
- ត្រូវធានាថាក្រុង ស្រុកបានធ្វើការគាំទ្រយ៉ាងត្រឹមត្រូវដល់សង្កាត់ក្នុងក្រុងនិងឃុំ សង្កាត់ក្នុងស្រុក ។

ក្រុមប្រឹក្សាខេត្តត្រូវបំពេញតួនាទីខាងលើនេះ លើមូលដ្ឋាននៃការធានាស្វ័យភាពរបស់ក្រុង ស្រុក ឃុំនិងសង្កាត់ ឱ្យស្របតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យនេះ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេចរបស់ គ.ជ.អ.ប. ។

ក្រុមប្រឹក្សាខេត្តត្រូវធ្វើប្រតិភូកម្មអំពីការគាំទ្រនិងការត្រួតពិនិត្យនីត្យានុកូលភាពនេះដល់គណៈអភិបាលខេត្ត

ដើម្បីអនុវត្តកិច្ចការប្រចាំថ្ងៃ។ ក្នុងការអនុវត្តការងារប្រចាំថ្ងៃ គណៈអភិបាលគឺជាខ្សែរយៈទំនាក់ទំនងទៅវិញទៅមក រវាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ជាមួយរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំនិងសង្កាត់ ព្រមទាំងការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ឃុំនិងសង្កាត់ក្នុងខេត្ត។

គណៈអភិបាលត្រូវស្នើសុំគោលការណ៍ណែនាំនិងធ្វើសេចក្តីរាយការណ៍ អំពីការអនុវត្តតួនាទី ភារកិច្ចខាងលើនេះ រៀងរាល់កិច្ចប្រជុំសាមញ្ញនៃក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាខេត្តអាចកោះប្រជុំវិសាមញ្ញ ដើម្បីពិនិត្យ ពិភាក្សាអំពីការគាំទ្រនិងការធ្វើប្រតិភូកម្មខាងលើនេះ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប.ត្រូវចេញប្រកាសដើម្បីកំណត់អំពីគោលការណ៍ និងនីតិវិធីនានាពាក់ព័ន្ធនឹងការធ្វើប្រតិភូកម្មខាងលើនេះ។

**មាត្រា ១៩៧.-**

អភិបាលខេត្តក្នុងនាមគណៈអភិបាលនិងក្រុមប្រឹក្សារបស់ខ្លួន ជាអ្នកចុះហត្ថលេខាលើលិខិតបទដ្ឋានរដ្ឋបាលនានា ដើម្បីបម្រើឱ្យទំនាក់ទំនងដូចបានកំណត់ក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ។

ឯកសារ លិខិតស្នាមពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលទៅរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំនិងសង្កាត់ ត្រូវបញ្ជូនទៅសាលាខេត្ត។

អភិបាលខេត្ត ត្រូវធានាបែងចែក និងបញ្ជូនឯកសារ លិខិតស្នាមខាងលើនេះឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាដល់ថ្នាក់រដ្ឋបាល ឬបុគ្គលដែលពាក់ព័ន្ធ។

**មាត្រា ១៩៨.-**

ក្រសួង ស្ថាប័ននានា អាចធ្វើទំនាក់ទំនងនិងកិច្ចសហការដោយផ្ទាល់ជាមួយរដ្ឋបាលក្រុង ឬរដ្ឋបាលស្រុក ឬរដ្ឋបាលឃុំ ឬរដ្ឋបាលសង្កាត់ តាមការចាំបាច់ ប៉ុន្តែត្រូវជូនដំណឹងដល់រដ្ឋបាលខេត្ត។

**មាត្រា ១៩៩.-**

ក្នុងករណីមានភាពមិនចុះសម្រុងគ្នារវាងរដ្ឋបាលខេត្ត ជាមួយរដ្ឋបាលក្រុង ឬជាមួយរដ្ឋបាលស្រុក ឬជាមួយរដ្ឋបាលឃុំ ឬជាមួយរដ្ឋបាលសង្កាត់ ឬរវាងរដ្ឋបាលណាមួយក្នុងចំណោមរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់ ក្រសួងមហាផ្ទៃ ត្រូវធ្វើការសម្របសម្រួលដោះស្រាយស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ២០០.-**

ក្នុងករណីមិនចុះសម្រុងគ្នារវាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលជាមួយក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត គ.ជ.អ.ប.ត្រូវសម្របសម្រួលដោះស្រាយ ផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

ក្នុងករណីមិនអាចសម្របសម្រួលដោះស្រាយបាន គ.ជ.អ.ប. ត្រូវធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា ២០១.-**

ផ្អែកតាមបទប្បញ្ញត្តិនានានៃអនុក្រឹត្យនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើសេចក្ដីណែនាំ ដើម្បីកំណត់អំពីដំណាក់កាល និងបែបបទ នីតិវិធីនានាក្នុងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ គោលការណ៍និងនីតិវិធីនានារបស់រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក ដើម្បីធានានូវនិរន្តរភាពនៃរដ្ឋបាលទាំងនោះ ។

ក្នុងពេលមិនទាន់មានការរៀបចំរចនាសម្ព័ន្ធនិងប្រព័ន្ធតាមស្មារតីនៃអនុក្រឹត្យនេះ រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុកត្រូវបន្តអនុវត្តនូវរចនាសម្ព័ន្ធនិងប្រព័ន្ធដែលមានបច្ចុប្បន្ន រហូតដល់មានការរៀបចំជាថ្មី ។

**មាត្រា ២០២.-**

ក្នុងពេលដែលរង់ចាំការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗបន្ថែមទៀតពីថ្នាក់ជាតិ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុងនិងក្រុមប្រឹក្សាស្រុក ត្រូវបន្តអនុវត្តនូវមុខងារ ភារកិច្ចដែលធ្លាប់បានអនុវត្តដោយរដ្ឋបាលរបស់ខ្លួន រហូតដល់មានការរៀបចំជាថ្មី ។

ក្រុមប្រឹក្សាត្រូវធានាចាត់ចែងមុខងារ ភារកិច្ចទាំងនេះ ដោយផ្អែកតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាននិងផ្អែកតាមតួនាទី ភារកិច្ច របៀបរបបការងារដូចមានចែងក្នុងអនុក្រឹត្យនេះ ។

គ.ជ.អ.ប.ត្រូវចាត់ចែងជាបន្ទាន់ ក្នុងការពិនិត្យមុខងារ ភារកិច្ចខាងលើនេះ ហើយត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីធ្វើការប្រគល់ឬធ្វើប្រតិភូកម្មមុខងារ ភារកិច្ចទាំងនោះឱ្យបានត្រឹមត្រូវដល់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក តាមគោលការណ៍នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យនេះ ។

**មាត្រា ២០៣.-**

ក្នុងពេលដែលមិនទាន់មានច្បាប់ស្ដីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវបន្តអនុវត្តតាមអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្ដីពីមូលនិធិឃុំ សង្កាត់ ។

**មាត្រា ២០៤.-**

ក្នុងពេលរង់ចាំការផ្ទេរមុខងារ ភារកិច្ចដល់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក គ.ជ.អ.ប. ត្រូវធានាឱ្យបានថា ក្រសួង ស្ថាប័ន បានធ្វើសមាហរណកម្មផែនការអភិវឌ្ឍនិងថវិការបស់ខ្លួនទៅក្នុងផែនការអភិវឌ្ឍនិងថវិការបស់ក្រុមប្រឹក្សាខេត្តនិងក្រុមប្រឹក្សាប្រភេទផ្សេងៗទៀតនៅក្នុងខេត្ត ។

**មាត្រា ២០៥.-**

ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ត្រូវធានាបន្តគ្រប់គ្រង ចាត់ចែងនិងអនុវត្តដីកា សេចក្ដីសម្រេច លិខិតបទដ្ឋាន កិច្ចសន្យា កិច្ចព្រមព្រៀង ការងារ ទ្រព្យសម្បត្តិ ចំណូល និងប្រាក់ទាំងអស់ ដែលបានគ្រប់គ្រង ចាត់ចែង និងអនុវត្តដោយឬក្នុងនាមរដ្ឋបាលខេត្ត ក្រុង ស្រុក ឱ្យស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាជា

ធរមាន។

**មាត្រា ២០៦.-**

ផ្អែកតាមរចនាសម្ព័ន្ធរបស់សាលាខេត្ត សាលាក្រុង និងសាលាស្រុក ដូចមានចែងក្នុងមាត្រា៩៥ មាត្រា៩៧ មាត្រា៩៨ មាត្រា១១២និងមាត្រា១៧៣នៃអនុក្រឹត្យនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធានាធ្វើសមាហរណកម្ម អង្គភាព មន្ត្រី បុគ្គលិកដែលស្ថិតនៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលស៊ីវិលនៃក្រសួងមហាផ្ទៃ ដែលកំពុងបម្រើការងារនៅក្នុង សាលាខេត្ត សាលាក្រុងនិងសាលាស្រុកបច្ចុប្បន្ន ទៅក្នុងរចនាសម្ព័ន្ធថ្មីនេះ។

ក្នុងពេលមិនទាន់មានលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ការកំណត់ឋានន្តរសក្តិ ថ្នាក់ និងមុខតំណែង ត្រូវផ្អែកតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៅនឹងមន្ត្រីរាជការ ស៊ីវិល។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការធ្វើសមាហរណកម្មនេះ ដើម្បីធានានូវ អត្ថប្រយោជន៍ មុខតំណែងនិងឋានន្តរសក្តិរបស់មន្ត្រី បុគ្គលិកដែលកំពុងបម្រើការងារនៅក្នុងអង្គភាពនានានៃសាលាខេត្ត សាលាក្រុងនិងសាលាស្រុក។

ក្នុងករណីមន្ត្រី បុគ្គលិកនៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលស៊ីវិលក្រសួងមហាផ្ទៃ ដែលកំពុងបម្រើការងារនៅសាលា ខេត្ត សាលាក្រុងនិងសាលាស្រុក បានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីដែលកំណត់ដោយអនុក្រឹត្យនេះរួចហើយ ប៉ុន្តែនៅតែពុំអាចបំពេញបានតាមតម្រូវការនៃរចនាសម្ព័ន្ធថ្មីនេះ ក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត ក្រុមប្រឹក្សានិង គណៈអភិបាលក្រុង ក្រុមប្រឹក្សានិងគណៈអភិបាលស្រុក អាចពិនិត្យនិងជ្រើសរើសមន្ត្រីរាជការស៊ីវិលក្រៅពីមន្ត្រី ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលស៊ីវិលក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិសមស្រប ដើម្បីស្នើសុំតែងតាំងមុខតំណែងដែល ត្រូវបំពេញបន្ថែមនេះ។

មន្ត្រី បុគ្គលិកដែលបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីដែលកំណត់ដោយអនុក្រឹត្យនេះ និងបុគ្គលិកជាប់ កិច្ចសន្យា កម្មករអណ្តែតដែលកំពុងបម្រើការងារក្នុងសាលាខេត្ត សាលាក្រុង និងសាលាស្រុក ត្រូវស្ថិតក្រោមការ គ្រប់គ្រងនិងចាត់ចែងដោយក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង ក្រុមប្រឹក្សានិង គណៈអភិបាលស្រុក។ ក្នុងពេលមិនទាន់មានលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ គណៈអភិបាល ត្រូវស្នើសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួនពាក់ព័ន្ធនឹងការតែងតាំង ការផ្លាស់ប្តូរ ការដំឡើងឋានន្តរសក្តិ ការដំឡើងថ្នាក់ ការរៀបចំបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំរបស់មន្ត្រី បុគ្គលិក និងការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា កម្មករ អណ្តែតនិងទីប្រឹក្សាបច្ចេកទេស។ ផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សា អភិបាលត្រូវធ្វើសំណើមករដ្ឋមន្ត្រីក្រសួង មហាផ្ទៃ ដើម្បីរៀបចំនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ ការដំឡើងឋានន្តរសក្តិនិងការដំឡើងថ្នាក់ឱ្យស្របតាមច្បាប់និង លិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការតែងតាំង ការ ផ្លាស់ប្តូរ ការដំឡើងឋានន្តរសក្តិ ការដំឡើងថ្នាក់ ការរៀបចំបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនិងការជ្រើសរើសបុគ្គលិក ជាប់កិច្ចសន្យា កម្មករអណ្តែតនិងទីប្រឹក្សាបច្ចេកទេសខាងលើនេះ។

**មាត្រា ២០៧.-**

នៅពេលមិនទាន់មានការកែសម្រួលឬធ្វើវិសោធនកម្មព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ដើម្បីកំណត់អំពីប្រាក់បំណាច់មុខងារសម្រាប់មុខតំណែងដែលមាននៅក្នុងរចនាសម្ព័ន្ធសាលាខេត្ត សាលាក្រុង សាលាស្រុកតាមស្មារតីនៃអនុក្រឹត្យនេះ មុខតំណែងនាយករងរដ្ឋបាលសាលាខេត្ត នាយករងរដ្ឋបាលសាលាក្រុង នាយករងរដ្ឋបាលសាលាស្រុក នាយកទីចាត់ការ នាយករងទីចាត់ការ ប្រធាននិងអនុប្រធានការិយាល័យនៃសាលាខេត្ត ប្រធាននិងអនុប្រធានការិយាល័យនៃសាលាក្រុង សាលាស្រុក ត្រូវបានកំណត់ដូចខាងក្រោម :

- នាយករងរដ្ឋបាលសាលាខេត្ត មានប្រាក់បំណាច់មុខងារស្មើនឹងប្រធានមន្ទីរជំនាញខេត្ត
- នាយកទីចាត់ការ មានប្រាក់បំណាច់មុខងារស្មើនឹងអនុប្រធានមន្ទីរជំនាញខេត្ត
- នាយករងទីចាត់ការ មានប្រាក់បំណាច់មុខងារស្មើនឹងប្រធានការិយាល័យនៃមន្ទីរជំនាញខេត្ត
- ប្រធាននិងអនុប្រធានការិយាល័យសាលាខេត្ត មានប្រាក់បំណាច់មុខងារស្មើនឹងប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរជំនាញខេត្ត
- នាយករងរដ្ឋបាលសាលាក្រុង សាលាស្រុក មានប្រាក់បំណាច់មុខងារស្មើនឹងប្រធានការិយាល័យជំនាញខេត្ត
- ប្រធាននិងអនុប្រធានការិយាល័យសាលាក្រុង សាលាស្រុក មានប្រាក់បំណាច់មុខងារស្មើនឹងប្រធាននិងអនុប្រធានការិយាល័យជំនាញស្រុក ។

**មាត្រា ២០៨.-**

ការិយាល័យច្រកចេញចូលតែមួយនិងការិយាល័យប្រជាពលរដ្ឋ ដែលតម្រូវឱ្យបង្កើតឡើងដោយសេចក្តីសម្រេចលេខ៤៧ ស.ស.រ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៣ និងគោលការណ៍ស្តីពីការបន្តរៀបចំការិយាល័យទាំងនេះ ត្រូវបានប្រើប្រាស់ជារចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងនៃថ្នាក់រដ្ឋបាលដែលពាក់ព័ន្ធ ។

គណៈអភិបាលនៃថ្នាក់រដ្ឋបាលដែលពាក់ព័ន្ធ ត្រូវចាត់ចែងការិយាល័យច្រកចេញចូលតែមួយ ដោយធ្វើគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សារបស់ខ្លួន ។

**មាត្រា ២០៩.-**

ក្នុងករណីមិនទាន់មានសេចក្តីណែនាំស្តីពីការសុំច្បាប់ឈប់សម្រាករបស់គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក បុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត បុគ្គលិករបស់ក្រុមប្រឹក្សាក្រុងនិងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក បែបបទ និងនីតិវិធីនៃការសុំច្បាប់ឈប់សម្រាក ត្រូវអនុវត្តតាមសេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ។

**មាត្រា ២១០.-**

គ.ជ.អ.ប. ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីធ្វើសមាហរណកម្មរចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត មកក្នុងរចនាសម្ព័ន្ធរដ្ឋបាលខេត្ត ស្របតាមស្មារតីនៃអនុក្រឹត្យនេះ ។

ក្នុងការសិក្សាខាងលើនេះ គ.ជ.អ.ប. ត្រូវធ្វើការពិគ្រោះយោបល់និងធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំយុទ្ធសាស្ត្រ និងដំណាក់កាលសមស្របក្នុងដំណើរការធ្វើសមាហរណកម្មនេះ ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា ២១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ធ្នូ ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២១៣៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌ នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញនិងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ។

**មាត្រា ២.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ ត្រូវរៀបចំឱ្យមានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរៀងៗខ្លួន ដើម្បីជួយសិក្សានិងផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន លើបញ្ហាទាក់ទងនឹងការងារផែនការ ថវិកា ការសម្របសម្រួលកិច្ចការនានាជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងក្រុមប្រឹក្សាប្រភេទផ្សេងទៀត និងបញ្ហាទាក់ទងនឹងមុខងារ ធនធានដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សារាជធានីនិងក្រុមប្រឹក្សាខណ្ឌ។

## ជំពូកទី២

## គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ

### ផ្នែកទី១

### សមាសភាព និង តួនាទី ភារកិច្ច

**មាត្រា ៣.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី មានសមាសភាពដូចខាងក្រោម :

- អភិបាលរាជធានី ជាប្រធាន
- អភិបាលរងរាជធានី០១រូប ជាអនុប្រធាន
- នាយករដ្ឋបាលសាលារាជធានី ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សារាជធានីយ៉ាងតិច០២រូប ជាសមាជិក
- ប្រធានមន្ទីរ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅរាជធានី ជាសមាជិក
- នាយកទីចាត់ការទាំងអស់របស់សាលារាជធានី ជាសមាជិក

- អភិបាលខណ្ឌទាំងអស់នៅក្នុងរាជធានី ជាសមាជិក
- តំណាងសមាគមក្រុមប្រឹក្សាសង្កាត់ប្រចាំរាជធានី០២រូប ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សារាជធានី០១រូប ជាសមាជិក

សមាសភាពអនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី ត្រូវស្នើដោយអភិបាលរាជធានី។

តំណាងសមាគមក្រុមប្រឹក្សាសង្កាត់ប្រចាំរាជធានី០២រូប ត្រូវចាត់តាំងឡើងដោយគណៈកម្មាធិការប្រតិបត្តិនៃសមាគមក្រុមប្រឹក្សាសង្កាត់ប្រចាំរាជធានី។ តំណាងទាំងពីររូបនេះត្រូវមានស្ត្រីមួយរូប។

ក្រុមប្រឹក្សារាជធានីត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សារាជធានី។

**មាត្រា ៤.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី មានតួនាទី ភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានីលើកិច្ចការសំខាន់ៗដូចខាងក្រោម :

**ក. ផែនការអភិវឌ្ឍនិងថវិកា**

- ការដាក់បញ្ចូលផែនការអភិវឌ្ឍនិងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលបានផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធ ដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សារាជធានី
- សេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងការធ្វើបច្ចុប្បន្នភាព
- សេចក្តីព្រាងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សារាជធានី
- សេចក្តីព្រាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងការធ្វើបច្ចុប្បន្នភាព
- ការងារហិរញ្ញវត្ថុនិងថវិការបស់ក្រុមប្រឹក្សារាជធានី
- សេចក្តីព្រាងគម្រោងវិភាជន៍មូលនិធិវិនិយោគរាជធានី ដើម្បីគាំទ្រដល់កម្មវិធីនានារបស់រាជធានី
- កៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធនានាដល់គម្រោងវិនិយោគរាជធានី
- របាយការណ៍រីកចម្រើននានា ទាក់ទងដល់ការងារផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ

និងថវិការបស់ក្រុមប្រឹក្សារាជធានី។

**ខ. សម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សារាជធានីជាមួយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានា**

- កិច្ចសហប្រតិបត្តិការ ការពិគ្រោះយោបល់ និងការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សារាជធានីជាមួយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន
- សម្របសម្រួលការផ្តល់សេវានិងការអភិវឌ្ឍដែលផ្តល់ដោយក្រសួង ស្ថាប័ន ឬដោយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន ដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋាន
- ការសម្របសម្រួលភាពមិនចុះសម្រុងគ្នារវាងកិច្ចការរបស់ក្រុមប្រឹក្សារាជធានី ជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញនានា
- ការផ្តល់អនុសាសន៍ដល់ក្រសួង ស្ថាប័ននានា ដើម្បីកែលម្អការផ្តល់សេវា និងការអភិវឌ្ឍ ស្របតាមតម្រូវការរបស់មូលដ្ឋាន។

**គ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពរាជធានី**

- ការរៀបចំយន្តការពិគ្រោះយោបល់និងការចូលរួមក្នុងដំណើរការអនុវត្តការងារនៃរដ្ឋបាលឯកភាពរាជធានី
- ការរៀបចំប្រព័ន្ធនិងនីតិវិធីបំពេញការងារ ព្រមទាំងទំនាក់ទំនងរបស់ទីចាត់ការនានានៃសាលារាជធានី
- ការដោះស្រាយនូវភាពមិនចុះសម្រុងគ្នាក្នុងការអនុវត្តការងាររបស់ទីចាត់ការនានានៃសាលារាជធានី។

**ឃ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សារាជធានីជាមួយក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់នៅក្នុងរាជធានី**

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សារាជធានីនិងក្រុមប្រឹក្សាខណ្ឌ ក្រុមបឹក្សាសង្កាត់ក្នុងរាជធានី
- ការឆ្លើយតបចំពោះអនុសាសន៍ សំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាខណ្ឌ ឬក្រុមប្រឹក្សាសង្កាត់ ក្នុងករណីដែលក្រុមប្រឹក្សាទាំងនោះមិនអាចដោះស្រាយបាន
- ការដោះស្រាយនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សារាជធានីនិងក្រុមប្រឹក្សាខណ្ឌ ឬ/និងក្រុមប្រឹក្សាសង្កាត់។

**ង. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សារាជធានីជាមួយក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត**

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សារាជធានីនិងក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នានិងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត

- ការសម្រុះសម្រួលនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សារាជធានីនិងក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នានិងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត។

**ច. ការងារទាក់ទងមុខងារនិងធនធាន**

- វិធានការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងធនធាន
- ការរៀបចំនូវលក្ខណសម្បត្តិនិងមធ្យោបាយដើម្បីទទួលនិងអនុវត្តមុខងារ និងធនធានថ្មីដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលរាជធានី
- ការផ្តួចផ្តើមស្នើឡើងនូវមុខងារនិងធនធានដែលគួរត្រូវបានប្រគល់ឬបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលរាជធានី
- ការផ្តួចផ្តើមអំពីការធ្វើប្រតិភូកម្មនូវមុខងារនិងធនធានដល់រដ្ឋបាលខណ្ឌនិងរដ្ឋបាលសង្កាត់
- ការវាយតម្លៃលើការអនុវត្តមុខងារនិងធនធាន ដែលស្ថិតក្រោមការទទួលខុសត្រូវនៃរដ្ឋបាលរាជធានី។

ក្រៅពីកិច្ចការខាងលើនេះ គណៈកម្មាធិការអាចទទួលអនុវត្តកិច្ចការផ្សេងទៀត តាមតម្រូវការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ឬតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សារបស់ខ្លួន។

## ផ្នែកទី២
## របៀបរបបការងារ

**មាត្រា ៥.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី ត្រូវជួបប្រជុំយ៉ាងតិចពីរខែម្តង។ កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការទាំងមូល។

សេចក្តីសម្រេចនៃកិច្ចប្រជុំអាចយកជាការបាន លុះត្រាមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។

ប្រធានគណៈកម្មាធិការជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការត្រូវមានកំណត់ហេតុ ដែលរៀបចំឡើងដោយនាយករដ្ឋបាលសាលារាជធានីនិងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

ផ្អែកតាមអនុក្រឹត្យនេះ គណៈកម្មាធិការអាចកំណត់អំពីរបៀបរបបប្រជុំ ការអនុម័តរបៀបរបបការងារជាក់ស្តែង និងការបែងចែកភារកិច្ចដល់សមាជិកគណៈកម្មាធិការតាមការចាំបាច់។

**មាត្រា ៦.-**

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការ ដែលជានាយករដ្ឋបាលសាលារាជធានី អភិបាលខណ្ឌ ប្រធានមន្ទីរ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលប្រចាំនៅរាជធានី នាយកទីចាត់ការនៃសាលារាជធានី អវត្តមាន សមាជិកនោះអាចចាត់តំណាងដែលមានសិទ្ធិសម្រេចជំនួសខ្លួន ឱ្យចូលរួមប្រជុំគណៈកម្មាធិការបាន។

**មាត្រា ៧.-**

អភិបាលរាជធានី អាចស្នើឱ្យអភិបាលរងរាជធានី មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធនានា ចូលរួមកិច្ចប្រជុំគណៈកម្មាធិការនេះតាមការចាំបាច់។ អភិបាលរងរាជធានី មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធទាំងនោះអាចផ្តល់យោបល់នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការបាន ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ។

**មាត្រា ៨.-**

កិច្ចប្រជុំនីមួយៗរបស់គណៈកម្មាធិការត្រូវមានរបៀបវារៈ ដែលបានត្រៀមរៀបចំជាមុន។

អភិបាលរាជធានី ដោយមាននាយករដ្ឋបាលសាលារាជធានីជាជំនួយការ ត្រូវរៀបចំរបៀបវារៈប្រជុំ ដោយផ្អែកតាម :

- តម្រូវការរបស់ក្រុមប្រឹក្សារាជធានី
- តម្រូវការរបស់គណៈអភិបាលរាជធានី
- តម្រូវការរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី
- សំណើរបស់សមាជិកយ៉ាងតិចមួយភាគបីនៃចំនួនសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី
- តម្រូវការនៃច្បាប់ឬលិខិតបទដ្ឋានគតិយុត្ត។

ផ្អែកតាមតម្រូវការ និងសំណើដូចខាងលើនេះ អភិបាលរាជធានីត្រូវពិគ្រោះយោបល់នៅក្នុងគណៈអភិបាលរបស់ខ្លួន ចាត់ឱ្យទីចាត់ការមួយ ឬច្រើនដែលពាក់ព័ន្ធនៃសាលារាជធានីដើម្បីសិក្សា រៀបចំឯកសារ បែបបទ នីតិវិធីនានា តាមរបៀបវារៈនីមួយៗ។

នាយករដ្ឋបាលសាលារាជធានីត្រូវដឹកនាំទីចាត់ការដែលពាក់ព័ន្ធនៅក្នុងសាលារាជធានីសិក្សា រៀបចំឯកសារ បែបបទ នីតិវិធីខាងលើនេះ ដោយសហការជាមួយមន្ទីរ អង្គភាព និងរដ្ឋបាលដែលពាក់ព័ន្ធនានាតាមការចាំបាច់។

**មាត្រា ៩.-**

ក្នុងការសិក្សា រៀបចំឯកសារ បែបបទ នីតិវិធីដូចមានចែងក្នុងមាត្រា៨ខាងលើនេះ នាយករដ្ឋបាលសាលារាជធានី ត្រូវផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីកាគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់

អនុវត្តច្បាប់ទាំងនេះ។

ក្រោយពេលរៀបចំឯកសារ បែបបទ នីតិវិធីតាមរបៀបវារៈនីមួយៗរួចហើយ នាយករដ្ឋបាលសាលារាជធានីត្រូវដាក់ជូនអភិបាលរាជធានី ដើម្បីពិនិត្យ និងរៀបចំកោះប្រជុំគណៈកម្មាធិការ។

**មាត្រា ១០.-**

អភិបាលរាជធានី ដោយមាននាយករដ្ឋបាលសាលារាជធានីជាជំនួយការ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការ ដើម្បីដាក់ជូនក្រុមប្រឹក្សារាជធានី ចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ឬដាក់ជូនគណៈអភិបាលរាជធានី ចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់គណៈអភិបាលរាជធានី។

**មាត្រា ១១.-**

ដើម្បីជួយសម្រួលដល់កិច្ចការរបស់ខ្លួន គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី អាចស្នើសុំបង្កើតអនុគណៈកម្មាធិការឬក្រុមការងារតាមការចាំបាច់ ឬតាមតម្រូវការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

សមាសភាពអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ អាចជ្រើសចេញពីសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មន្ត្រីអង្គភាពពាក់ព័ន្ធនៃសាលារាជធានី សាលាខណ្ឌ និងមន្ទីរ អង្គភាពពាក់ព័ន្ធនានាតាមការចាំបាច់។

ក្រុមប្រឹក្សារាជធានីត្រូវសម្រេចអំពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ។ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សារាជធានី ផ្អែកតាមការសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន។

## ជំពូកទី៣

## គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌ

### ផ្នែកទី១

### សមាសភាព និង តួនាទី ភារកិច្ច

**មាត្រា ១២.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនីមួយៗនៃរាជធានីភ្នំពេញមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - អភិបាលខណ្ឌ | ជាប្រធាន |
| - អភិបាលរងខណ្ឌ០១រូប | ជាអនុប្រធាន |
| - នាយករដ្ឋបាលសាលាខណ្ឌ | ជាសមាជិកអចិន្ត្រៃយ៍ |

- សមាជិកក្រុមប្រឹក្សាខណ្ឌយ៉ាងតិច០២រូប ជាសមាជិក
- ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានា របស់រាជរដ្ឋាភិបាលដែលប្រចាំនៅខណ្ឌ ជាសមាជិក
- ប្រធានការិយាល័យទាំងអស់របស់សាលាខណ្ឌ ជាសមាជិក
- ចៅសង្កាត់ទាំងអស់នៅក្នុងខណ្ឌ ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាខណ្ឌ០១រូប ជាសមាជិក

សមាសភាពអនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌ ត្រូវស្នើដោយអភិបាលខណ្ឌ។

ក្រុមប្រឹក្សាខណ្ឌត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌ។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខណ្ឌ។

**មាត្រា ១៣.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌ មានតួនាទី ភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌ លើកិច្ចការសំខាន់ៗដូចខាងក្រោម :

**ក. ផែនការអភិវឌ្ឍនិងថវិកា**

- សេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំនិងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំនិងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំរបស់រាជធានី
- សេចក្តីព្រាងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខណ្ឌ
- សេចក្តីព្រាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងការធ្វើបច្ចុប្បន្នភាព
- កៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធនានាដល់គម្រោងវិនិយោគខណ្ឌ
- កិច្ចសហប្រតិបត្តិការអនុវត្តគម្រោងអន្តរសង្កាត់
- របាយការណ៍រីកចម្រើននានា ទាក់ទងដល់ការងារអភិវឌ្ឍ កម្មវិធីវិនិយោគរបស់ខណ្ឌ។

**ខ. សម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាជាមួយការិយាល័យ អង្គភាពរបស់ក្រសួង ស្ថាប័ននានា**

- កិច្ចសហប្រតិបត្តិការ ការពិគ្រោះយោបល់ និងការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សាខណ្ឌជាមួយការិយាល័យ អង្គភាពរបស់ក្រសួង ស្ថាប័ន
- សម្របសម្រួលការផ្តល់សេវានិងការអភិវឌ្ឍដែលផ្តល់ដោយក្រសួង ស្ថាប័ន ឬ

ដោយការិយាល័យ អង្គភាពរបស់ក្រសួង ស្ថាប័ន ដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋាន

- ការសម្របសម្រួលភាពមិនចុះសម្រុងគ្នារវាងកិច្ចការរបស់ក្រុមប្រឹក្សាខណ្ឌ ជាមួយ ក្រសួង ស្ថាប័ន មន្ទីរ ការិយាល័យ អង្គភាពជំនាញនានា
- ការផ្តល់អនុសាសន៍ ដើម្បីកែលម្អការផ្តល់សេវា និងការអភិវឌ្ឍនានា ឱ្យស្របតាមតម្រូវការរបស់មូលដ្ឋាន។

**គ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពខណ្ឌ**

- ការរៀបចំយន្តការពិគ្រោះយោបល់និងការចូលរួមក្នុងដំណើរការអនុវត្តការងារនៃរដ្ឋបាលឯកភាពខណ្ឌ
- ការរៀបចំប្រព័ន្ធនិងនីតិវិធីបំពេញការងារ ព្រមទាំងទំនាក់ទំនងរបស់ការិយាល័យនានានៃសាលាខណ្ឌ
- ការសម្របសម្រួលនូវភាពមិនចុះសម្រុងគ្នាក្នុងការអនុវត្តការងាររបស់ការិយាល័យនានានៃសាលាខណ្ឌ។

**ឃ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាខណ្ឌជាមួយក្រុមប្រឹក្សាសង្កាត់នៅក្នុងខណ្ឌ**

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាខណ្ឌនិងក្រុមប្រឹក្សាខណ្ឌ និង រវាងក្រុមប្រឹក្សាខណ្ឌនិងក្រុមប្រឹក្សាសង្កាត់ក្នុងខណ្ឌ
- ការឆ្លើយតបចំពោះអនុសាសន៍ សំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាសង្កាត់ ក្នុងករណីដែលក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបាន
- ការសម្របសម្រួលនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាខណ្ឌនិងក្រុមប្រឹក្សាសង្កាត់ និង រវាងក្រុមប្រឹក្សាសង្កាត់និងក្រុមប្រឹក្សាសង្កាត់។

**ង. ការទទួលយកមុខងារនិងធនធាន**

- វិធានការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងធនធានដែលបានផ្ទេរ ប្រគល់
- ការរៀបចំនូវលក្ខណសម្បត្តិនិងមធ្យោបាយដើម្បីទទួលនិងអនុវត្តមុខងារ និង ធនធានដែលបានផ្ទេរប្រគល់ឱ្យរដ្ឋបាលខណ្ឌ
- ការផ្តួចផ្តើមស្នើឡើងនូវមុខងារនិងធនធានដែលគួរត្រូវបានផ្ទេរប្រគល់ឱ្យរដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់
- ការវាយតម្លៃលើការអនុវត្តមុខងារនិងធនធានដែលបានផ្ទេរប្រគល់ដោយរដ្ឋបាលរាជធានី។

ក្រៅពីកិច្ចការខាងលើនេះ គណៈកម្មាធិការអាចទទួលអនុវត្តកិច្ចការផ្សេងទៀត តាមតម្រូវការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ឬតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សារបស់ខ្លួន។

## ផ្នែកទី២
## របៀបរបបការងារ

**មាត្រា ១៤.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌ ត្រូវជួបប្រជុំយ៉ាងតិចពីរខែម្តង។ កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការទាំងមូល។

សេចក្តីសម្រេចនៃកិច្ចប្រជុំអាចយកជាការបាន លុះត្រាមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។

ប្រធានគណៈកម្មាធិការជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការត្រូវមានកំណត់ហេតុ ដែលរៀបចំឡើងដោយនាយករដ្ឋបាលសាលាខណ្ឌ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

ផ្អែកតាមអនុក្រឹត្យនេះ គណៈកម្មាធិការអាចកំណត់អំពីរបៀបរបបប្រជុំ ការអនុម័តរបៀបរបបការងារជាក់ស្តែងនិងការបែងចែកភារកិច្ចដល់សមាជិកគណៈកម្មាធិការតាមការចាំបាច់។

**មាត្រា ១៥.-**

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការ ដែលជានាយករដ្ឋបាលសាលាខណ្ឌ ចៅសង្កាត់ ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលប្រចាំនៅខណ្ឌ ប្រធានការិយាល័យនៃសាលាខណ្ឌ អវត្តមាន សមាជិកនោះអាចចាត់តំណាងដែលមានសិទ្ធិសម្រេចជំនួសខ្លួនឱ្យចូលរួមប្រជុំគណៈកម្មាធិការបាន។

**មាត្រា ១៦.-**

អភិបាលខណ្ឌអាចស្នើឱ្យអភិបាលរងខណ្ឌ មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធនានា ចូលរួមកិច្ចប្រជុំគណៈកម្មាធិការតាមការចាំបាច់។ អភិបាលរងខណ្ឌ មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធទាំងនោះ អាចផ្តល់យោបល់នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការបាន ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ។

**មាត្រា ១៧.-**

កិច្ចប្រជុំនីមួយៗរបស់គណៈកម្មាធិការត្រូវមានរបៀបវារៈ ដែលបានត្រៀមរៀបចំជាមុន។

អភិបាលខណ្ឌ ដោយមាននាយករដ្ឋបាលសាលាខណ្ឌជាជំនួយការ ត្រូវរៀបចំរបៀបវារៈប្រជុំ ដោយផ្អែកតាម ៖

- តម្រូវការរបស់ក្រុមប្រឹក្សាខណ្ឌ
- តម្រូវការរបស់គណៈអភិបាលខណ្ឌ
- តម្រូវការរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខណ្ឌ
- សំណើរបស់សមាជិកយ៉ាងតិចមួយភាគបីនៃចំនួនសមាជិកគណៈកម្មាធិការសម្រប សម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌ
- តម្រូវការនៃច្បាប់ឬលិខិតបទដ្ឋានគតិយុត្ត។

ផ្អែកតាមតម្រូវការនិងសំណើដូចខាងលើនេះ អភិបាលខណ្ឌត្រូវពិគ្រោះយោបល់នៅក្នុងគណៈអភិបាលរបស់ខ្លួន ចាត់ឱ្យការិយាល័យមួយឬច្រើន ដែលពាក់ព័ន្ធនៃសាលាខណ្ឌ ដើម្បីសិក្សា រៀបចំឯកសារ បែបបទ នីតិវិធីនានា តាមរបៀបវារៈនីមួយៗ។

នាយករដ្ឋបាលសាលាខណ្ឌត្រូវដឹកនាំការិយាល័យដែលពាក់ព័ន្ធនៅក្នុងសាលាខណ្ឌ សិក្សា រៀបចំឯកសារ បែបបទ នីតិវិធីខាងលើនេះ ដោយសហការជាមួយការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលប្រចាំនៅខណ្ឌ និងរដ្ឋបាលដែលពាក់ព័ន្ធនានាតាមការចាំបាច់។

ក្នុងករណីចាំបាច់ នាយករដ្ឋបាលសាលាខណ្ឌអាចស្នើសុំយោបល់ និងការគាំទ្រពីនាយករដ្ឋបាលសាលារាជធានី ក្នុងការរៀបចំឯកសារ បែបបទ នីតិវិធីខាងលើនេះ។

**មាត្រា ១៨.-**

ក្នុងការសិក្សា រៀបចំឯកសារ បែបបទ នីតិវិធីដូចមានចែងក្នុងមាត្រា១៧ខាងលើនេះ នាយករដ្ឋបាលសាលាខណ្ឌ ត្រូវផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តច្បាប់ទាំងនេះ ព្រមទាំងការណែនាំពីក្រុមប្រឹក្សា និង/ឬគណៈអភិបាលរាជធានី។

ក្រោយពេលរៀបចំឯកសារ បែបបទ នីតិវិធីតាមរបៀបវារៈនីមួយៗរួចហើយ នាយករដ្ឋបាលសាលាខណ្ឌត្រូវដាក់ជូនអភិបាលខណ្ឌ ដើម្បីពិនិត្យនិងរៀបចំកោះប្រជុំគណៈកម្មាធិការ។

**មាត្រា ១៩.-**

អភិបាលខណ្ឌ ដោយមាននាយករដ្ឋបាលសាលាខណ្ឌជាជំនួយការ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការ ដើម្បីដាក់ជូនក្រុមប្រឹក្សាខណ្ឌចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌ ឬដាក់ជូនគណៈអភិបាលខណ្ឌចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់គណៈអភិបាលខណ្ឌ។

**មាត្រា ២០.-**

ដើម្បីជួយសម្រួលដល់កិច្ចការរបស់ខ្លួន គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌ អាចស្នើសុំបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារតាមការចាំបាច់ ឬតាមតម្រូវការនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ឬតាមការណែនាំពីក្រុមប្រឹក្សានិង/ឬគណៈអភិបាលរាជធានី។

សមាសភាពអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ អាចជ្រើសចេញពីសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មន្ត្រីការិយាល័យពាក់ព័ន្ធនៃសាលាខណ្ឌ សមាជិកក្រុមប្រឹក្សាសង្កាត់និងការិយាល័យ អង្គភាពពាក់ព័ន្ធនានាតាមការចាំបាច់។

ក្រុមប្រឹក្សាខណ្ឌត្រូវសម្រេចអំពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខណ្ឌ ផ្អែកតាមការសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន។

## ជំពូកទី៤
## អំពីភារកិច្ច

**មាត្រា ២១.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំបន្ថែម អំពីការអនុវត្តតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌ ដោយផ្អែកតាមស្មារតីនៃអនុក្រឹត្យនេះ។

**មាត្រា ២២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មន្ត្រី បុគ្គលិកនៃសាលារាជធានី សាលាខណ្ឌ ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីធានាដល់ដំណើរការរបស់គណៈកម្មាធិការ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ២៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៨ ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.១៣៧៥..អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយ ថ្នាក់ ស្ថាបនាជាតិ** ជូននាយនគរបាលជាតិជាន់ខ្ពស់មានចិត្តសប្បុរសជួយឧបត្ថម្ភថវិកាផ្ទាល់ខ្លួន ដែលមានទឹកប្រាក់សរុបចំនួន ១៥.៩០០ ដុល្លា (ដប់ប្រាំពាន់ ប្រាំបួនរយដុល្លាសហរដ្ឋអាមេរិកគត់) ដើម្បីកសាងបន្ទប់ធ្វើការ ដែលមានទំហំ ៥ម × ៦មក្នុងស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យដូចមានរាយនាមខាងក្រោម :

១-លោកវរសេនីយ៍ទោ **គិន យ៉ាន** អត្តលេខ ០២៣៣៨ នាយរងការិយាល័យកណ្តាលបានឧបត្ថម្ភថវិកាចំនួន៥.៣០០ដុល្លា

២-លោកវរសេនីយ៍ត្រី **ជួន សួរ** អត្តលេខ ០៦៤២៦ នាយការិយាល័យ បានឧបត្ថម្ភថវិកា ចំនួន ៥.០២៥ ដុល្លា

៣-លោកវរសេនីយ៍ត្រី **ហម គិរម្យ** អត្តលេខ ០៩០៧២ នាយការិយាល័យ បានឧបត្ថម្ភថវិកា ចំនួន ៥.០២៥ ដុល្លា

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

***កន្លែងទទួល :***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា១ និងមាត្រា២*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:១៧៥៧.អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងកិច្ចការនារី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៤០០/១១៦ ចុះថ្ងៃទី០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

**សម្រេច**

**មាត្រា ១ :** ត្រូវបានផ្ទេរបញ្ចូលទៅក្នុង ឋានន្តរសក្តិ មន្ត្រីក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងកិច្ចការនារីជូនមន្ត្រីរាជការចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១-លោកស្រី **ប៉ែន ឆាវី** ឋានន្តរសក្តិ ក្រមការ ថ្នាក់លេខ ១៤

២-លោក **ប៉ុល ថូ** ឋានន្តរសក្តិ ក្រមការ ថ្នាក់លេខ ១៤

**មាត្រា ២ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៩*

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៧៤៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ឈេង សាមុត** ឱ្យបំពេញមុខងារជាអគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០៩*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧៥៩. អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោកស្រី **Helena Ahola** ប្រធានទីប្រឹក្សាផ្នែកអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការ តំណាងក្រសួងការបរទេសហ្វាំងឡង់ និងអង្គការ **IOM** ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជួយទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ជាមួយក្រសួងកិច្ចការនារី ចាប់ពីឆ្នាំ ២០០០ រហូតដល់ ២០០៩ នេះ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩*

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ១៧៧០ អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **ស៊ុន គីមលី** (Mr.SUN KIMLY) ប្រធានក្រុមហ៊ុន អេ-ជេ-ស៊ី ចំកាត់ ដែលបានចូលរួមជួយកសាងអគារសិក្សា និងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ និងទិញរទេះជូនជនពិការនៅតាមបណ្តាខេត្តមួយចំនួន ដូចជា សៀមរាប កណ្តាល រាជធានីភ្នំពេញ ព្រៃវែង កំពង់ចាម និង ខេត្តព្រះសីហនុ ចំណាយអស់ថវិកា ចំនួន ៥៦.៧៩១ ដុល្លារអាមេរិក ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧៦២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

**-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស**

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូននាយទាហាន និងមន្ត្រីរាជការ ចំនួន០៨រូប ដែលបានចូលរួមឧបត្ថម្ភជាថវិកា និងសម្ភារៈជាច្រើនជួយកសាងមន្ទីរពេទ្យ ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-*វរសេនីយ៍ឯក* | **ប្រុក សារ៉ុន** | នាយការិយាល័យបង្គប្រភពប្រេង |
| ២-*វរសេនីយ៍ឯក* | **នួច សុចត្ថិ** | នាយការិយាល័យផែនការប្រេង |
| ៣-*វរសេនីយ៍ទោ* | **នាក់ ឯកសុផល** | នាយរង កងដឹកជញ្ជូន |
| ៤-*វរសេនីយ៍ទោ* | **ទ៉ោយ សារឿន** | ជំនួយការហិរញ្ញវត្ថុ |
| ៥-*វរសេនីយ៍ទោ* | **ឡោក ស៊ីណា** | ជំនួយការហិរញ្ញវត្ថុ |
| ៦-*វរសេនីយ៍ទោ* | **ជន ច័ន្ទរដ្ឋ** | ជំនួយការហិរញ្ញវត្ថុ |
| ៧-*វរសេនីយ៍ទោ* | **និត្យ សុវណ្ណតារា** | នាយរងការិយាល័យវិស្វកម្ម |
| ៨-*វរសេនីយ៍ទោ* | **ព្រហ្ម ជន** | មេបញ្ជាការរងកងរាជអាវុធហត្ថ ខេត្តស្វាយរៀង |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ... ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:១៧៦២.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនអង្គការ **Room to Read Cambodia** ដែលបានចំណាយថវិកាសរុបចំនួន ៦៥៣.៧៧៥,៨៦ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារបណ្ណាល័យ ចំនួន ១០ខ្នង មាន១០បន្ទប់ សង់ពីបេតុង គ្រោងដំបូលដែក ប្រក់ក្បឿង និងបំពាក់គ្រឿងសង្ហារិម មណ្ឌលកុំព្យូទ័រ (**Computer Lab**) ចំនួន០៣មណ្ឌល និងបានផ្តល់អាហារូបករណ៍ ដល់កុមារីមួយចំនួនទៀតនៅសាលាបឋម សិក្សា អនុវិទ្យាល័យ ក្នុងខេត្តកំពង់ចាម និងខេត្តកំពង់ធំ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អភិបាលខេត្តកំពង់ចាម និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ១៧៦៣ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា១ .-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនលោក MASAO HOSONO ដែលបានផ្តល់ថវិកាសរុបចំនួន ១០៨.៦១០ ដុល្លារអាមេរិក តាមរយៈអង្គការមូលនិធិកុមារកម្ពុជា ក្នុងការជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ និងសម្ភារៈបរិក្ខារ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ ជូនដល់សាលាបឋមសិក្សាស្វាយផ្អែម ស្ថិតនៅភូមិស្វាយផ្អែម ឃុំស្វាយអង្គ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ HR

*រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ៩ ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ១៧៧៤ . អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- **តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

### សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០៣គ្រឿង ជូនអង្គការ សមាគម និងក្រុមហ៊ុន ដែលបានផ្តល់ថវិកាសរុបចំនួន ៤២.៤០០ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន០៣បន្ទប់ និងបង្គន់អនាម័យ ០១ខ្នង មាន០២បន្ទប់ ជូនដល់សាលាបឋមសិក្សាព្រៃរំចេក ស្ថិតនៅឃុំព្រៃស្វាយ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ដូចមានខាងក្រោម :-

១- ***អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍***

២- ***សមាគម*** ASSOCIATION OF FOLLOWING WIND-Japan

៣- ***ក្រុមហ៊ុនសំណង់*** DAIWA HOUSE-Japan

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១[illegible] ខែ ធ្នូ ឆ្នាំ ២០០៩
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ: ៦០៧ កសក..ប្រក

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់នូវឧបទេសពាក្យផ្ទៃក្នុងគំរូរបស់បុរេសហគមន៍កសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត / ០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ /នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម /០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៧០១ / ២៣៤ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃសហគមន៍អភិវឌ្ឍន៍កសិកម្ម សហភាពសហគមន៍អភិវឌ្ឍន៍កសិកម្ម និង បុរេសហគមន៍អភិវឌ្ឍន៍កសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស្ថុត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាស័យដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- បានឃើញប្រកាសលេខ៥៤៧ប្រក.កសក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៣ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវលក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូនៃសហគមន៍អភិវឌ្ឍន៍កសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានដាក់ឱ្យប្រើប្រាស់នូវបទបញ្ជាផ្ទៃក្នុងគំរូរបស់បុរេសហគមន៍កសិកម្ម ដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ។

**ប្រការ ២ :** គ្រប់បុរេសហគមន៍កសិកម្មត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងឱ្យសមស្របតាមស្ថានភាពជាក់ស្តែងរបស់ខ្លួនដោយផ្អែកលើគោលគំនិតដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងគំរូ និងត្រូវចុះបញ្ជិកានៅមន្ទីរកសិកម្មរាជធានី-ខេត្តសាមី ។

**ប្រការ ៣ :** អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកសិឧស្សាហកម្ម ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នាយកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ប្រធានមន្ទីរកសិកម្មរាជធានី-ខេត្ត និងគ្រប់បុរេសហគមន៍កសិកម្មត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញៈ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩

**កន្លែងទទួល :**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាស្តារ អភិវឌ្ឍវិស័យកសិកម្ម និង ជនបទ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់
-ក្រសួងផែនការ
- ក្រសួងអភិវឌ្ឍន៍ជនបទ
-ក្រសួងធនធានទឹក និងឧតុនិយម
-ក្រសួងកិច្ចការនារី
-ធនាគារជាតិនៃកម្ពុជា
-ធនាគារអភិវឌ្ឍន៍ជនបទ
-គ្រប់សាលារាជធានី-ខេត្ត
-ដូចប្រការ ៣
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ ៦០២ កសក.ប្រក ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩

# លក្ខន្តិកៈគំរូរបស់សហគមន៍កសិកម្ម

## ជំពូកទី ១
## គោលបំណង

**ប្រការ ១ :** ការបង្កើតសហគមន៍កសិកម្ម មានគោលបំណងជួយសម្រួលដល់ការដឹកនាំគ្រប់គ្រងលើសកម្មភាពផលិតកម្ម អាជីវកម្ម សេវាកម្ម សិប្បកម្ម ការទិញ-លក់កសិផល សម្ភារៈកសិកម្មរបស់សហគមន៍ឱ្យមានប្រសិទ្ធភាព សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់សមាជិកសហគមន៍ និងរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ។

**ប្រការ ២ :** សហគមន៍កសិកម្ម បង្កើតឡើងដោយប្រជាពលរដ្ឋខ្មែរយ៉ាងតិច ២៥ នាក់ ដែលមានគំនិតផ្តួចផ្តើមដោយផ្ទាល់ មានមុខរបរចម្បងស្ថិតនៅក្នុងវិស័យកសិកម្ម ឬ សេវាកម្មទាំងឡាយដែលទាក់ទងផ្ទាល់នឹងវិស័យកសិកម្ម ហើយ ប្រមូលផ្តុំគ្នាដោយស្ម័គ្រចិត្ត ។ សហគមន៍កសិកម្មត្រូវបានបង្កើតឡើងតាមរយៈសន្និបាតដំបូង ។ សហគមន៍ កសិកម្មត្រូវចុះឈ្មោះក្នុងបញ្ជីនៅមន្ទីរកសិកម្មរាជធានី ខេត្តសាមី ។

## ជំពូកទី ២
## នាមករណ៍ អាសយដ្ឋាន និង កម្មវត្ថុ

**ប្រការ ៣ :** សហគមន៍កសិកម្មឈ្មោះ :............................................................

ហៅកាត់ថា : ............................................................

អាសយដ្ឋាន : ផ្ទះលេខ..........ផ្លូវ................. ភូមិ..........................................

ឃុំ/សង្កាត់........................ក្រុង /ស្រុក/ខណ្ឌ ..............................ខេត្ត...............................

**ប្រការ ៤ :** សហគមន៍កសិកម្ម...............................មានកម្មវត្ថុ..........................................

............................................................................................

............................................................................................

............................................................................................

# ជំពូកទី ៣

# លក្ខខណ្ឌនៃការសុំចូលជាសមាជិក សិទ្ធិ និង ភារកិច្ច

**ប្រការ ៥ :** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងចូលជាសមាជិកបុរេសហគមន៍កសិកម្មត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម :

- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ ឆ្នាំឡើង
- មានមុខរបរចម្បងលើការងារកសិកម្ម ឬសេវាកម្មទាំងឡាយដែលទាក់ទងផ្ទាល់នឹងវិស័យកសិកម្ម
- ស្ម័គ្រចិត្តសុំចូលជាសមាជិកសហគមន៍តាមរយៈការដាក់ពាក្យ និងបង់ប្រាក់ចូលជាសមាជិកភាព ។

**ប្រការ ៦ :** សមាជិកខាងលើមានសិទ្ធិ :

- ចូលរួមប្រជុំមហាសន្និបាតនានា ហើយបោះឆ្នោតដោយស្មើភាពជាមួយនឹងសមាជិកផ្សេងទៀត ដោយពុំគិតពីកំរិតដើមទុនដែលបានវិនិយោគក្នុងសហគមន៍ឡើយ
- បោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតក្នុងការជ្រើសរើសជាសមាជិកគណៈនាយករបស់បុរេសហគមន៍កសិកម្ម
- ទទួលព័ត៌មានពីសមាជិកគណៈនាយក ពីសភាពការណ៍សេដ្ឋកិច្ច នៃបុរេសហគមន៍កសិកម្ម
- ស្នើសុំឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញដើម្បីធ្វើការពិភាក្សានិងសម្រេចលើបញ្ហាណាមួយ បើមានការគាំទ្រពីសមាជិក យ៉ាងតិចមួយភាគបី (១/៣) នៃចំនួនសមាជិករបស់បុរេសហគមន៍
- ស្នើសុំការត្រួតពិនិត្យមកពីក្រៅនៃសេវាពាណិជ្ជកម្មទទួលបន្ទុកខាងកសិកម្មបើមានពីរភាគបី(២/៣) នៃសមាជិកទាំងអស់ដែលបានស្នើសុំ
- ធ្វើសំណូមពរឱ្យដាក់បញ្ចូលក្នុងរបៀបវារៈនៃមហាសន្និបាតនូវបញ្ហាទាំងឡាយដែលមានប្រយោជន៍សម្រាប់បុរេសហគមន៍
- ទទួលប្រាក់ចំណេញតាមចំណែករបស់ខ្លួន
- ជួលសេវារបស់បុរេសហគមន៍កសិកម្ម និងគ្រឿងឧបករណ៍របស់សហគមន៍ដូចគ្នានឹងសមាជិកដទៃទៀតទាំងអស់
- ទទួលបាននូវភាគទុនដែលបានបង់គ្រប់ចំនួនហើយ បូកនឹងការប្រាក់ស្របតាមបទបញ្ជាផ្ទៃក្នុង ឬ ប្រាក់ដែលត្រូវបង្វិលមកវិញ ។ ដោយឡែកភាគទុន និងការប្រាក់អាចប្រែប្រួលឡើងចុះទៅតាមស្ថានភាពអតិរេក ឬ ឱនភាពមូលនិធិដែលបានជួបប្រទះជាក់ស្តែង ។

**ប្រការ ៧ :** សមាជិកបុរេសហគមន៍កសិកម្មមានកាតព្វកិច្ចដូចខាងក្រោម :

- ត្រូវគោរពបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត /០៧០១ / ២៣៤ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃសហគមន៍អភិវឌ្ឍន៍កសិកម្ម សហភាពសហគមន៍អភិវឌ្ឍន៍កសិកម្ម និង បុរេសហគមន៍អភិវឌ្ឍន៍កសិកម្ម
- ត្រូវគោរពបទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេច របស់មហាសន្និបាត បុរេសហគមន៍កសិកម្ម
- ត្រូវបង់ភាគទុនដែលបានចុះឈ្មោះទិញ ដោយអនុលោមទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងបុរេសហគមន៍កសិកម្ម
- ត្រូវទទួលខុសត្រូវរួមចំពោះបំណុលរបស់បុរេសហគមន៍កសិកម្មរបស់ខ្លួន ។ ការទទួលខុសត្រូវរបស់បុរេសហគមន៍កសិកម្មនេះ មានសុពលភាពរហូតដល់ទៅពីរ(០២)ឆ្នាំ ក្រោយពីការលាលែងរបស់សមាជិកចំពោះបំណុលដែលបុរេសហគមន៍បានខ្ចីមុនពេលដែលសមាជិកសាមីបានលាលែង ។

## ជំពូកទី ៤
## រចនាសម្ព័ន្ធបុរេសហគមន៍កសិកម្ម

**ប្រការ ៨ :** រចនាសម្ព័ន្ធបុរេសហគមន៍កសិកម្មមាន :

- មហាសន្និបាតដែលជាអង្គការកំពូល និង
- គណៈនាយកដែលជាអង្គការប្រតិបត្តិនៃបុរេសហគមន៍កសិកម្ម ។

**ប្រការ ៩ :** មហាសន្និបាតជាអង្គការកំពូល និងខ្ពស់បំផុតសម្រាប់ធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចចិត្តទាំងឡាយរបស់បុរេសហគមន៍កសិកម្ម ។ មហាសន្និបាតសាមញ្ញត្រូវរៀបចំធ្វើពីរ(០២)ដងក្នុងមួយឆ្នាំតាមការចាំបាច់របស់បុរេសហគមន៍។ សមាជិកបុរេសហគមន៍ទាំងអស់ត្រូវចូលរួមមហាសន្និបាតសាមញ្ញ ឬវិសាមញ្ញតាមការកោះអញ្ជើញរបស់ប្រធានគណៈនាយក។ ការកោះអញ្ជើញចូលរួមមហាសន្និបាតសាមញ្ញ ឬវិសាមញ្ញ ត្រូវបញ្ជាក់អំពីទីកន្លែង ថ្ងៃ ខែ ម៉ោង និង របៀបវារៈ ។

**ប្រការ ១០ :** មហាសន្និបាតមានភារកិច្ច :

- ឱ្យសច្ចានុម័តលើកំណត់ហេតុនៃកិច្ចប្រជុំកន្លងទៅ
- អនុម័ត ឬ កែសម្រួលបទបញ្ជាផ្ទៃក្នុង
- បោះឆ្នោតជ្រើសតាំងតាមរបៀបបោះឆ្នោតជាសម្ងាត់នូវប្រធាន និងសមាជិកដទៃទៀតនៃគណៈនាយក ក្នុងចំណោមសមាជិកបុរេសហគមន៍កសិកម្ម ហើយមហាសន្និបាតក៏អាចដកហូតតំណែងពីអ្នកទាំងនោះវិញ
- កំណត់ភារកិច្ចរបស់គណៈនាយក

- កំណត់កម្រិតអតិបរមានៃការជំពាក់បំណុល និងអនុញ្ញាតឱ្យវិនិយោគ ឬ ចងការមូលនិធិ
- អនុញ្ញាតឱ្យសមាជិកខ្ចីប្រាក់
- កំណត់ការបែងចែកប្រាក់ចំណេញ និងការបង្វិលប្រាក់ឱ្យសមាជិកវិញ
- កំណត់របៀបបំពេញឱនភាពជាយថាហេតុ
- អនុម័តកម្មវិធីសកម្មភាព និងថវិកាសម្រាប់គណៈនាយកចំពោះការិយបរិច្ឆេទខាងមុខ
- សម្រេចឱ្យចូល ព្យួរ និងបណ្តេញសមាជិកចេញ
- សម្រេចធ្វើបដិរូប ឬ រំលាយបុរេសហគមន៍កសិកម្ម ។

**ប្រការ ១១ :** មហាសន្និបាតសាមញ្ញ ឬ វិសាមញ្ញអាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានយ៉ាងតិចពីរភាគបី(២/៣) នៃចំនួនសមាជិកបុរេសហគមន៍កសិកម្ម ។ ក្នុងករណីដែលលក្ខខណ្ឌខាងលើពុំអាចបំពេញបានការកោះប្រជុំមហាសន្និបាតសាមញ្ញ ឬវិសាមញ្ញជាលើកទីពីរ(២)ដោយមានរបៀបវារៈដូចគ្នានិងរបៀបវារៈទីមួយ(១) ត្រូវធ្វើឡើងក្នុងរយៈពេលដប់(១០)ថ្ងៃ បន្ទាប់ពីថ្ងៃកំណត់សម្រាប់កិច្ចប្រជុំលើកទីមួយ(១) ។ កិច្ចប្រជុំលើកទីពីរ(២) នេះ ចំនួនសមាជិកវត្តមានពុំមានកំណត់ទេ ។ មហាសន្និបាតត្រូវដឹកនាំដោយប្រធានគណៈនាយក ឬប្រធានអង្គប្រជុំជ្រើសរើសថ្មីក្នុងចំណោមសមាជិកវត្តមាន ។ មហាសន្និបាតត្រូវតែងតាំងលេខាធិការអង្គប្រជុំម្នាក់ សម្រាប់ធ្វើកំណត់ហេតុ និងបញ្ជីវត្តមាន។ លេខាធិការ និងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ ។ សមាជិកនីមួយៗមានសម្លេងតែមួយគត់នៅក្នុងមហាសន្និបាត ហើយពុំអាចបញ្ជូនតំណាងមកជំនួសបានទេ។ សេចក្តីសម្រេចរបស់មហាសន្និបាតដែលទាក់ទងនឹងបទបញ្ជាផ្ទៃក្នុង ការធ្វើបដិរូប ឬ ការរំលាយបុរេសហគមន៍ ត្រូវឱ្យមានការយល់ព្រមពីរភាគបី(២/៣) នៃសមាជិកបុរេសហគមន៍ទាំងអស់ ។ សេចក្តីសម្រេចដទៃទៀតតម្រូវឱ្យមានការយល់ព្រមពីមតិភាគច្រើននៃសមាជិកវត្តមាន ។

**ប្រការ ១២ :** គណៈនាយកជាអង្គការប្រតិបត្តិរបស់បុរេសហគមន៍។ ប្រធានព្រមទាំងសមាជិកដទៃទៀតនៃគណៈនាយកត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសមាជិកបុរេសហគមន៍នាពេលមហាសន្និបាតសម្រាប់អាណត្តិបី(៣)ឆ្នាំ ។ សមាសភាពគណៈនាយកមានចំនួនយ៉ាងតិចបី(៣)នាក់ដែលបេក្ខនារីត្រូវបានលើកទឹកចិត្ត ។ ឪពុកម្តាយ បងប្អូនបង្កើត ប្តីប្រពន្ធ ពុំអាចធ្វើជាសមាជិក គណៈនាយកជាមួយគ្នាបានទេ។

សមាសភាពគណៈនាយករួមមាន :

- ប្រធាន
- សមាជិកម្នាក់ ជាហេរញ្ញិក
- សមាជិកម្នាក់ទៀត ជាលេខាធិការ

គណៈនាយកត្រូវជ្រើសរើសដោយការបោះឆ្នោតជាសម្ងាត់នូវហេរញ្ញិកមួយ(១)រូប និងលេខាធិការមួយ(១)រូប ក្នុងចំណោមសមាជិករបស់ខ្លួន តែបើក្នុងចំណោមសមាជិកមិនអាចរើសបាន អាចជ្រើសរើសបន្ថែមពីខាងក្រៅ ។

សមាជិកគណៈនាយកទទួលខុសត្រូវរៀងៗខ្លួនផង និងរួមគ្នាផងចំពោះកំហុសដែលបានធ្វើក្នុងការបំពេញមុខងាររបស់ខ្លួនដោយមិនទាន់គិតដល់ពីការទទួលខុសផ្នែកព្រហ្មទណ្ឌរបស់ខ្លួនឡើយ ។

**ប្រការ ១៣ :** លក្ខខណ្ឌនៃការកោះប្រជុំគណៈនាយក :

- ប្រធានគណៈនាយកជាតំណាងបុរេសហគមន៍ ត្រូវកោះប្រជុំគណៈនាយកមួយ (១) ខែម្តង
- ប្រធានគណៈនាយកអាចកោះប្រជុំវិសាមញ្ញបានតាមសំណើរបស់សមាជិកភាគច្រើនរបស់ខ្លួន ឬ ក្នុងករណីបន្ទាន់ចាំបាច់
- គណៈនាយកអាចប្រជុំបាន លុះត្រាតែមានសមាជិកវត្តមានពាក់កណ្តាលនៃសមាជិករបស់ខ្លួន
- សេចក្តីសម្រេចរបស់អង្គប្រជុំដែលចាត់ទុកជាបានការ គឺភាគច្រើនដាច់ខាតនៃសមាជិកវត្តមាន ។ ក្នុងករណីដែលចំនួនសម្លេងចែកជាពីរ (០២) ស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមានុភាព។

**ប្រការ ១៤ :** ភារកិច្ចរបស់គណៈនាយកមានដូចតទៅ :

- កាន់បញ្ជីគណនេយ្យសាមញ្ញរបស់បុរេសហគមន៍
- រៀបចំកិច្ចប្រជុំមហាសន្និបាតនានា
- ដាក់ជូនមហាសន្និបាតសាមញ្ញនូវរបាយការណ៍ស្តីពីការគ្រប់គ្រងការិយបរិច្ឆេទកន្លងទៅ កម្មវិធីសកម្មភាព និងគម្រោងថវិកាសម្រាប់ការិយបរិច្ឆេទខាងមុខ
- រៀបចំកិច្ចប្រជុំមហាសន្និបាតវិសាមញ្ញ កាលណាការប្រព្រឹត្តទៅរបស់បុរេសហគមន៍កសិកម្មតម្រូវឱ្យមានការពិភាក្សា អនុម័ត ឬ ធ្វើសេចក្តីសម្រេច ឬ តាមការស្នើសុំរបស់សមាជិកចំនួនពីរភាគបី(២/៣) នៃសមាជិកទាំងអស់ ។

**ប្រការ ១៥ :** បើមានសមាជិកបុរេសហគមន៍កសិកម្មចំនួនមួយភាគបី (១/៣) បានស្នើសុំពិនិត្យបញ្ជីគណនេយ្យ ឬ បញ្ជីផ្សេងទៀតនោះ គណៈនាយកត្រូវសម្រួលឱ្យពិនិត្យតាមការស្នើសុំ ដោយការចាត់តាំងតំណាងរបស់ខ្លួនដើម្បីពិនិត្យ។ បន្ទាប់ពីពិនិត្យរួច អ្នកតំណាងត្រូវជូនព័ត៌មានទៅគណៈនាយក រាយការណ៍ជូនសមាជិក និងមហាសន្និបាត។

**ប្រការ ១៦ :** គណៈនាយកអាចអញ្ជើញតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ គណៈអភិបាលក្រុង ស្រុក ខណ្ឌ និង ប្រធានមន្ទីរកសិកម្មរាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធផ្សេងទៀតចូលរួមជាកិត្តិយសក្នុងមហាសន្និបាត ។

លក្ខខណ្ឌនៃការកោះប្រជុំមាន :

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹង និង បិទប្រកាសនៅទីស្នាក់ការ
- សមាជិកបុរេសហគមន៍ត្រូវបានទទួលការអញ្ជើញចូលរួមដប់ប្រាំ (១៥) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាត
- សមាជិកបុរេសហគមន៍ត្រូវបានទទួលការអញ្ជើញប្រជុំប្រាំពីរ (៧) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ ។

## ជំពូកទី ៥
## ភាគទុនរបស់បុរេសហគមន៍កសិកម្ម

**ប្រការ ១៧ :** ភាគទុននីមួយៗត្រូវមានតម្លៃស្មើគ្នា ហើយត្រូវសម្រេចដោយមហាសន្និបាត ។ សមាជិកម្នាក់ៗត្រូវទិញមួយភាគទុនយ៉ាងតិចក្នុងតម្លៃ.............រៀល។ ភាគទុននីមួយៗត្រូវបង់ឱ្យគ្រប់ចំនួនក្នុងរយៈពេល...........ខែ ដោយគិតចាប់ពីថ្ងៃសម្រេចរបស់សន្និបាតកំណើតដំបូង ឬមហាសន្និបាត ។

សមាជិកម្នាក់ៗមិនអាចមានភាគទុនលើសពីម្ភៃភាគរយ(២០%) នៃចំនួនភាគទុនសរុបបានទេ ។

**ប្រការ ១៨ :** ភាគទុនមានឈ្មោះមិនអាចបំបែក មិនអាចរឹបអូសដោយតតិយជន មិនអាចលក់បានទេ គឺបានតែផ្ទេរពីសមាជិកម្នាក់ទៅសមាជិកម្នាក់ទៀតរបស់បុរេសហគមន៍ ឬ ទៅអ្នកទទួលកេរមរតកពីសមាជិកដោយអនុលោមទៅតាមច្បាប់ជាធរមាន និង ក្រោយពីមានការឯកភាពពីគណៈនាយក ។

**ប្រការ ១៩ :** សមាជិកម្នាក់ៗត្រូវបង់ប្រាក់ភាគទុនដែលបានទិញតាមការកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង។ សមាជិកម្នាក់ៗត្រូវទទួលខុសត្រូវរៀងៗខ្លួនផង និងរួមគ្នាផងចំពោះបំណុល និងលទ្ធផលហិរញ្ញវត្ថុរបស់បុរេសហគមន៍ទៅតាមសមាមាត្រនៃភាគទុនដែលសមាជិកបានទិញ ។

**ប្រការ ២០ :** សមាជិកណាដែលពុំបានបង់ប្រាក់សម្រាប់ភាគទុនរបស់ខ្លួន ពុំបានបង់ប្រាក់ផ្សេងៗទៀត ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនេះ ឬ ពុំបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួនចំពោះបុរេសហគមន៍កសិកម្ម ពុំអាចចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់បុរេសហគមន៍ ឬ ទាញយកចំណេញពីបុរេសហគមន៍ ឬ ក៏កាន់តំណែងក្នុងអង្គភាពផ្ទៃក្នុងណាមួយបានឡើយ។

## ជំពូកទី ៦
## ហិរញ្ញវត្ថុបុរេសហគមន៍ និង បញ្ជីឯកសារ

**ប្រការ ២១ :** ប្រភពហិរញ្ញវត្ថុបុរេសហគមន៍រួមមាន :

- ភាគទុនដែលទិញ និង បង់ដោយសមាជិក
- មូលនិធិបម្រុងដែលដកចេញពីប្រាក់ចំណេញ
- អំណោយជាកេរមរតក ឬ វិភាគទានផ្សេងៗ ពីសប្បុរសជន អង្គការនានា ឬ ការឧបត្ថម្ភពីរាជរដ្ឋាភិបាល
- កម្ចីពីតតិយជន
- កម្ចីពីសមាជិកដែលមានរូបភាពជាប្រាក់តម្កល់ ឬ ជាប្រាក់សន្សំ ។

**ប្រការ ២២ :** ដើមទុនរបស់បុរេសហគមន៍កសិកម្មអាចប្រែប្រួលទៅតាមការកើនឡើងបណ្តាលមកពីការចូលថែមសមាជិកថ្មី ឬ ការទិញភាគទុនបន្ថែម និងការថយចុះបណ្តាលមកពីសងបំណុល ឬ នៅពេលដែលមានដកភាគទុន ។

**ប្រការ ២៣ :** នៅពេលដំណើរការបានចំណេញ បុរេសហគមន៍កសិកម្មនឹងបង្កើត :

- មូលនិធិបម្រុងដោយដកយកម្ភៃភាគរយ(២០%)ពីប្រាក់ចំណេញសុទ្ធ ។ មូលនិធិបំរុងទាំងនេះមិនអាចយកទៅចែកចាយឱ្យសមាជិកបានទេ ។
- មូលនិធិសម្រាប់បណ្តុះបណ្តាលអប់រំដោយដកយកបីភាគរយ (៣ %)ពីប្រាក់ចំណេញសុទ្ធ ។

**ប្រការ ២៤ :** បុរេសហគមន៍កសិកម្មត្រូវរៀបចំឱ្យមានបញ្ជី និងឯកសារៈ

- ចំណូលចំណាយថវិកា
- សារពើភ័ណ្ឌ
- សមទិន
- សមាជិកសហគមន៍
- ភាគទុន
- កំណត់ហេតុអង្គប្រជុំគណៈនាយក
- កំណត់ហេតុអង្គប្រជុំមហាសន្និបាត និង
- កំណត់ហេតុអង្គប្រជុំអង្គភាពដទៃទៀតនៅក្នុងបុរេសហគមន៍ដែលមហាសន្និបាតបានបង្កើតឡើង ។

**ប្រការ ២៥ :** រាល់ការចំណាយ គណៈនាយកជាអ្នកទទួលខុសត្រូវទៅតាមផែនការរបស់មហាសន្និបាតកំណត់ និងផលប្រយោជន៍របស់បុរេសហគមន៍។ ហេរញ្ញិកជាអ្នកគ្រប់គ្រងថវិកាទាំងអស់ក្នុងសហគមន៍ និងថែរក្សានូវរាល់ឯកសារហិរញ្ញវត្ថុ ។

**ប្រការ ២៦ :** ថវិកាសម្រាប់ដំណើរការរបស់បុរេសហគមន៍ត្រូវសម្រេចដោយមហាសន្និបាត ។ បើថវិការបស់បុរេសហគមន៍មិនគ្រប់គ្រាន់តាមសេចក្តីត្រូវការសម្រាប់បម្រើសកម្មភាពបុរេសហគមន៍ទេនោះ ប្រធានគណៈនាយកអាចស្នើឱ្យមហាសន្និបាតសម្រេចខ្ចីទុនពីខាងក្រៅដោយមិនឱ្យលើសពីដប់(១០)ដង នៃដើមទុនសរុបរបស់បុរេសហគមន៍ទេ។ ការខ្ចីទុននេះត្រូវរក្សាបាននូវស្វ័យភាព និងឯករាជ្យភាពរបស់ខ្លួន ។ ក្នុងករណីដំណើរការខាត ប្រធានគណៈនាយកអាចស្នើឱ្យមហាសន្និបាតសម្រេចប្រើមូលនិធិបម្រុងសម្រាប់បំពេញការខាតបង់នេះ ។

**ប្រការ ២៧ :** ការបែងចែកប្រាក់ចំណេញឱ្យសមាជិកត្រូវសម្រេចដោយមហាសន្និបាត សមាមាត្រទៅតាមភាគទុនក្រោយពីបានទូទាត់ចំណាយ បំណុល មូលនិធិបម្រុង និងមូលនិធិបណ្តុះបណ្តាល ។

## ជំពូកទី ៧

## លក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញនៃសមាជិក

**ប្រការ ២៨ :** សមាជិកមានសិទ្ធិសុំលាឈប់ពីសមាជិកភាពនៃបុរេសហគមន៍កសិកម្មតាមរយៈការដាក់ពាក្យជាលាយល័ក្ខអក្សរដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់។ ចំពោះការដកភាគទុនត្រូវសម្រេចដោយមហាសន្និបាតរបស់បុរេសហគមន៍ ហើយភាគទុនថយចុះ ឬ កើនឡើងអាស្រ័យទៅលើស្ថានភាពហិរញ្ញវត្ថុជាក់ស្តែងរបស់បុរេសហគមន៍។

**ប្រការ ២៩ :** ក្នុងករណីដែលមានសមាជិកបុរេសហគមន៍ណាម្នាក់ធ្វើឱ្យមានការប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃបុរេសហគមន៍ ឬ សមាជិកបុរេសហគមន៍ដទៃទៀត សមាជិករូបនោះអាចត្រូវបានព្យួរសមាជិកភាព ឬ បណ្តេញចេញពីបុរេសហគមន៍ក្រោយពីបានការពារខ្លួននៅចំពោះមុខគណៈនាយក ។ ការព្យួរ ឬ ការបណ្តេញចេញសមាជិកភាពត្រូវសម្រេចដោយមហាសន្និបាត។ ក្នុងករណីមានការប្រញាប់ គណៈនាយកអាចប្រកាសជាបណ្តោះអាសន្ននូវការព្យួរ ឬ ការបណ្តេញចេញបាន តែត្រូវមានកោះប្រជុំមហាសន្និបាតវិសាមញ្ញជាបន្ទាន់ដើម្បីពិភាក្សា និងសម្រេចលើបញ្ហានេះ។ រយៈពេលនៃការព្យួរសមាជិកភាពមិនត្រូវឱ្យហួសពីមួយ(០១)ឆ្នាំឡើយ។

## ជំពូកទី ៨

## លក្ខខណ្ឌនៃការរំលាយបុរេសហគមន៍កសិកម្ម

**ប្រការ ៣០ :** មហាសន្និបាតត្រូវសម្រេចរំលាយបុរេសហគមន៍ចោល បើមានមូលហេតុដូចតទៅ :

- គ្មានសកម្មភាពក្នុងរយៈពេលបី (៣) ឆ្នាំជាប់ៗគ្នា គិតចាប់ពីថ្ងៃចុះបញ្ជិការផ្លូវការ
- ធនក្ស័យ ឬអសោធនភាពជាប្រចាំ ។ ដោយមិនបង្អែរបង្អង់មហាសន្និបាតត្រូវជ្រើសតាំងអ្នកជម្រះបញ្ជីដែលមានសមត្ថកិច្ច និងមានសមត្ថភាពម្នាក់ ឬ ច្រើននាក់ជាសមាជិក ឬ មិនមែនជាសមាជិកបុរេសហគមន៍។ ក្នុងករណីដែលមហាសន្និបាតមិនព្រមរំលាយបុរេសហគមន៍ទោះជាបានដឹងថាមានមូលហេតុដូចខាងលើបានកើតមានហើយក៏ដោយ ក៏តុលាការមានសមត្ថកិច្ចត្រូវសម្រេចរំលាយដោយស្វ័យប្រវត្តិ បើសិនជាមានការតវ៉ាណាមួយ។

**ប្រការ ៣១ :** បុរេសហគមន៍កសិកម្មជាសហគមន៍កសិកម្មបណ្តោះអាសន្នដែលមិនអាចមានអត្ថិភាពលើសពីបី(០៣)ឆ្នាំបានឡើយ។ ពេលចប់រយៈពេលនេះ បុរេសហគមន៍កសិកម្មមានជម្រើសពីរយ៉ាង ឬ មួយក្លាយខ្លួនទៅជាសហគមន៍កសិកម្មដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃសហគមន៍អភិវឌ្ឍន៍កសិកម្ម សហភាពសហគមន៍អភិវឌ្ឍន៍កសិកម្ម និងបុរេសហគមន៍អភិវឌ្ឍន៍កសិកម្ម ឬ មួយរំសាយខ្លួន។ ក្នុងករណីពិសេស បុរេសហគមន៍អាចធ្វើពាក្យសុំទៅមន្ទីរកសិកម្មខេត្តបានដោយបញ្ជាក់មូលហេតុសមរម្យ

ដើម្បីសុំបន្តនៅជាបុរេសហគមន៍កសិកម្មសម្រាប់រយៈពេលពីរ(០២) ឆ្នាំតទៅទៀត ក្នុងន័យថាខ្លួននឹងបដិរូបជាសហគមន៍កសិកម្មក្នុងលក្ខណៈគាប់ប្រសើរក្នុងចន្លោះពេលនេះ ។

**ប្រការ ៣២ :** បុរេសហគមន៍កសិកម្មអាចប្តូរទៅជាសហគមន៍តែម្នាក់ឯង ឬមួយចូលរួមជាមួយបុរេសហគមន៍ដទៃទៀតដែលមានបំណងដូចគ្នាបាន។ បដិរូបកម្មបុរេសហគមន៍កសិកម្មទៅជាសហគមន៍កសិកម្ម ត្រូវសម្រេចដោយមហាសន្និបាតវិសាមញ្ញ។ មហាសន្និបាតនេះ នឹងក្លាយទៅជាសន្និបាតកំណើតដំបូងសហគមន៍កសិកម្មដែលត្រូវបង្កើត។ ក្នុងករណីដែលមានបុរេសហគមន៍កសិកម្មច្រើនបញ្ចូលគ្នាដើម្បីបង្កើតសហគមន៍ សន្និបាតកំណើតដំបូងត្រូវមានសមាសភាពមកពីមហាសន្និបាតនៃក្រុមដែលបញ្ចូលគ្នា រួមគ្នាជាមហាសន្និបាតវិសាមញ្ញ ។

## ជំពូកទី ៩
## នីតិវិធីនៃការដោះស្រាយពេលរំលាយបុរេសហគមន៍ និងវិវាទ

**ប្រការ ៣៣ :** អ្នកជម្រះបញ្ជីត្រូវទទួលរ៉ាប់រងអំណាចទាំងអស់ពីគណៈនាយក ចាប់ពីថ្ងៃតែងតាំងទៅ ហើយត្រូវយកអំណាចនេះទៅប្រើសម្រាប់តែជាកម្មវត្ថុនៃការជម្រះបញ្ជីប៉ុណ្ណោះ។ មុននឹងចាប់ដំណើរការជម្រះបញ្ជីអ្នកជម្រះបញ្ជីត្រូវធ្វើតារាងតុល្យការ។ បន្ទាប់ពីបិទការជម្រះបញ្ជី សហគមន៍ត្រូវបានលុបឈ្មោះចេញពីបញ្ជី។ ការលុបឈ្មោះពីបញ្ជី ត្រូវផ្សព្វផ្សាយតាមរបៀបដូចការចុះបញ្ជីដែរ ។ តាមរយៈនេះ ម្ចាស់បំណុលដែលបានប្រកាសអំពីបំណុលរបស់ខ្លួនឱ្យគេដឹងឮ ត្រូវតវ៉ាក្នុងរយៈពេលប្រាំមួយ(៦)ខែ បន្ទាប់ពីការចុះផ្សាយតាមតារាងបែងចែកសំណងដែលកំណត់ឡើងដោយអ្នកជម្រះបញ្ជី ។

**ប្រការ ៣៤ :** ក្រៅពីសិទ្ធិរបស់ជនគ្រប់រូបប្តឹងទៅតុលាការ វិវាទទាំងឡាយដែលកើតចេញពីការអនុវត្តន៍បទបញ្ជាផ្ទៃក្នុងនេះរវាងសមាជិក និងសមាជិកបុរេសហគមន៍ក្តី រវាងអង្គភាពផ្ទៃក្នុងនៃបុរេសហគមន៍ក្តី ឬ រវាងអង្គភាពក្រៅណាមួយ និងបុរេសហគមន៍ក្តី គ្រប់វិវាទទាំងអស់នោះត្រូវដាក់ក្រោមមជ្ឈត្តវិនិច្ឆ័យរបស់រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ដែលត្រូវតែងតាំងគណៈកម្មាធិការមួយដែលមានតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទម្នាក់ តំណាងអាជ្ញាធរ ឃុំ-សង្កាត់ ម្នាក់ ព្រមទាំងបុគ្គលដែលមិនពាក់ព័ន្ធនឹងវិវាទនេះមួយចំនួនដែលក្រសួងកសិកម្មរុក្ខា ប្រមាញ់ និង នេសាទ យល់ឃើញថាអាចនឹងជួយជ្រោមជ្រែងក្នុងការដោះស្រាយវិវាទនេះ ។

## ជំពូកទី ១០
## និតិវិធីនៃការកែប្រែបទបញ្ជាផ្ទៃក្នុង

**ប្រការ ៣៥** : ការកែប្រែបទបញ្ជាផ្ទៃក្នុងបុរេសហគមន៍ត្រូវសម្រេចដោយមហាសន្និបាត។ ការលើកសំណើកែប្រែបទបញ្ជាផ្ទៃក្នុងត្រូវធ្វើឡើងដោយសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈនាយកមួយ(១)ខែមុនបើកមហាសន្និបាត ។ បទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបានលុះត្រាតែមានសំលេងយល់ព្រមពីរភាគបី (២/៣) នៃសមាជិកវត្តមានក្នុងមហាសន្និបាតកំណើតដំបូង។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**ប្រការ ៣៦** : បទបញ្ជាផ្ទៃក្នុងនេះបានអនុម័តដោយសន្និបាតកំណើតដំបូងរបស់បុរេសហគមន៍នៅថ្ងៃទី.....ខែ........ឆ្នាំ ......... និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា ឬ ស្នាមមេដៃនៃសមាជិកអ្នកបង្កើត ។

**********

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ២០៥.........ប្រក.កសក

# ប្រកាស

## ស្ដីពី

## ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តស្វាយរៀង

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ ស្ដីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
No. 200 Preah Norodom Blvd. Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ

# សម្រេច

**ប្រការ ១.-**

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តស្វាយរៀង សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមលក្ខណៈសហគមន៍ព្រៃឈើ ដែលមានទីតាំងស្ថិតនៅក្នុងផ្នែករដ្ឋបាលព្រៃឈើស្វាយរៀង នៃខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម ។

**ប្រការ ២.-**

ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលបំណង :

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវៈចម្រុះ និង អភិវឌ្ឍព្រៃសហគមន៍ឱ្យមាននិរន្តរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើ ជាលក្ខណៈប្រពៃណី សម្រាប់ការរស់នៅ ទំនៀមទម្លាប់ និង ជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមសក្តានុពល និង លទ្ធភាពធនធានព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ៣.-**

តំបន់ព្រៃសហគមន៍នេះមានចំនួន ០៣កន្លែង ដែលមានផ្ទៃក្រឡាសរុបចំនួន ៥០៤( ប្រាំរយបួន) ហិកតា ដូចមានក្នុងផែនទីភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ និង ជាប្រព័ន្ធខ្សែព្រំបិទជិត កំណត់ដោយចំណុចគោល និងនិយាមកា ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។

**ប្រការ ៤.-**

ដំណើរការរៀបចំ និង ការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើ ក្នុងប្រកាសនេះត្រូវអនុវត្តតាមនីតិវិធី ដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និង ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។

**ប្រការ ៥.-**

ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានមន្ទីរកសិកម្មខេត្តស្វាយរៀង និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៩

ចាន់ សារុន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី ✓
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្ត ស្វាយរៀង
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី២:** ភ្ជាប់ប្រកាសលេខ.....៦០៥ ប្រក.កសក.....ចុះថ្ងៃទី..១៥...ខែ..៨...ឆ្នាំ២០០៩

## ទីតាំងព្រៃសហគមន៍ក្នុងខេត្តស្វាយរៀង

| ល.រ | ឈ្មោះសហគមន៍ | ផ្ទៃដី (ហិកតា) | និយាមកា UTM | | | | | | | ចំនួន ភូមិ | ឃុំ | ស្រុក | ផ្នែករដ្ឋបាលព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | កំណត់បណ្តាញប្រឹវពិភាគ ឥណ្ឌា ១៩៦០ | | | | | | | | | | |
| 1 | មនោរម្យ ១០០ហិកតា | ៣០ | ជើង | A | 614768 | 1226520 | B | 615592 | 1226255 | ១ | មនោរម្យ | ស្វាយទៀប | ស្វាយរៀង |
| | | | កើត | B | 615592 | 1226255 | C | 615606 | 1226010 | | | | |
| | | | ត្បូង | C | 615606 | 1226010 | D | 614997 | 1225778 | | | | |
| | | | លិច | D | 614997 | 1225778 | A | 614768 | 1226520 | | | | |
| | | ៧០ | ជើង | A1 | 616455 | 1227672 | B1 | 617101 | 1227567 | | | | |
| | | | កើត | B1 | 617101 | 1227567 | C1 | 617232 | 1226494 | | | | |
| | | | ត្បូង | C1 | 617232 | 1226494 | D1 | 616761 | 1226309 | | | | |
| | | | លិច | D1 | 616761 | 1226309 | A1 | 616455 | 1227672 | | | | |
| 2 | ចំការកូនគគីរ | ៤០៤ | ជើង | A2 | 618317 | 1221135 | B2 | 621561 | 1222034 | ៤ | បាទី | បាវិត | ស្វាយរៀង |
| | | | កើត | B2 | 621561 | 1222034 | C2 | 621685 | 1220514 | | | | |
| | | | ត្បូង | C2 | 621685 | 1220514 | D2 | 618439 | 1220254 | | | | |
| | | | លិច | D2 | 618439 | 1220254 | A2 | 618317 | 1221135 | | | | |
| ផ្ទៃដីសរុប | | ៥០៤ | | | | | | | | ៥ | 2 | 2 | 1 |